**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា**

# ការអនុវត្តថវិកាកម្មវិធី
# របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

កម្មសិក្សាពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧

ឈ្មោះស្ថាប័ន៖ **ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**


តាក់តែងដោយ៖

និស្សិតឈ្មោះ៖ **ជា សៀវ៉ា**
**ទឹម ដានិត**

សាស្ត្រាចារ្យណែនាំ

**លោកស្រី ឡុង ម៉ាមីឌី**


| | | | |
|---|---|---|---|
| ថ្នាក់បរិញ្ញាបត្រ | វិទ្យាសាស្ត្រសេដ្ឋកិច្ច | ឆ្នាំចូលសិក្សា | ២០១៣ |
| ជំនាញគ្រប់គ្រងធុរកិច្ច | ជំនាន់ទី ១៦ | ឆ្នាំសរសេររបាយការណ៍ | ២០១៧ |

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ជា សៀវ៉ា** និង **ទឹម ដានិត** ជានិស្សិតបរិញ្ញាបត្រផ្នែកគ្រប់គ្រងធុរកិច្ចជំនាន់ទី១៦នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមថ្លែងអំណរគុណដ៏ប្រសើរឧត្តុងឧត្តមជ្រាលជ្រៅអស់ពីដួងចិត្តជូនចំពោះលោកឪពុក និងអ្នកម្តាយដែលជាអ្នកមានគុណមិនអាចកាត់ថ្លៃបានដែលបាន ធ្វើឱ្យខ្ញុំសម្រេចតាមគោលបំណងប្រាថ្នាដោយសារជំបូន្មានអ្នកមានគុណនេះ។

ព្រមទាំងសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ជូនចំពោះបងប្អូនទាំងអស់ដែលបានជួយផ្តល់កម្លាំងចិត្តនិងលើកទឹកចិត្តដល់រូបយើងខ្ញុំរហូតដល់បានសំរេចជាផ្លែផ្កាជាទីមោទនភាព ។

ជាងនេះទៅទៀតសូមថ្លែងអំណរគុណអរគុណ ដ៏ស្មោះស្ម័គ្រចំពោះលោកសាកលវិទ្យាធិការសាកលវិទ្យាធិការរងសាស្ត្រចារ្យទាំងអស់ និងបុគ្គលិកការិយាល័យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានយកចិត្តទុកដាក់បង្ហាត់បង្រៀនដឹកនាំគ្រប់គ្រងដល់យើងខ្ញុំប្រកបដោយកាយវិការគួរជាទីគោរពស្រឡាញ់។

ជាពិសេសសូមថ្លែងអំណរគុណដ៏ស្មោះអស់ពីដួងចិត្តជូន ចំពោះលោកស្រីសាស្ត្រាចារ្យ **ឡុង ម៉ាមីឌី** ដែលបានជួយផ្តល់យោបល់និងកែលំអរនូវរបាយការណ៍ស្រាវជ្រាវនេះដោយមិនគិតពីភាពនឿយហត់ក្នុងការបង្កើតឡើងឱ្យលេចជារូបរាងគួជាទីពេញចិត្ត ។ ជាងនេះទៅទៀតខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរជូនចំពោះបងប្រុស និងបងស្រីនៅការិយាល័យរដ្ឋបាលនិងហរិញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលបានផ្តល់ឯកសារជាច្រើនក្នុងការសរសេររបាយការណ៍ស្រាវជ្រាវអំពី ការអនុវត្តថវិកាកម្មវិធី របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ជាទីបញ្ចប់ខ្ញុំសូមគោរពជូនពរលោកអ្នកដែលមានគុណ ទាំងឡាយព្រមទាំងបងប្អូនទាំងអស់និងសូមគោរពជូនពរសម្តេចឯកឧត្តមលោកជំទាវលោកលោកស្រីអ្នកនាងកញ្ញា ទាំងអស់ជួបប្រទះពុទ្ធពរទាំងឡាយបួនប្រការគឺអាយុ:វណ្ណៈសុខ:ពល:កំបីឃ្លាងឃ្លាតឡើយ។

# អារម្ភកថា

ដោយសង្កេតឃើញពីការអនុវត្តថវិកា របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈការធ្វើផែនថវិកាដែលមានការរៀបចំ ការព្យាករណ៍ ការគ្រោងចំណូល និង កញ្ចប់ថវិកាសម្រាប់ចំណាយប្រកបដោយប្រសិទ្ធភាព និងភាពសិក្តសិទ្ធហើយការអនុវត្តថវិកាទាំងនេះ សុទ្ធតែមានគោលការណ៍ និងសេចក្តីណែនាំ ដើម្បីឱ្យស្ថាប័នរដ្ឋនីមួយៗចំណាយថវិកាបានត្រឹមត្រូវ និងមានភាពស័ក្តសិទ្ធស្របតាមកម្មវិធី និងច្បាប់របស់រាជរដ្ឋាភិបាល ព្រមទាំងមានការចូលរួមពីភ្នាក់ងារ របស់រដ្ឋាភិបាលក្នុងការអនុវត្ត និងវាយតម្លៃការអនុវត្តថវិកាទាំងនោះផងដែរ ។ ដោយឡែកការអនុវត្តថវិកាកម្មវិធីចាំបាច់ទាមទារអោយមានការរៀបចំផែនការថវិកា តាមរយៈការព្យាករណ៍ ការប៉ាន់ស្មាន និងការប្រមើលមើលនូវការចំណាយដែលមានភាពសន្សំសំចៃ និងចំគោលដៅ ។ តែការអនុវត្តថវិកាកម្មវិធីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចប្រព្រឹត្តទៅបានល្អ តម្រូវឱ្យមានទិន្នន័យច្បាស់លាស់ ។ ដោយប្រការខាងលើនេះ អត្ថបទទាំងមូលចង់បង្ហាញអំពីធាតុផ្សំ មួយចំនួននៃការអនុវត្តថវិកាកម្មវិធីរបស់ក្រសួង ជាពិសេសផ្តោតទៅលើការអនុវត្តថវិកាកម្មវិធីផ្ទាល់ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីជាជំនួយក្នុងការស្វែងយល់ការអនុវត្តផ្ទាល់ និងគោលការណ៍ដែលបានដាក់ចេញ តើមានលក្ខណៈត្រឹមត្រូវទៅតាមគោលការណ៍ដែលបានដាក់ចេញឬទេ ហើយក៏ជាជំនួយសម្រាប់ការធ្វើផែនការ និងអនុវត្តជាក់ស្តែងឱ្យមានប្រសិទ្ធភាព ។

ជាទីបញ្ចប់នេះ សមិទ្ធផលនៃរបាយការណ៍បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញគ្រប់គ្រងធុរកិច្ចនេះ និងអាចផ្តល់នូវចំណេះដឹងថ្មីៗ ពាក់ព័ន្ធទៅនិងការអនុវត្តថវិកាកម្មវិធីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាប្រធានបទថ្មី និងអាចជាជំនួយដល់និស្សិត និងអ្នកអានទាំងឡាយដែលចង់ដឹងអំពីប្រធានបទនេះ ឬមានបំណងចង់ស្រាវជ្រាវប្រធានបទបន្ថែមដែលមានលក្ខណៈប្រហាក់ប្រហែលនេះ ។ ជាពិសេសជាងនេះទៅទៀតការសរសេររបាយការណ៍បញ្ចប់ឆ្នាំសិក្សានេះ គឺជាបទពិសោធន៍ដំបូងរបស់យើងខ្ញុំទាំងពីរនាក់ហេតុនេះហើយយើងខ្ញុំសូមអភ័យទោសនូវរាល់កំហុសខុសឆ្គងដែលកើតឡើងដោយអចេតនា យើងខ្ញុំនិងរងចាំ ទទួលនូវការរិះគន់ និងកែលម្អគ្រប់ពេលវេលាអំពីគ្រប់មជ្ឈដ្ឋានដោយក្តីសោមនស្សរីករាយ។

# មាតិកា

បញ្ជីអក្សរកាត់ ..... iv
បញ្ជីតារាង ..... v
បញ្ជីក្រាហ្វិក ..... vi

## សេចក្តីផ្តើម

១.លំនាំបញ្ហានៃការស្រាវជ្រាវ ..... ១
២.ចំណោទបញ្ហានៃការស្រាវជ្រាវ ..... ២
៣.គោលបំណង់នៃការស្រាវជ្រាវ ..... ២
៤.សារៈសំខាន់នៃការស្រាវជ្រាវ ..... ៣
៥.ទំហំនិងដែនកំណត់នៃការស្រាវជ្រាវ ..... ៣
៦.វិធីសាស្រ្តនៃស្រាវជ្រាវ ..... ៤
៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ..... ៤

## ជំពូកទី១
## ទ្រឹស្តីជាមូលដ្ឋាននៃថវិកាកម្មវិធី

១.១ ទិដ្ឋភាពទូទៅរបស់ថវិកា ..... ៦
១.១.២ និយមន័យថវិកាកម្មវិធី ..... ៧
១.២ ការរៀបចំកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល (ក.ស.វ) ..... ៧
១.២.១ និយមន័យ ..... ៧
១.២.២ គោលបំណងនៃការរៀបចំកម្មវិធីវិយោគសាធារណៈបីឆ្នាំរំកិល ..... ៧
១.២.៣ វិធាននៃការរៀបចំកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល ..... ៨
១.២.៣.១ ការរៀបចំក.ស.វបីឆ្នាំរំកិលរបស់រាជរដ្ឋាភិបាល ..... ៨
១.៣.៣.២ ការរៀបចំក.ស.វបីឆ្នាំរំកិលរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ..... ៩
១.៣ ការរៀបចំផែនការយុទ្ធសាស្រ្តថវិកា ..... ១០
១.៣.១ និយមន័យ ..... ១០
១.៣.២ សារាចរៀបចំផែនការយុទ្ធសាស្រ្តថវិកាប្រចាំឆ្នាំ ..... ១០
១.៣.៣ អត្ថប្រយោជន៍នៃការរៀបចំផែនការយុទ្ធសាស្រ្តថវិកា ..... ១១
១.៣.៤ រចនាសម្ព័ន្ធសៀវភៅផែនការយុទ្ធសាស្រ្តថវិកា ..... ១២
១.៣.៥ ប្រតិទិននៃការរៀបចំផែនការយុទ្ធសាស្រ្តថវិកា ..... ១៣
១.៤ ការគ្រោងកញ្ចប់ថវិកាប្រចាំឆ្នាំ ..... ១៤

១.៤.១ គម្រោងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ............................. ១៤
១.៤.១.១ សារាចរណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៦ ........... ១៤
១.៤.១.២ ប្រតិទិននៃការរៀបចំកញ្ចប់ថវិកាប្រចាំឆ្នាំ ........................................ ១៦
១.៥ ការត្រៀមការអនុវត្តថវិកា ................................................................... ១៧
១.៥.១ អាណាប័ក ..................................................................................... ១៧
១.៥.២ ក្រុមការងារថវិកា ........................................................................... ១៨
១.៥.២.១ ក្រុមលទ្ធកម្ម ........................................................................... ១៩
១.៥.២.២ រដ្ឋទេយ្យករចំណូល ................................................................... ២៦
១.៥.២.៣ រដ្ឋទេយ្យករបុរេប្រទាននិងរដ្ឋទេយ្យបុរេប្រទានរង ................................ ២៧
១.៥.២.៤ ភ្នាក់ងារបើកផ្តល់និងភ្នាក់ងារបើកផ្តល់ជំនួស ........................................ ៣០
១.៦ ការរៀបចំសំណើរសុំចំណាយនិងការទូទាត់ចំណាយ .................................. ៣៣
១.៦.១ ដំណើរការនៃការស្នើសុំចំណាយ ........................................................ ៣៣
១.៦.២ ចំណាយបន្ទុកបុគ្គលិក .................................................................... ៣៥
១.៦.៣ ចំណាយក្រៅបន្ទុកបុគ្គលិក ................................................................ ៣៦
១.៧ ការកត់ត្រាសន្និធិឥណទាន .................................................................. ៣៨
១.៨ ការធ្វើចលនាឥណទាន ........................................................................ ៣៩
១.៨.១ ការស្នើសុំធ្វើនិយ័តកម្មឥណទាន ........................................................ ៣៩
១.៨.១.១ និយ័តកម្មឥណទានថវិកាសម្រាប់រដ្ឋបាលថ្នាក់កណ្តាល ............................ ៣៩
១.៨.១.២ និយ័តកម្មឥណទានថវិកាសម្រាប់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ...................... ៤០
១.៨.២ ការផ្ទេរនិងនិយ័តកម្មឥណទានដែលមិនអនុញ្ញាតលើអនុគណនី ........................ ៤១
១.៩ ការត្រួតពិនិត្យនិងការតាមដានការអនុវត្តថវិកាកម្មវិធី ................................... ៤២
១.៩.១ របាយការណ៍ហិរញ្ញវត្ថុនៃការអនុវត្តថវិកាកម្មវិធី ...................................... ៤២
១.៩.២ របាយការណ៍សមិទ្ធកម្មនៃការអនុវត្តថវិកាកម្មវិធី ...................................... ៤៣

## ជំពូកទី២

## ស្ថានភាពទូទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

២.១ ប្រវត្តិក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ........................................................ ៤៤
២.២ រចនាសម្ព័ន្ធរបស់ក្រសួងសេដ្ឋកិច្ចនិងហរិញ្ញវត្ថុ ................................................ ៤៥
២.៣ រចនាសម្ព័ន្ធគោលបំណងគោលនយោបាយរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ............. ៤៧
២.៤ ភារកិច្ចនិងការទទួលខុសត្រូវ ............................................................... ៤៨

២.៤.១ កម្មវិធីទី១ពង្រឹងនិងបង្កើនប្រសិទ្ធិភាពនៃការគ្រប់គ្រងសេដ្ឋកិច្ច ............................ ៤៨
២.៤.២ កម្មវិធីទី២ពង្រឹងនិងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងការត្រួតពិនិត្យនិងការអភិវឌ្ឍ វិស័យហិរញ្ញវត្ថុ ............................................................................................ ៤៨
២.៤.៣ កម្មវិធីទី៣ពង្រឹងនិងបង្កើនស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាពនៃការគ្រប់គ្រងការកៀរគរ ចំណូលថវិកាជាតិ និងទ្រព្យសម្បត្តិរដ្ឋ ............................................................ ៤៩
២.៤.៤ កម្មវិធីទី៤ពង្រឹងនិងបង្កើនស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាពនៃការគ្រប់គ្រងចំណាយ សាធារណៈ............................................................................................................ ៤៩
២.៤.៥ កម្មវិធីទី៥ពង្រឹងនិងបង្កើនស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាពនៃការគាំទ្រទូទៅនិងការ ធានាគណនេយ្យភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ................................. ៥០

## ជំពូកទី៣
## ការអនុវត្តថវិកាកម្មវិធី និងការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ

៣.១ ផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០១៦-២០១៨ .................................................................. ៥២
៣.១.១ ផ្នែកចំណូល ................................................................................................ ៥២
៣.១.២ ផ្នែកចំណាយ................................................................................................ ៥៣
៣.២ របាយការបោះផ្សាយអាណត្តិបើកប្រាក់ទូទាត់ចំណាយតាមខែ........................................ ៥៤
៣.៣ ចលនាឥណទាន ...................................................................................................... ៥៥
៣.៤ សមតុល្យឥណទានចំណាយនៅសល់ តាមអង្គភាពថវិកា ............................................... ៥៦
៣.៥ លម្អិតលទ្ធផលនៃការអនុវត្តចំណាយ នៅតាមអង្គភាពថវិកាថ្នាក់មូលដ្ឋាន ...................... ៥៧
៣.៦ ការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ .......................................................................... ៥៨
៣.៦.១ ការវិភាគចំណុចខ្លាំង ........................................................................................ ៥៨
៣.៦.២ ការវិភាគចំណុចខ្សោយ ...................................................................................... ៥៩

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

១. សេចក្តីសន្និដ្ឋាន.......................................................................................................... ៦០
២. អនុសាសន៍ .................................................................................................................. ៦១
ឯកសារយោង
ឧបសម្ព័ន្ធ

# បញ្ជីអក្សរកាត់

- ក.ស.ហ.វ ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ.ម.ក ៖ គណៈកម្មការមូលបត្រកម្ពុជា
- អ.គ.ហ.ស ៖ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- អកសហវ ៖ អគ្គលេខាធិការដ្ឋាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- មសហវ ៖ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក.វ.ស ៖ ការរៀបចំកម្មវិធីវិនិយោគសាធារណៈ៣ ឆ្នាំរំកិល
- ផ.យ.អ.ជ ៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
- ក.ថ.ក ៖ ក្រុមការងារថវិកាកម្រិតថ្នាក់ដឹកនាំ
- ក.ថ.អ ៖ ក្រុមការងារថវិកាកម្រិតថ្នាក់ដឹកនាំអង្គភាព
- ក.ថ.ប ៖ ក្រុមការងារថវិកាកម្រិតថ្នាក់បច្ចេកទេស
- ក.ថ.ផ ៖ ក្រុមការងារថវិកាកម្រិតថ្នាក់អង្គភាពថវិកា
- FMIS : Financial Management System Information System

# បញ្ជីតារាង

តារាងទី១ ៖ រចនាសម្ព័ន្ធសៀវភៅយុទ្ធសាស្ត្រថវិកា....................១២
តារាងទី២ ៖ ពាក្យបច្ចេកទេសក្នុងកិច្ចលទ្ធកម្ម....................២១
តារាងទី៣ ៖ កិច្ចដំណើរការស្នើសុំគោលការណ៍ធានាចំណាយ....................២៥
តារាងទី៤ ៖ កិច្ចដំណើរការអនុវត្តរបស់ភ្នាក់ងារបើកផ្តល់....................៣១
តារាងទី៥ ៖ រចនាសម្ព័ន្ធគោលបំណងគោលនយោបាយនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ... ៤៧

# បញ្ជីឧបសម្ព័ន្ធ


ក្រាហ្វិកទី១ ៖ គម្រោងចំណូលថវិការបស់ក.ស.ហ.វឆ្នាំ២០១៥-២០១៨...............................៥២

ក្រាហ្វិកទី២ ៖ គម្រោងចំណាយថវិការបស់ក.ស.ហ.វឆ្នាំ២០១៥-២០១៨ .............................៥៣

ក្រាហ្វិកទី៣ ៖ របាយការណ៍ចំណាយថវិកា ប្រចាំឆ្នាំ២០១៦របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមមាតិកាកម្មវិធី....................................................................៥៤

ក្រាហ្វិកទី៣ ៖ របាយនៃការបោះផ្សាយអាណត្តិបើកប្រាក់ ឆ្នាំ២០១៦...................................៥៥

ក្រាហ្វិកទី៤ ៖ ការធ្វើចលនាឥណទានប្រចាំឆ្នាំ២០១៦ .......................................................៥៦

ក្រាហ្វិកទី៦ ៖ លម្អិតលទ្ធផលនៃការអនុវចំណាយ នៅតាមអង្គភាពថវិកាថ្នាក់មូលដ្ឋាន........ ៥៧

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ដោយសារតែការមើលឃើញ នូវការអភិវឌ្ឍប្រទេសឆ្ពោះទៅរកភាពរីកចម្រើនក្នុងប្រទេសកម្ពុជាស្របជាមួយនឹងច្បាប់នៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកំពុងមានកង្វះខាត ជាមួយគ្នានេះផងដែរនៅក្នុងឆ្នាំ ២០០៤ [1] រាជរដ្ឋាភិបាលប្រទេសកម្ពុជាបានចាប់ផ្តើមអនុវត្តកម្មវិធីកែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលមានបួនដំណាក់កាលហើយដំណាក់កាលទាំងបួននេះ គឺសំដៅធ្វើការផ្លាស់ប្តូរជាបណ្តើរៗ ពីប្រព័ន្ធគ្រប់គ្រងថវិកាដែលផ្អែកលើធាតុចូល និងមជ្ឈការឆ្ពោះទៅកាន់ប្រព័ន្ធថវិកាដែលផ្អែកលើសមិទ្ធកម្ម និងវិមជ្ឈការវិញ ហើយការអនុវត្តថវិកាកម្មវិធីនេះគឺស្ថិតនៅក្នុងដំណាក់កាលទី៣ នៃកំណែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ គឺការផ្សារភ្ជាប់រវាងថវិកាទៅនឹងគោលនយោបាយ ហើយចំណុចដែលជាគន្លឹះ ក្នុងដំណាក់កាលនេះគឺឈានទៅកែលម្អគុណភាពនៃវដ្តថវិកា (ការរៀបចំ ការអនុម័តថវិកា ការអនុវត្តថវិកានិង ការត្រួតពិនិត្យតាមដាននិងវាយតម្លៃលទ្ធផល) នៅលើមាគ៌ានៃកំណែទម្រង់នេះ គោលដៅសំខាន់បំផុតមួយគឺការធ្វើឱ្យ **ប្រព័ន្ធថវិកា** កាន់តែក្លាយទៅជាឧបករណ៍គោលនយោបាយពិតប្រាកដក្នុង ការវិភាជន៍និងប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងភាពសក្តិសិទ្ធិ ក្នុងការឆ្លើយតបទៅ នឹងសេចក្តីត្រូវការ សំណូមពរ និងបំណងប្រាថ្នារបស់ប្រជាជន ។ ថវិកាកម្មវិធីត្រូវបានអនុវត្តសាកល្បងចាប់ពីឆ្នាំ ២០០៧មកដើម្បីដកស្រង់បទពិសោធន៍ពីការរៀបចំ ការអនុវត្ត និងការត្រួតពិនិត្យ ថវិកាដែលមានក្រសួងចំនួន ៨ ដែលជាអ្នកអនុវត្តថវិកាកម្មវិធីសាកល្បងក្នុងនោះមាន ៖ ក្រសួងអប់រំ យុវជន និងកីឡា ,ក្រសួងសុខាភិបាល ,ក្រសួងកសិកម្ម រុក្ខាប្រមាញ់និង នេសាទ, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងកិច្ចការនារី, ក្រសួងយុត្តិធម៌,ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។ ស្របពេលនឹងការពង្រីកវិសាលភាពនៃការអនុវត្តថវិកាកម្មវិធី នៅក្នុងឆ្នាំ២០១៥ រដ្ឋាភិបាលបានបញ្ចូលក្រសួងចំនួនពីរទៀត ដើម្បីអនុវត្តថវិកាកម្មវិធីនេះគឺក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូន ។

ទន្ទឹមនឹងនេះផងដែរ អង្គភាពថវិកាត្រូវបានបង្កើតឡើងដើម្បីធានាបាននូវភាពជាម្ចាស់កម្មវិធី ដោយផ្សារភ្ជាប់រវាងធនធានទៅនិងការទទួលខុសត្រូវចំពោះការអនុវត្ត និងសមិទ្ធកម្ម ។ ក្នុងគោលដៅនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញជាគោលការណ៍ណែនាំ ការរៀបចំ ការអនុម័ត ការអនុវត្ត និងការតាមដានវាយតម្លៃ ដើម្បីឱ្យការអនុវត្តថវិកាកម្មវិធីនៅតាមអង្គភាពដែលស្ថិត

[1] រាជរដ្ឋាភិបាលកម្ពុជា, ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨

ក្រោមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចអនុវត្ត និងការបែងចែកថវិកាប្រើប្រាស់អោយចំគោលដៅ និងប្រកបដោយភាពសន្សំសំចៃ ។

ដោយសម្លឹងឃើញពីប្រសិទ្ធភាព នៃការអនុវត្តថវិកាកម្មវិធីរបស់ក្រសួងនីមួយៗ ជាពិសេសគឺក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគឺពិតជាផ្តល់នូវសារៈសំខាន់ខ្ពស់ក្នុងការតាមដាននូវចំណាយ របស់ស្ថាប័នរដ្ឋ ដើម្បីអនុវត្តថវិការបស់អង្គភាពខ្លួន ដោយមានមុខចំណាយត្រឹមត្រូវ និងអនុវត្តចំគោលដៅឬមិនចំគោលដៅ ។ អត្ថបទនេះស្រាវជ្រាវឡើងគឺសិក្សាស៊ីជម្រៅទៅលើស្ថានភាពនៃការរួមចំណែកក្នុងការតាមដានការអនុវត្តថវិការបស់ក្រសួង ស្ថាប័ន មន្ទីរជំនាញនីមួយៗ ថាតើដំណើរការនៃការអនុវត្តថវិការបស់ក្រសួង ឬស្ថាប័នរដ្ឋចាប់ផ្តើមពី ដំណាក់កាលណាទៅដំណាក់កាលណា ស្ថាប័ន នីមួយៗ ប្រើប្រាស់ថវិការបស់ខ្លួនចំគោលដៅយ៉ាងដូចម្តេច ហើយមុខចំណាយនីមួយៗចំណាយចំគោលដៅឬទេ ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ការរៀបចំការចំណាយរបស់ក្រសួង ឬស្ថាប័នរដ្ឋនីមួយៗជាកត្តាដែលគួរយកចិត្តទុកដាក់ និងសំខាន់បំផុតសម្រាប់ក្រសួង ឬស្ថាប័ននោះ ហើយការចំណាយនីមួយៗ តម្រូវឱ្យមានការកំណត់ឱ្យបានច្បាស់លាស់ ជៀសវាងការចំណាយដែលមិនចំនិងគោលដៅ ហេតុដូច្នោះហើយបានជារដ្ឋាភិបាលប្រទេសកម្ពុជាបានធ្វើការកំណែទម្រង់ថ្មីទៅលើ ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈគោលដៅរៀបចំប្រព័ន្ធថវិកាដើម្បីចំណាយឱ្យមានប្រសិទ្ធភាព ភាពសិក្តិសិទ្ធ ។

- តើអ្វីជាកម្មវិធីកំណែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មី ?
- តើការអនុវត្តថវិកាកម្មវិធីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានដំណើរការយ៉ាងដូចម្តេច?
- តើក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានវិធីសាស្ត្របែបណាក្នុងការត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តថវិកាកម្មវិធី?

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

តាមរយៈការសិក្សាទៅលើប្រធានបទ "ការអនុវត្តថវិកាកម្មវិធីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ" គោលបំណងដែលក្រុមយើងខ្ញុំធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះគឺដើម្បីសិក្សាស្វែងយល់ និងបកស្រាយទៅលើចំនុចមួយចំនួនដូចខាងក្រោម ៖

- កំណត់ទ្រឹស្តីមួយចំនួនទាក់ទងទៅនឹងការធ្វើថវិកាកម្មវិធី
- កត្តាផ្សេងៗដែលចូលរួមក្នុងការកាត់បន្ថយចំណាយមិនចាំបាច់របស់ស្ថាប័នរដ្ឋមួយចំនួន
- ស្ថានភាពទូទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- រៀបចំយុទ្ធសាស្ត្រ និងការព្យាករណ៍ក្នុងការចំណាយផ្សេងៗនៅពេលអនាគត
- ប្រតិបត្តិការចំណាយ ឬតួនាទី និងការបែងចែកក្រុមការងារអនុវត្ត
- វិភាគលើកការអនុវត្តថវិកាកម្មវិធី របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ៤.សារៈសំខាន់នៃការស្រាវជ្រាវ

ដោយសារតែមើលឃើញពីចំណុចមួយចំនួន ពាក់ព័ន្ធទៅនិងការចំណាយរបស់រដ្ឋាភិបាលសម្រាប់ការចំនាយតាមរយៈកញ្ចប់ថវិកាសម្រាប់កម្មវិធីនីមួយៗ មានប្រសិទ្ធភាព និងមានសមិទ្ធកម្មច្បាស់លាស់ ។ ជាការពិតណាស់ ការចំណាយរបស់ក្រសួង ឬស្ថាប័នរដ្ឋ និងការចំណាយមានគោលការណ៍ ការរៀបចំ និងមានការតាមដានវាយតម្លៃមានភាពត្រឹមត្រូវជាកត្តាសំខាន់បំផុត ដើម្បីឱ្យអង្គភាពនោះមានដំនើរការល្អ និងសម្រេចគោលដៅច្បាស់លាស់ ។ យោងតាមការរៀបរាប់ខាងលើនេះ ហើយទើបបានជាយើងខ្ញុំចងក្រងឯកសារនេះឡើងដែលអាចជាគុណប្រយោជន៍សម្រាប់ ៖

- ការសិក្សាស្វែងយល់អំពីការកែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដើម្បីដំណើរការនៃការអនុវត្តចំណាយរបស់រដ្ឋាភិបាលបានត្រឹមត្រូវ និងចំគោលដៅ ។
- ការចូលរួមស្វែងយល់អំពីការគ្រោង ការរៀបចំកញ្ចប់ថវិកាទុកជាមុន សម្រាប់ពេលអនាគត
- ការអនុវត្តប្រព័ន្ធថវិកាដែលមានលក្ខណៈត្រឹមត្រូវ មានការតាមដាន វាយតម្លៃអំពីសកម្មភាពក៏ដូចជាលទ្ធផលសម្រេចបានច្បាស់លាស់ និងប្រាកដប្រជា ។
- ការផ្តល់ជាមតិយោបល់ និងដំណោះស្រាយពាក់ព័ន្ធនិងការអនុវត្តថវិកាកម្មវិធី ។

## ៥. ទំហំនិងដែនកំណត់នៃការសិក្សាស្រាវជ្រាវ

កិច្ចការស្រាវជ្រាវនេះ គឺផ្តោតសំខាន់ទៅលើតែការអនុវត្តថវិកាកម្មវិធីរបស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុតែមួយគត់ ដោយមិនបានរាប់បញ្ចូលទៅនិងការអនុវត្តរបស់ក្រសួងឬស្ថាប័ន រដ្ឋដទៃទៀតឡើយ ហើយរបាយការណ៍ស្រាវជ្រាវនេះ គឺពតិមានបង្ហាញអំពីគោលការណ៍នៃការរៀបចំកញ្ចប់ថវិកា ការអនុវត្ត និងពត៌មានបង្ហាញពីការអនុវត្តថវិកាកម្មវិធីដែលមាន ការតាមដានវាយតម្លៃនូវរបាយការណ៍ដែលបានអនុវត្តរួចជាស្រេច ។ ឯកសារនេះគ្រាន់តែជាផ្នែក មួយដែលបង្ហាញពីការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា តាមរយៈការរៀបចំ ការកំណត់ផែនការយុទ្ធសាស្ត្រ ការព្យាករណ៍ចំណាយនៅពេលខាងមុខ របស់រដ្ឋាភិបាលកម្ពុជាតាមរយៈស្ថាប័នរដ្ឋគឺក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជៀសវាងការចំណាយមិនចាំបាច់ និងខ្ជះខ្ជាយ ។ លើសពីនេះទៅទៀត វាក៏អាចជាជំនួយសម្រាប់ការយល់ដឹង និងការពិចារណាអំពីការចំណាយរបស់បុគ្គលផ្ទាល់ ស្ថាប័នរដ្ឋ ឬ ស្ថាប័នឯកជន ក្នុងការ

ចំណាយដែលមានផែនការគ្រោងទុកជាមុន ដើម្បីងាយស្រួលក្នុងការចំនាយបានត្រឹមត្រូវចំគោលដៅ និងមានប្រសិទ្ធភាព ។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

ដើម្បីចងក្រងប្រមូលទិន្នន័យ និងពត៌មានផ្សេងៗយកមកប្រើប្រាស់នៅក្នុងរបាយការណ៍ស្រាវជ្រាវនេះឡើង មានតម្រូវការទិន្នន័យតាមបែបបរិមាណវិស័យ និងទិន្នន័យបន្ទាបបន្សំ ៖

- ទិន្នន័យបន្ទាប់បន្សំ (Secondary Data) ៖ ទិន្នន័យដែលប្រើសម្រាប់វិភាគនៅក្នុងអត្ថបទស្រាវជ្រាវនេះគឺបានមកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងដំណាក់កាល ការអនុវត្តថវិកាកម្មវិធីក្នុងឆ្នាំ ២០១៥-២០១៦ ដើម្បីបកស្រាយលទ្ធផលនេះត្រូវពិនិត្យលើ ៖
    - គម្រោងចំណូល-ចំណាយថវិការយៈពេលមធ្យម (៣ឆ្នាំរំកិល) របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០១៦-២០១៨ មកធ្វើការប្រៀបធៀបនឹងឥណទានឆ្នាំ២០១៥
    - ធ្វើការបកស្រាយលើទិដ្ឋភាពចំណាយតាមមាតិការកម្មវិធីប្រចាំឆ្នាំ ២០១៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធៀបនឹងឥណទានថ្មី។ សូមបញ្ជាក់ថាឥណទានថ្មី គឺជាឥណទានចុងឆ្នាំ ដែលឆ្លងកាត់ការនិយ័តចេញ និងចូលក្នុងឆ្នាំអនុវត្ត ។
    - វិភាគអំពីរបាយនៃការបោះផ្សាយអាណត្តិបើកប្រាក់/អាណត្តិនិយ័តកម្ម ទូទាត់ចំណាយតាមខែ
    - ធ្វើវិភាគលើចលនាឥណទាន របស់អង្គភាពថវិកាថ្នាក់កណ្តាល ប្រចាំឆ្នាំ២០១៦

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

របាយការណ៍ក្រោមប្រធានបទ "ការអនុវត្តថវិកាកម្មវិធីរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ" ត្រូវបានចែកចេញជាបួនជំពូកធំៗដូចជា **ជំពូកទី១ ទស្សនៈផ្សេងៗទាក់ទងនឹងទ្រឹស្តីការរៀបចំផែនការថវិកាក្នុងការអនុវត្តថវិកាកម្មវិធី៖** ផ្នែកនេះបានផ្តល់នូវទ្រឹស្តីផ្សេងៗពាក់ព័ន្ធនិងទ្រឹស្តីផ្សេងៗពាក់ព័ន្ធនិងការរៀបចំផែនការថវិកាកម្មវិធី និងគោលការណ៍ណែនាំស្តីពីការអនុវត្តថវិកាកម្មវិធី ព្រមទាំងដំណើរការនៃការគ្រោងថវិកាប្រចាំឆ្នាំ ។ **ជំពូកទី២ ស្ថានភាពទូទៅនៃក្រសួងសេដ្ឋកិច្ច និងការទទួលខុសត្រូវនៅក្នុងកិច្ចដំណើរការនៃការអនុវត្ត** ៖ នៅក្នុងផ្នែកនេះ យើងនឹងនិយាយអំពីស្ថានភាពទូទៅរចនាសម្ព័ន្ធគ្រប់គ្រង និងសិទ្ធអំណាចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ **ជំពូកទី ៣ ៖ ការអនុវត្តថវិកាកម្មវិធីនិងការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ ៖** ក្នុងផ្នែកនេះយើងនិងធ្វើការបកស្រាយ

ពិពណ៌នា ព្រមទាំងធ្វើការវិភាគពន្យល់អំពីទិន្នន័យដែលយើងប្រមូលបានពីតាមស្ថាប័ន និងឯកសារពាក់ព័ន្ធមួយចំនួន ហើយធ្វើការបកស្រាយ ពត៌មានដែល ទទួលបាននិងបង្ហាញពីបញ្ហាប្រឈមដែលកើតមានឡើងក្នុងពេលអនុវត្តថវិកាកម្មវិធីនៅក្នុងពេលអនុវត្តជាក់ស្តែង និងនាពេលអនាគត ។ និងធ្វើការវិភាគពីចំណុចខ្លាំង និងចំណុចខ្សោយនៃការអនុវត្តនេះតែម្តង។

# ជំពូកទី១

# ទ្រឹស្តីជាមូលដ្ឋាន នៃ

# ថវិកាកម្មវិធី

# ជំពូកទី១
# ទ្រឹស្តីជាមូលដ្ឋាននៃថវិកាកម្មវិធី

## ១.១ និដ្ឋភាពទូទៅរបស់ថវិកា

រាល់ថវិកា ជាការគ្រោងនៃសកម្មភាពទាំងបុគ្គល ទាំងសហគ្រាស ទាំងសមូហភាពសាធារណៈ និងរដ្ឋដែលយើងហៅថា ភ្នាក់ងារសេដ្ឋកិច្ច ។ ទាំងអស់គ្នានេះសុទ្ធតែបង្កើតឡើង នូវកម្មវិធីហិរញ្ញវត្ថុក្រោមរូបភាពជាការគ្រោងទុកសម្រាប់ ចំណូល និង ចំណាយរបស់ខ្លួន។

គ្រប់ភ្នាក់ងារសេដ្ឋកិច្ចទាំងអស់ ការគ្រប់គ្រងប្រាក់ចំណូលដែលគេរកបានសុទ្ធតែត្រូវ គិតគូរយ៉ាងម៉ត់ចត់ ដោយចាត់ចែងប្រាក់ចំណូលទាំងនោះយ៉ាងប្រុងប្រយ័ត្នក្នុងគោលបំណង ធ្វើអោយមានអត្ថិភាពជានិរន្តរ៍។ យើងក៏សូមលើកយក ភ្នាក់ងារសេដ្ឋកិច្ចមួយដែលមានរូបវ័ន្ត បុគ្គលមកធ្វើការបញ្ជាក់ ដែលក្នុងគ្រួសារមួយមានបុរសជាស្វាមី ជាអ្នកគ្រប់គ្រង មានប្រពន្ធនិងកូននៅក្នុងបន្ទុក ដូចនេះបុគ្គលរូបនេះនឹងធ្វើការគ្រប់គ្រងចំណូលរបស់គាត់ដោយគិតគូរ ពីសេដ្ឋកិច្ចរបស់គាត់ និង សេចក្តីត្រូវការរបស់គាត់ ដោយគាត់គិតគូរទៅតាមប្រាក់ ចំណូលរបស់គាត់ដែលរកបាន។ ប្រការដែលសំខាន់នោះ គាត់ប្រាកដជាត្រូវជ្រើសរើសយក សេចក្តីត្រូវការជាបឋម និងចាំបាច់ជាមុនសិន មុននឹងគិតទៅដល់សេចក្តីត្រូវការ បន្ទាប់បន្សំ មានដូចជា ការហូបចុក ការស្លៀកពាក់ដែលជំនួសអោយការប្រើប្រាស់របស់របរទំនើប និង មានការចំណាយឥតប្រយោជន៍ ។

ប៉ុន្តែបើនិយាយដល់រដ្ឋ ដែលជានីតិបុគ្គលវិញ មិនដូចជារូបវ័ន្តបុគ្គលទេ ពោលគឺរដ្ឋមានតួនាទីសំខាន់ក្នុងការអនុវត្តបេសកម្មដ៏សន្ធឹកសន្ធាប់ និងស្មុគស្មាញទៅលើគ្រប់វិស័យ ដើម្បីធានាឱ្យផ្នែកសាធារណៈទាំងអស់ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់សមស្រប និង មានប្រសិទ្ធិភាព ។ ដូចនេះរាជរដ្ឋាភិបាលត្រូវដាក់ចេញនូវគោលនយោបាយ ផ្នែកថវិការបស់ខ្លួន ដោយខិតខំប្រមែប្រមូលចំណូលពីក្នុងស្រុក និងក្រៅស្រុក ដើម្បីឱ្យរដ្ឋមានថវិកា គ្រប់គ្រាន់ សម្រាប់ផ្គត់ផ្គង់ តាមរបៀបវិទ្យាសាស្ត្រដល់សេវាសាធារណៈ ជូនដល់មន្ត្រីរាជការទាំងអស់អាចដំណើរការជាប្រក្រតីគ្រប់ផ្នែក ។

ដើម្បីអនុវត្តបេសកកម្មទាំងនេះឱ្យមានប្រសិទ្ធិភាព រាជរដ្ឋាភិបាលត្រូវតែមានធនធាន គ្រប់គ្រាន់ ដែលធនធានទាំងនោះអាចជាធនធានមនុស្ស និងធនធានសម្ភារៈបរិក្ខារ ឧបករណ៍ជាដើម ដើម្បីធ្វើដំណើរការប្រកបដោយនិរន្តរភាព។ ដូចនេះវាជាការចាំបាច់ ដែលរាជរដ្ឋាភិបាល ត្រូវតែរៀបចំថវិកា ជាពិសេសក្នុងផ្នែកចំណាយឱ្យបានគ្រប់គ្រាន់ សម្រាប់ឆ្នាំដែលមកដល់ និង ដាក់ជូនរដ្ឋសភាអនុម័តដោយបែងចែកច្បាស់លាស់នូវថវិកាតាមក្រសួងស្ថាប័ននីមួយៗ នឹងធ្វើឱ្យបានលម្អិតទៅ

តាមប្រភេទ ជំពូក កថាខ័ណ្ឌ វាក្យខ័ណ្ឌ និង ដល់គ្រប់ផ្នែកសាធារណៈ រដ្ឋបាលដែលក្រសួង ឬស្ថាប័ននីមួយៗគ្រប់គ្រង ។

គ្រប់ប្រទេសលើលោកទោះជាប្រទេសអភិវឌ្ឍន៍ ឬប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីធានាបាននូវអត្ថិភាពរបស់រដ្ឋ គេខិតខំបញ្ចេញកម្លាំងកាយចិត្ត ដើម្បីរៀបចំថវិកាជាតិដាក់ជូនរដ្ឋ សភាអនុម័តដើម្បីយកទៅអនុវត្តនូវបេសកម្មរបស់ខ្លួន និងម្យ៉ាងទៀតគេអាចនិយាយបានថាថវិការដ្ឋគឺមានលក្ខណៈពិសេសរបស់វា ។

**១.១.២ និយមន័យថវិកាកម្មវិធី**[2]

ថវិកាកម្មវិធីសំដៅទៅលើថវិកា ដែលបែងចែកជាអនុកម្មវិធី ឬក្រុមចង្កោមសកម្មភាពដែលមានលក្ខណៈឯករាជ្យតែមានទំនាក់ទំនងគ្នាយ៉ាងជិតស្និត ហើយត្រូវបានរៀបចំឡើង ដើម្បីរួមចំណែកសម្រេចបាននូវគោលបំណងគោលនយោបាយរួមមួយ និងមានបញ្ជាក់ពីសកម្មភាព ដែលត្រូវអនុវត្តលទ្ធផលក្នុងឆ្នាំ លទ្ធផលចុងក្រោយ ព្រមទាំងសូចនាករដែលជាមូលដ្ឋានសម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលដែលសម្រេចបានពីការអនុវត្តថវិកាកម្មវិធី។

## **១.២ការរៀបចំកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល (ក.វ.ស)**

**១.២.១និយមន័យ**

ជាផែនការថវិការយៈពេលមធ្យម (៣ឆ្នាំរំកិល) តាមអភិក្រមពីក្រោមឡើងលើ(Bottom-up Approach) ដើម្បីធានាថាគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលត្រូវបានផ្សារភ្ជាប់ទៅនឹងថវិកាតាមរយៈការកំណត់ឲ្យច្បាស់លាស់នូវៈ

- គោលបំណងគោលនយោបាយរបស់ក្រសួងស្ថាប័ន
- កម្មវិធីឬយុទ្ធសាស្ត្រអាទិភាព
- សូចនាករនិងគោលដៅសូចនាករ
- ធនធានចរន្តនិងធនធានមូលធនទាំងថវិការដ្ឋទាំងថវិកាដៃគូអភិវឌ្ឍន៍

**១.២.២គោលបំណងនៃការរៀបចំកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល**

ការរៀបចំកម្មវិធីវិនិយោគសាធារណៈ (ក.វ.ស) ៣ឆ្នាំរំកិលមានគោលបំណងសំខាន់ដូចខាងក្រោមៈ

[2] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, សៀវភៅគោលការណ៍ណែនាំស្តីពី នីតិវិធីនៃអនុវត្តថវិកាកម្មវិធី

- បង្ហាញពីទិន្នន័យគម្រោងវិនិយោគមានអាទិភាពខ្ពស់ទាំងអស់របស់បណ្តាក្រសួង-ស្ថាប័នដែលជាគោលនយោបាយមានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណ
- ជាផែនទីចង្អុលផ្លូវសម្រាប់ការអនុវត្តគោលនយោបាយមានចែងក្នុងផែនការយុទ្ធ-សាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.)
- ប្រើប្រាស់ជាធាតុចូលក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា។

ក.វ.ស៣ឆ្នាំរំកិលត្រូវបានរៀបចំឡើងដោយដាក់បញ្ចូលគ្នារវាងៈគម្រោងកំពុងដំណើរការ (គម្រោងកំពុងបន្តក្នុងដំណាក់កាលក.វ.សក្នុងក្រមខណ្ឌហិរញ្ញប្បទានសហប្រតិបត្តិការដែលបានផ្តល់ដោយគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានិងពិនិត្យកែសម្រួលដោយក្រសួង-ស្ថាប័នអនុវត្តគម្រោងរបស់រាជរដ្ឋាភិបាល) និងគម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. (គម្រោងស្នើសុំថ្មីដែលត្រូវអនុវត្តក្នុងដំណាក់កាលក.វ.ស.) ។

## **១.២.៣ វិធាននៃការរៀបចំកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល** (ក.វ.ស.)

### **១.២.៣.១ការរៀបចំក.វ.ស. ៣ឆ្នាំរំកិលរបស់រាជរដ្ឋាភិបាល**

នៅក្នុងឆ្នាំថវិកានីមួយៗ គ្រប់ក្រសួង-ស្ថាប័នត្រូវរៀបចំសំណើតម្រូវការចំណាយវិនិយោគ-សាធារណៈដោយផ្អែកលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ក្នុងទម្រង់ជា "កម្មវិធី- វិនិយោគសាធារណៈ៣ឆ្នាំរំកិល" ដែលសរសេរកាត់ថា "ក.វ.ស." ដើម្បីស្នើសុំការពិនិត្យនិងអនុម័តពីរាជរដ្ឋាភិបាល។

ដោយហេតុថាការរៀបចំក.វ.ស៣ឆ្នាំរំកិលជាផ្នែកមួយយ៉ាងសំខាន់នៃដំណើរការសុខដុមនីយកម្មការងារផែនការចំណាយវិនិយោគសាធារណៈរបស់រដ្ឋនិងហិរញ្ញប្បទានសហប្រត្តិបត្តិការអន្តរជាតិ។ហេតុដូចនេះក្នុងនាមជាអ្នករៀបចំក.វ.ស. ៣ឆ្នាំរំកិលក្រសួងផែនការបានជំរុញកិច្ច-សហប្រត្តិបត្តិការយ៉ាងជិតស្និទ្ធជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍនកម្ពុជាក្នុងនោះវិធីសាស្ត្រដែលក្រសួងផែនការប្រើប្រាស់ដើម្បីធ្វើការវិភាជថវិកាសម្រាប់ក.វ.ស. ៣ឆ្នាំរំកិលមានមូលដ្ឋានៃលក្ខណវិនិច្ឆ័យដូចខាងក្រោមៈ

- ការវិភាជសរុបដល់វិស័យដែលមានចែងច្បាស់លាស់នៅក្នុងផ.យ.អ.ជ. សម្រាប់គម្រោងកំពុងដំណើរការនិងគម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. ប្រកបដោយសង្គតិភាព។

- អាទិភាពនៃការវិភាជថវិកាដល់បណ្តាគម្រោងកំពុងដំណើរការដើម្បីបន្តការអនុវត្ត និង/ឬបញ្ចប់ការអនុវត្ត។
- ថវិកាដែលនៅសល់ត្រូវវិភាជលើគម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. ផ្សេងទៀត ដោយផ្អែកលើ៖
  - អាទិភាពនៃគម្រោងដែលកំណត់ដោយក្រសួង-ស្ថាប័នសាមី
  - គម្រោងសម្រាប់អនុវត្តយុទ្ធសាស្ត្រតាមវិស័យរបស់ក្រសួង-ស្ថាប័នដើម្បីអនុវត្តគោលនយោបាយអាទិភាពនៃយុទ្ធសាស្ត្រចតុកោណនិងផ.យ.អ.ជ.
  - ព័ត៌មានដែលក្រសួង-ស្ថាប័នបានផ្ញើមកក្រសួងផែនការស្តីពីស្ថានភាពសក្តានុពលក្នុងការសន្យាផ្តល់ហិរញ្ញប្បទានដល់គម្រោងសម្រាប់អនុវត្ត ផ.យ.អ.ជ.
  - កិច្ចពិភាក្សាជាមួយកសហវ. ដើម្បីពិនិត្យនិងកែសម្រួលឡើងវិញនូវការសន្យាផ្តល់ថវិកាពីកញ្ចប់ថវិកាជាតិនិងលទ្ធផលនៃកិច្ចពិភាក្សារវាងក្រសួង-ស្ថាប័ននិងកសហវ. ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ស្ថាប័ននិមួយៗ

### ១.៣.៣.២ការរៀបចំក.វ.សពាឆ្នាំរំកិលរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ដើម្បីរួមចំណែកអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានរៀបចំសំណើរគម្រោងវិនិយោគសាធាណ:៣ឆ្នាំរំកិលឆ្នាំ២០១៧-២០១៩ ផ្ញើជូនក្រសួងផែនការពិនិត្យនិងដាក់ឆ្លងក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្រ្តីនាពេលខាងមុខ។

ឆ្លងតាមការណែនាំរបស់ថ្នាក់ដឹកនាំអគ្គលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានសហាការជាមួយអគ្គនាយកដ្ឋានពាក់ព័ន្ធ (អគ្គនាយកដ្ឋានថវិកា, អគ្គនាយកដ្ឋានសហប្រត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុលនិងអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ) និងបណ្តាអង្គភាពថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើការងារដូចខាងក្រោម៖

- ប្រមូលផ្តុំរបាយការណ៍ស្តីពីស្ថានភាពនៃការអនុវត្តគម្រោងដែលទទួលបានការសន្យាផ្តល់ឥណទានក្នុងឆ្នាំ២០១៦
- ពិនិត្យស្ថានភាពនៃការអនុវត្តគម្រោងដែលបានអនុម័តនិងទទួលបានការសន្យាផ្តល់ឥណទានពីរាជរដ្ឋាភិបាលក្នុងឆ្នាំ២០១៧

- បន្តគ្រោងគម្រោងដែលបានអនុម័តក្នុងឆ្នាំ២០១៧ប៉ុន្តែពុំទាន់ទទួលបានការសន្យាផ្តល់ឥណទាននៅឡើយចូលទៅក្នុងគម្រោងវិនិយោគសាធារណៈ៣ឆ្នាំរំកិល ២០១៧-២០១៩
- ពិនិត្យនិងដាក់បញ្ចូលតម្រូវការជាក់ស្តែងរបស់អង្គភាពថវិកាក្នុងការស្នើសុំគម្រោងថ្មីក្នុងរង្វង់ឆ្នាំ២០១៨-២០២០។

រួមសេចក្តីមកគម្រោងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល (ក.វស) ត្រូវបានរៀបចំឡើងដើម្បីរួមចំណែកអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជានិងផែនទីចង្អុលផ្លូវក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

ក្នុងការរួមចំណែកអនុវត្តបទដ្ឋានដូចបានលើកឡើងកម្រងតម្រូវការគម្រោងកម្មវិធីវិនិ-យោគសាធារណៈ៣ឆ្នាំរំកិល២០១៧-២០១៩របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបានរៀបចំឡើងដោយបង្ហាញចេញនូវព័ត៌មាននៃតម្រូវការគម្រោងវិនិយោគដែលអង្គភាពថវិកានៃក្រសួងបានស្នើសុំ។ការចងក្រងតម្រូវការគម្រោងកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល២០១៧-២០១៩លើកនេះមានភាពល្អប្រសើរ។

## ១.៣ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា

### ១.៣.១និយមន័យ

ជាផែនការថវិការយៈពេលមធ្យម (៣ឆ្នាំរំកិល) តាមអភិក្រមពីក្រោមឡើងលើ (Bottom-up Approach) ដើម្បីធានាថាគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលត្រូវបានផ្សារភ្ជាប់ទៅនឹងថវិកាតាមរយៈការកំណត់ឲ្យច្បាស់លាស់នូវះ

- គោលបំណងគោលនយោបាយរបស់ក្រសួងស្ថាប័ន
- កម្មវិធីឬយុទ្ធសាស្ត្រអាទិភាព
- សូចនាករនិងគោលដៅសូចនាករ
- ធនធានចរន្តនិងធនធានមូលធនទាំងថវិការដ្ឋទាំងថវិកាដៃគូអភិវឌ្ឍន៍

### ១.៣.២ សារាចររៀបចំផែនការយុទ្ធសាស្ត្រថវិកាប្រចាំឆ្នាំ

- សារាចរណ៍រៀបចំផែនការថវិកាយុទ្ធសាស្ត្រថវិកាប្រចាំឆ្នាំ ត្រូវបានរៀបចំឡើងក្នុងគោលបំណងជាច្រើនដូចខាងក្រោម ៖

- បង្ហាញអំពីគោលការណ៍នៃការរៀបចំផែនការថវិកា ពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត ព្រមទាំងគោលដៅរបស់រដ្ឋាភិបាល តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានដាក់

ចេញនូវក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់រៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសាធារណៈសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧[3] ដើម្បីឱ្យក្រសួង ស្ថាប័ននីមួយៗ មានមូលដ្ឋានសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រឆ្នាំ ២០១៧-២០១៩ និងការលើកគម្រោងថវិកាប្រចាំឆ្នាំ ២០១៧ ។

- សារាចរណែនាំស្ដីពីការរៀបចំផែនការថវិកា ក៏បានបង្ហាញពីក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច,គោលនយោបាយសាធារណៈ,គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច,ក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ព្រមទាំងគោលការណ៍ផ្សេងៗពាក់ព័ន្ធនិងចំណូល-ចំណាយ ពន្ធគយផងដែរ ។ *(មើលបន្ថែមក្នុងឧបសម្ព័ន្ធទី១)*

### ១.៣.៣អត្ថប្រយោជន៍ នៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា

មានអត្ថប្រយោជន៍ដូចជា៖

- ផ្សារភ្ជាប់ថវិកាទៅនឹងគោលបំណងគោលនយោបាយ
- មូលដ្ឋានសម្រាប់ការរៀបចំយុទ្ធសាស្ត្រអាទិភាព
- មូលដ្ឋាននៃការរៀបចំថវិកាកម្មវិធី
- ធានាបានប្រសិទ្ធភាពនិងភាពស័ក្តសិទ្ធិនៃការប្រើប្រាស់ធនធានសាធារណៈ
- ឧបករណ៍សម្រាប់ធ្វើសមាហរណកម្មថវិការវាងថវិកាចរន្តនិងមូលធន (ទាំងថវិការដ្ឋនិងថវិកាដៃគូអភិវឌ្ឍន៍)

[3]រាជរដ្ឋាភិបាលកម្ពុជា, ច្បាប់ស្ដីពីកំណែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨

## ១.៣.៤រចនាសម្ព័ន្ធសៀវភៅផែនការយុទ្ធសាស្ត្រថវិកា

**សេចក្តីផ្តើម**

- រំលេចអំពីបេសសកម្ម និងភារកិច្ចចម្បងៗសម្រាប់ឆ្នាំ ២០១៧- ២០១៩ ក្នុងក្របខណ្ឌនៃតួនាទី និងភារកិច្ចរបស់ក្រសួង ស្ថាប័ន
- បរិយាយអំពីលទ្ធផលសម្រេចបានក្នុងឆ្នាំ ២០១៥ (ធៀបសូចនាករដែលបានកំណត់)
- លើកអំពីបញ្ហាប្រឈម (ដែលត្រូវយកចិត្តទុកដាក់ក្នុងឆ្នាំ ២០១៦ និងឆ្នាំខាងមុខ)
- លើកអំពីវិធានការគោលការគោលនយោបាយ សម្រាប់រួមចំណែកអនុវត្តយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៣- ២០១៧ រួមបញ្ចូលទាំងវិធាន ការគោលនយោបាយដែលមានចរិតតាមវិស័យ និងអន្តរវិស័យសម្រាប់ឆ្នាំ ២០១៧- ២០១៩

↓

គោលបំណងគោលនយោបាយ

បម្រើឱ្យគោលនយោបាយយុទ្ធសាស្ត្រណាមួយនិងវិធានការគោលនយោបាយអ្វីខ្លះនៃយុទ្ធសាស្ត្រចតុកោណ

ស្ថិតនៅក្នុងវិស័យណាមួយនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

- ដើម្បីរួមចំណែកអនុវត្តគោលនយោបាយតាមវិស័យ ពិសេស គោលនយោបាយរួមរបស់រដ្ឋាភិបាលដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពសំដៅសម្រេចឱ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ ក្រសួង ស្ថាប័ន

↓

ការរៀបចំកម្មវិធី

ដើម្បីអនុវត្តគោលបំណងគោលនយោបាយខាងលើឱ្យទទួលបានជោគជ័យ ក្រសួងស្ថាប័ន បានរៀបចំកម្មវិធីមួយចំនួន (មិនលើសពី ៥)ដូចខាងក្រោម ៖

១..................................

គោលបំណងនៃកម្មវិធី ៖ ...........

២..................................

គោលបំនងនៃកម្មវិធី ៖ ..............

៣..................................

គោលបំនងនៃកម្មវិធី ៖...............

*តារាងទី១៖ រចនាសម្ព័ន្ធសៀវភៅផែនការយុទ្ធសាស្ត្រថវិកា*

### ក. ការកំនត់ធនធាន

### ការគ្រោងចំណូល

ដើម្បីរួមចំណែកក្នុងការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម (២០១៣-២០១៧) របស់រាជរដ្ឋាភិបាល និងដើម្បីចូលរួមសម្រេចឱ្យបានគោលដៅសូចនាករចំណូល ដែលបានកំនត់ក្នុងក្របខណ្ឌហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០១៧-២០១៨ ក្រសួង ស្ថាប័ន បានដាក់ចេញនូវវិធានការមួយចំនួន ដើម្បីពង្រឹងការប្រមូលចំណូលដូចខាងក្រោម ៖

### ខ. ការកំណត់តម្រូវការចំណាយ

**(១) សម្រាប់ចំណាយចរន្ត** ៖ ជាគោលការណ៍កំណត់តម្រូវការចំណាយត្រូវគិតគូរលើទិដ្ឋភាពបី៖

- ✓ គោលនយោបាយ និងសកម្មភាពការងារដែលត្រូវបន្តអនុវត្ត
- ✓ គោលនយោបាយ ឬសកម្មភាពការងារដែលមានលក្ខណៈបញ្ចប់ត្រឹមមួយឆ្នាំ
- ✓ គោលនយោបាយ ឬសកម្មភាពការងារថ្មី

ហេតុនេះរាល់ការកំណត់តម្រូវការចំណាយដែលធំ និងខ្ពស់ជាងគោលការណ៍ដែលចែងក្នុងសារាចរណែនាំស្ដីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ( ផ្នែកការគ្រោងចំណាយ) គឺត្រូវផ្ដល់ការពន្យល់ និងផ្ដល់អំណះអំណាងឱ្យបានត្រឹមត្រូវ ជាក់លាក់ និងច្បាស់លាស់ ។

**(២) សម្រាប់ចំណាយមូលធន**

- ✓ គម្រោងមានហិរញ្ញប្បទានសំដៅដល់គម្រោងដំណើរការ និងគម្រោងដែលបានចុះកិច្ចសន្យារួច
- ✓ គម្រោងមិនទាន់មានហិរញ្ញប្បទានសំដៅដល់គម្រោងកំពុងចរចា និងគម្រោងកំពុងស្វែងរក ហិរញ្ញប្បទាន ។

## ១.៣.៥ប្រតិទិននៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា

មាត្រា៣៩នៃច្បាប់ស្តីពីហិរញ្ញវត្ថុសាធារណៈដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ចុះថ្ងៃទី១៣ខែឧសភាឆ្នាំ២០០៨ ។ បានកំណត់នូវប្រតិទិនសម្រាប់ការរៀបចំថវិកា (រៀបចំសេចក្ដីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ) ជា០៣ដំណាក់កាល៖

- ដំណាក់កាលទី១៖ រៀបចំផែនការយុទ្ធសាស្ត្រថវិកា ពីខែមីនា ដល់ខែឧសភា
- ដំណាក់កាលទី២៖ ការរៀបចំកញ្ចប់ថវិកា ពីខែមិថុនា ដល់ខែកញ្ញា
- ដំណាក់កាលទី៣៖ ការអនុម័តថវិកា ពីខែតុលា ដល់ខែធ្នូ

## ១.៤ការគ្រោងកញ្ចប់ថវិកាប្រចាំឆ្នាំ

### ១.៤.១ គម្រោងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ជាទូទៅ គោលការណ៍ចំណាយរបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តមិនអាចស្នើសុំបន្ថែមឥណទានបានទេ គឺត្រូវអនុវត្តចំណាយក្នុងកម្រិតអតិបរមានៃឥណទានថវិកាដែលបានអនុម័ត និងបែងចែកជូននៅក្នុងសៀវភៅថវិកា ។ ក្រសួងស្ថាប័ន ត្រូវធ្វើវិចារណកម្មអាទិភាពចំណាយ ព្រមជាមួយនឹងការបង្កើនប្រសិទ្ធភាពក្នុងកម្រិតឥណទានថវិកាដែលមាន ដើម្បីបង្កើនបរិមាណ ឬគុណភាពនៃទំនិញនិងសេវាកម្ម ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងពិនិត្យលើសំណើឥណទានតែក្នុងករណីរាជរដ្ឋាភិបាលសម្រេចនូវគោលនយោបាយថ្មី ដូចជាពាក់ព័ន្ធនឹងបៀវត្ស និងសេចក្ដីសម្រេចផ្សេងៗដែលនាំឱ្យមានតម្រូវការថវិកាដើម្បីអនុវត្តសកម្មភាពថ្មី ហើយក្រសួង ស្ថាប័នពិតជាមិនអាចសន្សំចំណាយក្នុងឆ្នាំនៃការអនុវត្តថវិកាបាន ។

#### ១.៤.១.១ សារាចរណ៍រៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ ២០១៦

ជាទូទៅ មុននឹងសម្រេចកញ្ចប់ថវិកាសម្រាប់ការអនុវត្តប្រចាំឆ្នាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំគម្រោងកញ្ចប់ថវិកាប្រចាំឆ្នាំ ដែលក្នុងនោះមានការពាក់ព័ន្ធនិង :

**ក. ការគ្រោងចំណូល**

ការគ្រោងចំណូល គឺជាការគ្រោងសម្រាប់រយៈពេល ៣ឆ្នាំ ២០១៧- ២០១៩ ដោយរួមទាំងចំណូលថវិការដ្ឋដែលស្ថិតក្រោមការគ្រប់គ្រង និងប្រមូលផ្ទាល់ដោយក្រសួង- ស្ថាប័ន និងចំណូលដែលបានមកពីហិរញ្ញប្បទានសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ និងប្រភពផ្សេងៗទៀត ។នៅក្នុងការគ្រោងចំណូល ក្រសួង- ស្ថាប័នដោយរួមទាំងមន្ទីរជំនាញរាជធានី- ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវផ្ដោតការយកចិត្តទុកដាក់លើចំណុចសំខាន់ៗ ដូចខាងក្រោម ៖

- គោលដៅសូចនាករចំណូលនៃក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលបាន ដាក់ចេញនៅក្នុងសារាចរនេះ
- ការវាយតម្លៃការអនុវត្តការប្រមូលចំណូលក្នុងឆ្នាំកន្លងទៅ និងការប៉ាន់ស្មានការអនុ-វត្តប្រមូល ចំណូលក្នុងឆ្នាំកំពុងអនុវត្ត
- យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៣-២០១៧ តាមរយៈការដាក់ចេញវិធានការដាក់ស្ដែងបន្ថែមទៀតតាមក្រសួង-ស្ថាប័ននីមួយៗ ដើម្បីបង្កើនការប្រមូលចំណូលដែលស្ថិត នៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ។

ក្រសួង-ស្ថាប័នមន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវរៀបចំផ្នែកនេះទៅតាមតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ ។ នៅក្នុងផ្នែកនេះ ប្រសិនបើក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តដែលមិនមានប្រភពចំណូល គឺពុំតម្រូវឱ្យរៀបចំឡើយ ។

ទន្ទឹមនេះក្រសួង-ស្ថាប័ននិងមន្ទីរជំនាញរាជធានី-ខេត្តព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលប្រភពចំណូល គឺត្រូវរៀបចំដាក់ចេញវិធានការជាក់ស្តែងបន្ថែមទៀតតាមក្រសួង-ស្ថាប័ននីមួយៗ សម្រាប់ពង្រឹងការគ្រប់គ្រង និងការប្រមូលចំណូល ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ។ ផ្ទុយទៅវិញ ការគ្រោងចំណូលមិនអស់សក្តានុពលដែលមាន គឺជាកម្មវត្ថុនៃការរឹតត្បិតចំណាយ នៅក្នុងដំណាក់កាលចរចាកញ្ចប់ថវិកាប្រចាំឆ្នាំសម្រាប់ក្រសួង-ស្ថាប័នដែលមានភារកិច្ចប្រមូលចំណូល ។

### ខ. ការគ្រោងចំណាយថវិកា

ការគ្រោងតម្រូវការចំណាយ គឺជាការគណនាចំណាយសម្រាប់រយៈពេល ៣ឆ្នាំ ២០១៧-២០១៩ ទៅតាមកម្មវិធីនីមួយៗ និងទៅតាមប្រភេទចំណាយ និងប្រភពធនធាន រួមទាំងថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍ ។ ក្រសួង-ស្ថាប័នមន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវរៀបចំខ្លឹមសារនៃផ្នែកទី៥ នេះតាមតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ ។

ក្នុងគណនាអំពីតម្រូវការថវិកា ដើម្បីអនុវត្តកម្មវិធីនីមួយៗ ត្រូវផ្តោតការយកចិត្តទុកដាក់លើចំណុចសំខាន់ៗដូចខាងក្រោម ៖

ទី១ ៖ ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈដែលរាជរដ្ឋាភិបាលបានដាក់ចេញ តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលរួមមានគោលដៅសូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ ដូចជាកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ អត្រាអតិផរណាប្រចាំឆ្នាំ និងគោលដៅសូចនាករចំណាយ ព្រមជាមួយនឹងគោលនយោបាយអាទិភាពចំណាយទាំងផ្នែកចំណាយចរន្ត និងចំណាយមូលធន ឬហៅថាចំណាយវិនិយោគ

ទី២ ៖ ការវាយតម្លៃលើសមត្ថភាពរបស់ខ្លួន ក្នុងការអនុវត្តចំណាយក្នុងរយៈពេលកន្លងមក និងការប៉ាន់ស្មានសមត្ថភាពអនុវត្តចំណាយក្នុងឆ្នាំ ២០១៦ដែលក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្តនិងគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗបាន និងកំពុងអនុវត្ត

ទី៣ ៖ ការកំណត់តម្រូវការថវិកាតាមឆ្នាំនីមួយៗ ត្រូវគណនាចំណាយប្រកបដោយសុក្រឹតភាពទៅតាមតម្រូវការជាក់ស្តែងនៃកម្មវិធីនីមួយៗ ដោយត្រូវគិតគូរឈរលើទិដ្ឋភាពបី ៖

• ផែនការសកម្មភាព ឬសកម្មភាពការងារដែលមានស្រាប់ដែលត្រូវបន្តអនុវត្ត ដើម្បីសម្រេចគោលនយោបាយរបស់ក្រសួង-ស្ថាប័នរៀងៗខ្លួន

• ផែនការសកម្មភាព ឬសកម្មភាពការងារដែលមានលក្ខណៈបញ្ចប់ត្រឹមមួយឆ្នាំ និង

• ផែនការសកម្មភាព ឬសកម្មភាពការងារថ្មី ដើម្បីសម្រេចគោលនយោបាយរបស់ ក្រសួង-ស្ថាប័នរៀងៗខ្លួន ។

ដូច្នេះផ្អែកលើគោលការណ៍ទាំងបីខាងលើនេះ គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី/ខេត្តនិងគ្រឹះស្ថាន សាធារណៈរដ្ឋបាលក្រោមឱវាទទាំងអស់ ត្រូវគ្រោងតម្រូវការចំណាយសម្រាប់ឆ្នាំ ២០១៧- ២០១៩ ។*(សូមមើលបន្ថែមក្នុងឧបសម្ព័ន្ធទី២)*

### ១.៤.១.២ ប្រតិទិននៃការរៀបចំកញ្ចប់ថវិកាប្រចាំឆ្នាំ[4]

ជាទូទៅ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមុននឹងសម្រេចកញ្ចប់ថវិកាសម្រាប់ការអនុវត្តបាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវធ្វើសំណើរស្នើមក ប្រធានអង្គភាពនីមួយៗ ដើម្បីចាត់តំណាងក្រុមការងារថវិកាដែលមានសិទ្ធសម្រេចលើកញ្ចប់ថវិកាឆ្នាំនីមួយៗ របស់អង្គភាពថវិកានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីធ្វើការប្រជុំជាពីរកម្រិតគឺ កម្រិតថ្នាក់បច្ចេកទេស និងកម្រិតថ្នាក់ដឹកនាំ។

• **កម្រិតបច្ចេកទេស**

រាល់កញ្ចប់ថវិកាដែលបានគ្រោងសម្រាប់ចំណាយប្រចាំឆ្នាំ ត្រូវឆ្លងកាត់ជាច្រើនដំណាក់-កាល ទើបអាចទទួលបានថវិកានោះទៅអនុវត្ត យ៉ាងណាមិញថវិកាដែលបានគ្រោងជាដំបូងត្រូវឆ្លងកាត់កិច្ចប្រជុំកម្រិតថ្នាក់បច្ចេកទេសជាមុនសិន នៅក្នុងកិច្ចប្រជុំកម្រិតថ្នាក់បច្ចេកទេសមានន័យថាមានអគ្គនាយកដ្ឋានថវិកាជាអ្នកដឹកនាំការប្រជុំ ដែលបានអញ្ជើញមន្ត្រីជំនាញមកពីអង្គភាពថវិកាក្រោមឱវាទរបស់ក្រសួង ដើម្បីចរចាថវិកាដែលបានគ្រោង ហើយមានតំណាងអគ្គថវិកាដែលជាប្រធានរបស់អង្គប្រជុំ ធ្វើបទបង្ហាញអំពីគម្រោងថវិការបស់អង្គភាពនីមួយៗ ក្នុងករណីដែលអង្គភាពមួយគ្រោងលើសពី ១០% (គោលការណ៍នៃការគ្រោងថវិកាមិនឱ្យលើសពី ១០% នៃថវិកាប្រចាំឆ្នាំក្នុងករណីគ្រោងលើស)នៃថវិកាប្រចាំឆ្នាំ ក្នុងករណីគ្រោងលើសប្រធានអង្គប្រជុំ មានសិទ្ធស្នើកាត់ថវិកា ប៉ុន្តែប្រសិនបើអង្គភាពថវិកាណាមួយដែលមិនសុខចិត្តចំពោះការកាត់នេះ អង្គភាពថវិកាអាចលើកជាហេតុផលជាក់លាក់មួយ ថាមិនអោយកាត់ថវិកាហ្នឹងបានទេ នោះប្រធានអង្គប្រជុំក៏សម្រេចថា និងសម្រេចអោយថវិការបស់អង្គភាពនេះទៅប្រជុំ នៅកម្រិតថ្នាក់ដឹកនាំវិញ ។

[4]ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី

- **កម្រិតថ្នាក់ដឹកនាំ**

ចំពោះកម្រិតថ្នាក់ដឹកនាំ មានឯកឧត្តមទេសរដ្ឋមន្ត្រីជាអ្នកដឹកនាំអង្គប្រជុំ ដែលមានសមាសភាពចូលរួមពីប្រធានអង្គភាពថវិកានីមួយៗ នៅក្នុងកម្រិតថ្នាក់ដឹកនាំ គឺប្រធានអង្គភាពនឹងធ្វើការ បកស្រាយថាហេតុអ្វីបានជាថវិកា កើនឡើងច្រើនជាង ១០% បន្ទាប់មកឯកឧត្តមប្រធានអង្គប្រជុំ និងធ្វើការបកស្រាយថាផ្តល់ថវិកាអោយ ឬមិនគួរអោយ ពេលនោះប្រធានអង្គប្រជុំនិងបកស្រាយថាថវិកា ដែលអង្គភាពនីមួយៗសំខាន់ ឬមិនសំខាន់ ប្រសិនបើថវិកានោះចាំបាច់ និងសំខាន់នោះ ឯកឧត្តមប្រធានអង្គភាពនឹងព្រមតាមសំណើរ ប៉ុន្តែប្រសិនបើមិនសំខាន់ សំណើរថវិកាអាចត្រូវបានបន្តសម្រាប់ឆ្នាំបន្តបន្ទាប់ ។

## ១.៥ការត្រៀមការអនុវត្តថវិកា

ដើម្បីកំណត់ឱ្យបានច្បាស់លាស់នូវសិទ្ធអំណាច និងការទទួលខុសត្រូវក្នុងការរៀបចំការអនុវត្ត ការវាយតម្លៃផ្សេងៗ អង្គភាពទទួលបន្ទុកនីមួយៗតែងតែមានក្រុមការងារដើម្បីអនុវត្តសម្រាប់អង្គភាពរបស់ខ្លួនជានិច្ច ហើយការអនុវត្តការងារត្រូវបានកំណត់ដោយច្បាប់ និងថ្នាក់ដឹកនាំរបស់អង្គភាពទាំងនោះគោលបំណងនេះគឺដើម្បីកំណត់សិទ្ធអំណាច និងការទទួលខុស ត្រូវឱ្យបានច្បាស់លាស់ក្នុងការអនុវត្តសកម្មភាពការងារ គឺដើម្បីបង្កើតបានជាលទ្ធផលជាក់លាក់ និងអាចវាស់វែងបានដល់អង្គភាពនីមួយៗ ជាពិសេសអង្គភាពថវិកា ដែលជាប្រតិបត្តិករថវិកាកម្មវិធី នៃក្រសួងស្ថាប័នថវិកាកម្មវិធី ។ ម្យ៉ាងវិញទៀត ការកំណត់នេះដើម្បីបង្កើនប្រសិទ្ធភាព ស័ក្តសិទ្ធភាព និងលើកកម្ពស់តម្លាភាព គណនេយ្យភាព ក្នុងការគ្រប់គ្រង និងអនុវត្តថវិកាទៅតាមសកម្ម ភាពការងារ និងសម្រេចបានលទ្ធផលការងារកាន់តែប្រសើរ និងប្រកបដោយប្រសិទ្ធភាពទាំងទិដ្ឋ ភាពថវិកា និងទិដ្ឋភាពសេវាសាធារណៈ ។ ខាងក្រោមនេះគឺជាសិទ្ធអំណាច និងការទទួលខុសត្រូវ ក្នុងការអនុវត្តថវិកាកម្មវិធី ៖

### ១.៥.១ អាណាប័ក

អាណាប័ក គឺជាអភិបាលកំពូលនៃក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល ដែលមានសិទ្ធអំណាចគ្រប់គ្រាន់តាមច្បាប់ ក្នុងការបញ្ជាចំណូល និងបញ្ជាចំណាយថវិការបស់ក្រសួងស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល ។ ក្នុងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុអាណាប័កចាត់ចែងក្រោមការទទួលខុសត្រូវរបស់ខ្លួនក្នុងកម្រិតឥណទានថវិកា ដែលទទួលបានដើម្បីស្នើសុំធានាចំណាយ អនុវត្តកិច្ចលទ្ធកម្មសាធារណៈ បោះផ្សាយអាណត្តិបើកប្រាក់ និងកិច្ចបញ្ជិកាក្នុងវង្វង់ថវិការបស់ខ្លួន ។

**អាណាប័កចែកចេញជាបីប្រភេទ៖**

**ក. អាណាប័កដើមខ្សែ** ៖ គឺជារដ្ឋមន្ត្រី ប្រធានស្ថាប័ន និងប្រធានអង្គភាពសាធារណៈ ប្រហាក់ប្រហែលដែលមានសិទ្ធពេញលេញក្នុងការបញ្ជាចំណាយថវិកាដោយខ្លួនឯងផ្ទាល់ដោយត្រូវគោរពទៅតាមព្រំដែននៃសិទ្ធអំណាច និងមុខងាររបស់ខ្លួន ។

**ខ. អាណាប័កផ្ទេរសិទ្ធ** ៖ គឺជាអភិបាលរាជធានី ខេត្ត ដែលទទួលបានសិទ្ធប្រទានពីអាណាប័កដើមខ្សែសម្រាប់កិច្ចប្រតិបត្តិការហិរញ្ញវត្ថុនៃថវិកាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ឬជាប្រធានមន្ទីរជំនាញ រាជធានី/ខេត្ត ឬប្រធានអង្គភាពក្រោមឱវាទ ដែលទទួលបានការផ្ទេរសិទ្ធពីអាណាប័កដើមខ្សែ សម្រាប់កិច្ចប្រត្តិបត្តិការហិរញ្ញវត្ថុនៃថវិកា បន្ទាប់ពីមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋ កិច្ច និងហិរញ្ញវត្ថុ ។

**គ. អាណាប័កជំនួស** ៖ គឺជាមន្ត្រីរាជការ ដែលអាណាប័កដើមខ្សែ ឬអាណាប័កផ្ទេរសិទ្ធបានជ្រើសតាំងដើម្បីផ្ទេរសិទ្ធ ឬជំនួសខ្លួនដោយផ្អែកលើបទបញ្ជាគណនេយ្យសាធារណៈក្នុងពេលដែលអាណាប័កដើមខ្សែ ឬអាណាប័កផ្ទេរសិទ្ធ អវត្តមានពីការងារ ឬមានធុរៈ ។

### ១.៥.២ ក្រុមការងារថវិកា

ដើម្បីសម្រេចនូវការកំណត់គោលដៅរបស់រដ្ឋាភិបាល ក្នុងការអនុវត្តថវិកាឲ្យមានប្រសិទ្ធភាព ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមានអង្គភាពថវិកាជាអ្នកទទួលខុសត្រូវនិងត្រួតពិនិត្យលើការអនុវត្តថវិការបស់ក្រសួងស្ថាប័ននីមួយៗ នៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយក្រុមការងារថវិកាទាំងនោះចែកចេញជា ៤ កម្រិតដូចខាងក្រោម ៖

- **ក្រុមការងារថវិកាកម្រិតថ្នាក់ដឹកនាំ**(ក.ថ.ក) ៖ ក្រុមការងារថវិកាកម្រិតថ្នាក់ដឹកនាំ គឺជាក្រុមការងារទាំងឡាយណាដែលដឹកនាំដោយរដ្ឋមន្ត្រី និងមានសមាសភាពនៃគ្រប់រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- **ក្រុមការងារថវិកាកម្រិតថ្នាក់ដឹកនាំអង្គភាពថវិកា** (ក.ថ.អ) ៖ ក្រុមការងារថវិកាកម្រិតថ្នាក់ដឹកនាំអង្គភាពថវិកា គឺជាក្រុមការងារទាំងឡាយណាដែលដឹកនាំដោយរដ្ឋលេខាធិការ ទទួលបន្ទុកអគ្គលេខាធិការដ្ឋាន និងមានសមាសភាពនៃគ្រប់ប្រធានអង្គភាពថវិកាកណ្ដាល ។
- **ក្រុមការងារកម្រិតថ្នាក់បច្ចេកទេស** (ក.ថ.ប) ៖ ក្រុមការងារកម្រិតថ្នាក់បច្ចេកទេស គឺជាក្រុមការងារទាំងឡាយណា ដែលដឹកនាំដោយអគ្គលេខាធិការ ដោយមានសមាសភាព នៃថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃអគ្គលេខាធិការដ្ឋាន ។

- **ក្រុមការងារថវិកាកម្រិតផ្ទៃក្នុងអង្គភាពថវិកា** (ក.ថ.ផ) ៖ ក្រុមការងារថវិកាកម្រិតផ្ទៃ ក្នុងអង្គភាពថវិកា គឺជាក្រុមការងារទាំងឡាយដែលដឹកនាំដោយប្រធានអង្គភាព អមដោយថ្នាក់ដឹក នាំ និងមន្ត្រីជំនាញនៃអង្គភាពថវិកានីមួយៗ ។

### ១.៥.២.១ក្រុមលទ្ធកម្ម

ក្រុមការងារលទ្ធកម្មត្រូវបានបង្កើតឡើងក្នុងគោលបំណង កំណត់យន្តការនៃការដឹកនាំនិងការអនុវត្តលទ្ធកម្មសាធារណៈ របស់អង្គភាពថវិកានៃស្ថាប័នអនុវត្តលទ្ធកម្ម ដើម្បីធានាឱ្យការដឹកនាំ និងការអនុវត្តលទ្ធកម្មសាធារណៈសម្រាប់ការទិញ ការសាងសង់ ការជួសជុល ការជួលសេវាកម្ម និងការជួលសេវាទីប្រឹក្សាប្រព្រឹត្តទៅដោយរលូន ប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព សមភាព ការសន្សំសំចៃ និងទាន់ពេលវេលា ។ នីតិវិធី លម្អិតសម្រាប់បង្កើតក្រុមលទ្ធកម្មត្រូវអនុវត្តតាមប្រកាសលេខ២៤៩ សហវ.ប្រកចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥[5] ស្តីពីការបង្កើតក្រុមលទ្ធកម្មរបស់អង្គភាពថវិកា ។ ដើម្បីបង្កើតក្រុមលទ្ធកម្មបានអង្គភាពថវិកា ត្រូវស្នើសុំសាមីស្ថាប័នអនុវត្តលទ្ធកម្ម ដើម្បីបង្កើតនិងតែងតាំងក្រុមលទ្ធកម្មមួយ សម្រាប់ថ្នាក់ដឹកនាំ និងអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ឱ្យបានត្រឹមត្រូវតាមគោលការណ៍វិធានវិធីសាស្ត្រនិងនីតិវិធី ដែលត្រូវបានកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។ក្រុមលទ្ធកម្ម គឺជាក្រុមមន្ត្រីរបស់អង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិ ដែលត្រូវបានចាត់តាំងសម្រាប់អនុវត្តកិច្ចលទ្ធកម្មសាធារណៈរបស់អង្គភាពថវិកា ក្នុងកម្រិតឥណទានថវិកា និងសិទ្ធអំណាចប្រគល់ជូនដោយអាណាប័កដើមខ្សែ ។

ក្រុមការងារលទ្ធកម្មមានសមាសភាពដូចតទៅ ៖

| | | |
|---|---|---|
| • ប្រធានអង្គភាពថវិកា | | ប្រធាន |
| • អនុប្រធានអង្គភាពថវិកា | ១រូប | អនុប្រធាន |
| • មន្ត្រី | ៣រូប | សមាជិក |

ក្រុមលទ្ធកម្មអាចមានតំណាង១រូប ពីអង្គភាពបច្ចេកទេសពាក់ព័ន្ធមុខសញ្ញាលទ្ធកម្មនីមួយៗជាសមាជិកចំពោះកិច្ច ដោយពេញច្បាប់ ដើម្បីពិគ្រោះយោបល់អាស្រ័យទៅតាមគម្រោងលទ្ធកម្មនីមួយៗ ។ សមាសភាពជាក់ស្តែងនៃក្រុមលទ្ធកម្ម ត្រូវកំណត់ដោយប្រកាស សេចក្តីសម្រេច ឬដីការបស់ប្រធានស្ថាប័នអនុវត្តលទ្ធកម្ម ។

[5] ក្រសួងសេដ្ឋកិច្ច, សេចក្តីប្រកាសលេខ២៤៩ សហវ.ប្រកចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការបង្កើតក្រុមលទ្ធកម្ម

## ភារកិច្ច និងការទទួលខុសត្រូវ

ភារកិច្ច និងការទទួលខុសត្រូវនៅក្នុងអង្គភាពនីមួយៗសុទ្ធតែដូចៗគ្នា ដោយ ផ្នែកក្រុមការងារលទ្ធកម្ម មានភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោម ៖

- រៀបចំសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំ និង/ឬផែនការលទ្ធកម្មកែតម្រូវ ដោយបញ្ចូលជាឧបសម្ព័ន្ធនៃផែនការលទ្ធកម្មរបស់សាមីស្ថាប័នអនុវត្តលទ្ធកម្ម ដែលត្រូវផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិនិត្យនិងអនុម័ត
- អនុវត្តកិច្ចលទ្ធកម្ម ស្របតាមផែនការលទ្ធកម្មដែលត្រូវបានអនុម័តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។
- កំណត់បុរេលក្ខណៈសម្បត្តិ ចំពោះកិច្ចលទ្ធកម្មដែលមានលក្ខណៈស្មុគស្មាញ
- រៀបចំ ពិនិត្យ និងសម្រេចលើឯកសារដេញថ្លៃដែលស្ថិតក្នុងសិទ្ធិសម្រេចរបស់ខ្លួន ឬបញ្ជូនឯកសារដេញថ្លៃទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីពិនិត្យ និងផ្តល់ទិដ្ឋាការចំពោះកិច្ចលទ្ធកម្មដែលលើសសិទ្ធសម្រេចរបស់ខ្លួន
- រៀបចំ និងផ្សព្វផ្សាយសេចក្តីជូនដំណឹងអំពីការដេញថ្លៃ និងលក់ឬផ្តល់ឯកសារដេញថ្លៃជូនអ្នកមានបំណងចូលរួមក្នុងការដេញថ្លៃ ។
- ទទួលសំណើដេញថ្លៃ និងបកស្រាយបំភ្លឺចំពោះអ្នកដេញថ្លៃទាំងអស់ ក្នុងករណីមានសំណួរពាក់ព័ន្ធនឹងការដេញថ្លៃ ។
- ប្រជុំបើកសំណើដេញថ្លៃ ពិគ្រោះថ្លៃ ស្ទង់តម្លៃ ឬចចារថ្លៃ ។
- រៀបចំធ្វើរបាយការណ៍ ឬកំណត់ហេតុស្តីពីការបើកសំណើដេញថ្លៃ ពិគ្រោះថ្លៃ ស្ទង់តម្លៃ ឬចរចាថ្លៃ ។
- ប្រជុំវាយតម្លៃប្រគល់កិច្ចសន្យា ។
- ត្រួតពិនិត្យ និងវាយតម្លៃលក្ខណៈសម្បត្តិរបស់អ្នកដេញថ្លៃនាំមុខ ។
- រៀបចំ និងផ្ញើលិខិតជូនដំណឹងស្តីពីការប្រគល់កិច្ចសន្យាទៅអ្នកដេញថ្លៃឈ្នះ និងចម្លងជូនទៅគ្រប់អ្នកដេញថ្លៃចាញ់ ។
- រៀបចំការផ្សព្វផ្សាយលទ្ធផលនៃការដេញថ្លៃ ។
- រៀបចំសេចក្តីព្រាងកិច្ចសន្យា និងចុះហត្ថលេខាជាភាគីនៃកិច្ចសន្យា ដោយអនុលោមតាមមាត្រាដ្ឋាននិងគំរូកិច្ចសន្យាដែលកំនត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ លើការអនុវត្តកិច្ចសន្យា ។
- ដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្ម តាមសមត្ថកិច្ចរបស់ខ្លួន។
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំត្រីមាស ឆមាស និងឆ្នាំ ។

**និយមន័យបច្ចេកទេសក្នុងកិច្ចលទ្ធកម្ម**

បច្ចេកសព្ទ ឬវាក្យសព្ទទាំងឡាយសម្រាប់គោលបំនងនៃបទប្បញ្ញត្តិនេះ មានអត្ថ-ន័យដូចខាងក្រោម ៖

*តារាងទី២៖ ពាក្យបច្ចេកទេសក្នុងកិច្ចលទ្ធកម្ម*

| | |
|---|---|
| សំណើដេញថ្លៃ | សំដៅដល់សំណុំឯកសារ រួមមានឯកសារដេញថ្លៃដែលបានបំពេញដោយអ្នកដេញថ្លៃ និងឯកសារភ្ជាប់មួយចំនួនទៀត ដូចមានតម្រូវការក្នុងឯកសារដេញថ្លៃ ដែលអ្នកដេញថ្លៃបាននៅក្នុងស្ថាប័នអនុវត្តលទ្ធកម្ម សម្រាប់គោលបំណងផ្គត់ផ្គង់ទំនិញ ទទួលការសំណង់ ផ្តល់សេវាទីប្រឹក្សា |
| ប្រាក់កក់ធានាដេញថ្លៃ | ជាប្រាក់ធានាដែលអ្នកដេញថ្លៃត្រូវកក់មុន នឹងចូលរួមការដេញថ្លៃដើម្បីធានាថាអ្នកដេញថ្លៃឈ្នះនឹងទទួលយកកិច្ចសន្យាជាមួយរដ្ឋបាលក្រុងស្រុកខណ្ឌ ស្របតាមពេលវេលាដែលបានកំណត់នៅក្នុងការជូនដំណឹងស្តីពីការប្រគល់កិច្ចសន្យា |
| អ្នកដេញថ្លៃ | សំដៅទៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំនងចូលរួមក្នុងកិច្ចលទ្ធកម្មរបស់រដ្ឋបាល ក្រុង ស្រុក ខណ្ឌ និងបានដាក់សំណើរដេញថ្លៃឬសំណើរបញ្ជាក់ពី ចំណាប់អារម្មណ៍ |
| ការដេញថ្លៃ | សំដៅដល់ដំណើរការលទ្ធកម្មដែលសំណើរដេញថ្លៃ ត្រូវបានដាក់ទទួល និងវាយតម្លៃកិច្ចសន្យា សម្រាប់គោលបំនងប្រគល់កិច្ចសន្យា។ |
| ឯកសារដេញថ្លៃ | សំដៅដល់សំណុំឯកសារដែលអង្គភាពលទ្ធកម្ម បានរៀបចំនិងផ្តល់ជាដំបូងទៅឱ្យអ្នកដេញថ្លៃ ដើម្បីប្រើសម្រាប់រៀបចំសំណើរដេញថ្លៃដែលរួមមានពាក្យសុំ ដេញថ្លៃ សេចក្តីអញ្ជើញឱ្យចូលរួមក្នុងកំណត់បុរេ លក្ខណៈសម្បត្តិសេចក្តីណែនាំចំពោះអ្នកដេញថ្លៃ លក្ខណៈបច្ចេកទេស ទំហំការងារ ល័ក្ខខណ្ឌយោងនិងលក្ខខណ្ឌកិច្ចសន្យា ។ |
| ទីប្រឹក្សា | សំដៅទៅដល់ទីប្រឹក្សាឯកត្តជនឬក្រុមហ៊ុនទីប្រឹក្សាដែលមានមុខរបរសេវាផ្នែកបញ្ញា ។ |
| សេវាទីប្រឹក្សា | សំដៅទៅដល់ សេវាជំនាញការដែលផ្តល់ដោយក្រុមហ៊ុនទីប្រឹក្សា ឬទីប្រឹក្សាឯកត្តជនដែលពាក់ព័ន្ធគម្រោងណាមួយឬសម្រាប់ពង្រឹងពង្រីកស្ថាប័ន ឬបង្កើនសមត្ថភាព ។ |

| | |
|---|---|
| កិច្ចសន្យា | ជាកិច្ចព្រមព្រៀងរវាងរដ្ឋបាលក្រុង ស្រុកខណ្ឌជាមួយនឹងអ្នកផ្គត់ផ្គង់ទំនិញ អ្នកទទួលសំណង់ ផ្តល់សេវាកម្ម ឬ សេវាទីប្រឹក្សា។ |
| ប្រាក់កក់ធានាអនុវត្តកិច្ចសន្យា | ជាប្រាក់ធានាដែលអ្នកដេញថ្លៃឈ្នះបានកក់ដើម្បីធានាការបំពេញកាតព្វកិច្ចរបស់ខ្លួនត្រឹមត្រូវតាមលក្ខខណ្ឌនៃកិច្ចសន្យា ។ប្រាក់កក់ធានានេះនឹងត្រូវរឹបអូសដោយរដ្ឋបាលក្រុង ស្រុកខណ្ឌ ក្នុងករណីដែលអ្នកដេញថ្លៃឈ្នះខកខានពុំបានបំពេញនូវកាតព្វកិច្ចរបស់ខ្លួន តាមលក្ខខណ្ឌនៃកិច្ចសន្យា។ |
| ទំនិញ | សំដៅដល់វត្ថុរាវ រឹងឬជាឧស្ម័នដែលមានតម្លៃឬផលប្រយោជន៍សេដ្ឋកិច្ចដូចជាគ្រឿងចក្រ ឧបករណ៍ សម្ភារៈគ្រឿងឧបភោគបរិភោគ ឱសថ និងផលិតផលផ្សេងៗរួមទាំងអគ្គិសនីផងដែរ ។ |
| សំណង់ | សំដៅដល់រាល់សកម្មភាពដែលពាក់ព័ន្ធនិងការងារសាងសង់ការងារជួសជុលការធ្វើឡើងជាថ្មី ការដំឡើង ការជីក ការបូមនិងការងារប្រហាក់ប្រហែលដែលបង្កើតឱ្យមានការប្រើប្រាស់កម្លាំងពលកម្ម គ្រឿងម៉ាស៊ីនបរិក្ខារ និងបច្ចេកវិទ្យា ។ |
| លទ្ធកម្ម | សំដៅដល់ការ ឬរកបាននូវទំនិញ សំណង់ សេវាកម្ម ឬសេវាទីប្រឹក្សាតាមរយៈវិធីសាស្ត្រដូចបានកំណត់ក្នុងបទប្បញ្ញត្តិនេះ ។ |
| កិច្ចលទ្ធកម្ម | សំដៅដល់ដំណើរការលទ្ធកម្ម ចាប់ពីពេលរៀបចំឯកសារដេញថ្លៃរហូតដល់ពេលទទួលបានទំនិញ សំណង់ សេវាកម្ម ឬសេវាទីប្រឹក្សា ។ |
| សេវាកម្ម | សំដៅទៅដល់រាល់សកម្មភាពដែលពាក់ព័ន្ធនឹងការប្រើប្រាស់កម្លាំងមនុស្សគ្រឿងបរិក្ខារ ឬបច្ចេកវិទ្យាដែល នាំមកនូវផលប្រយោជន៍រដ្ឋបាលក្រុង ស្រុកខណ្ឌប៉ុន្តែមិនរាប់បញ្ចូលការងារសាងសង់ និងសេវាទីប្រឹក្សាទេ ។ |
| អង្គភាពប្រើប្រាស់ | ជាអង្គភាព ឬការិយាល័យរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌដែលស្នើកិច្ចលទ្ធកម្ម |

*ប្រភព ៖ សេចក្តីណែនាំស្តីពីវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មរបស់រដ្ឋបាល ក្រុង ស្រុក ខណ្ឌ*

**សិទ្ធិអំណាច និងកិច្ចដំណើរការអនុវត្តកិច្ចលទ្ធកម្ម**

- ចំពោះអង្គភាពថវិកាថ្នាក់កណ្តាលនៃស្ថាប័នអនុវត្តលទ្ធកម្មថ្នាក់ជាតិ កម្រិតទឹកប្រាក់សិទ្ធិ សម្រេចលទ្ធកម្មត្រូវអនុវត្តដូចគ្នានឹងកម្រិតទឹកប្រាក់សិទ្ធិសម្រេចលទ្ធកម្ម របស់សាមីស្ថាប័នអនុវត្តលទ្ធ

- ចំពោះអង្គភាពថវិកាថ្នាក់មូលដ្ឋាន នៃស្ថាប័នអនុវត្តលទ្ធកម្មថ្នាក់ក្រោមជាតិ កម្រិតទឹកប្រាក់ សិទ្ធសម្រេចលទ្ធកម្មត្រូវអនុវត្តដូចគ្នា និងកម្រិតទឹកប្រាក់សិទ្ធិសម្រេចលទ្ធកម្មរបស់មន្ទីរជំនាញរាជ ធានី ខេត្ត។

- ចំពោះអង្គភាពថវិកា នៃស្ថាប័នអនុវត្តថ្នាក់ក្រោមជាតិ កម្រិតទឹកប្រាក់សិទ្ធិសម្រេចលទ្ធកម្ម ត្រូវអនុវត្តដូចគ្នានិងកម្រិតទឹកប្រាក់សិទ្ធិសម្រេចលទ្ធកម្ម របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

- អង្គភាពថវិកានៃរដ្ឋបាលថ្នាក់ជាតិ ត្រូវរៀបចំនិងផ្ញើរបាយការណ៍អនុវត្តលទ្ធកម្មប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំផ្ញើមកសាមីស្ថាប័នអនុវត្តលទ្ធកម្ម ដើម្បីបូកសរុបជាឧបសម្ព័ន្ធនៃរបាយការណ៍ អនុវត្តលទ្ធកម្ម របស់សាមីស្ថាប័នអនុវត្តលទ្ធកម្ម ដែលត្រូវបញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

- អង្គភាពថវិកានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំនិងផ្ញើរបាយការណ៍អនុវត្តលទ្ធកម្មប្រចាំ ត្រីមាស ឆមាស និងឆ្នាំផ្ញើមកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានីខេត្ត ដើម្បីបូកសរុប និងបញ្ជូនមក អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ចំណាយតម្រូវឱ្យអនុវត្តតាមលទ្ធកម្មសាធារណៈ**

ចំណាយតម្រូវឱ្យអនុវត្តតាមនីតិវិធីលទ្ធកម្មសាធារណៈ គឺចំណាយលើការទិញ ការសាងសង់ ការជួសជុល ការជួលសេវាកម្ម និងការជួលទីប្រឹក្សា នៃជំពូក៦០ ជំពូក៦៤ ជំពូក៦៥ ដោយអនុលោមតាមមាត្រា៦៥ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០០៨[6] ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ ២០១២[7] អនុក្រឹត្យលេខ១៣ អនក្រ.បក ចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០១៥ ស្តី ពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មាធិកាលទ្ធកម្ម និងអង្គភាពលទ្ធកម្ម ប្រកាសលេខ ២៤៩ សហវ.ប្រក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ ២០១៥ ស្តីពីការបង្កើតក្រុមលទ្ធកម្មរបស់អង្គភាពថវិកា សៀវភៅលទ្ធកម្មស្តីពីការអនុវត្តវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ និងលិខិតបទដ្ឋានគតិយុត្តដទៃទៀតដែលពាក់ព័ន្ធនឹងលទ្ធកម្ម សាធាណៈ។

- **នីតិវិធីអនុវត្តចំណាយ**

[6] រាជរដ្ឋាភិបាលកម្ពុជា, ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០០៨

[7] ក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុ, ប្រកាសស្តីពីកិច្ចលទ្ធកម្មសាធារណៈឆ្នាំ ២០១៥- ២០១៦

- **ដំណាក់កាលធានាចំណាយ**

ចំណាយសាធារណៈត្រូវបានអនុញ្ញាតឱ្យអនុវត្តដោយអនុលោមតាម ខ្លឹមសារនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០០៨ [8] ស្តីពីបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការបស់រដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល ។ ដូច្នេះក្រសួងស្ថាប័នត្រូវដាក់សំណើរសុំគោលការណ៍ធានាចំណាយមក ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំណែកមន្ទីរជំនាញ រាជធានី ខេត្ត ត្រូវដាក់សំណើរសុំគោលការណ៍ ធានាចំណាយមកមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយត្រូវឆ្លងកាត់បរិបទនៅក្នុងក្រសួង ស្ថាប័នសាមី និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬមន្ទីរជំនាញរាជធានីខេត្ត និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជធានីខេត្ត ដូចខាងក្រោម ៖

- **ដំណើរការស្នើសុំគោលការណ៍ធានាចំណាយ**

បន្ទាប់ពីឥណទានថវិកាត្រូវបានអនុម័តដោយច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ និងត្រូវបានវិភាជន៍លម្អិតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អង្គភាពថវិកាស្ថិតនៅក្រោមឱវាទនៃក្រសួង ស្ថាប័នអាចចាប់ផ្តើមរៀបចំសំណើរចំណាយថវិកាស្របតាមសៀវភៅវិភាជន៍ថវិកា គម្រោង ចំណាយក្នុងការរៀបចំថវិកា ស្របតាមផែនការលទ្ធកម្មសាធារណៈ តាមសកម្មភាពនៃថវិកាកម្មវិធី និងតាមតម្រូវការចាំបាច់ក្នុងការចំណាយ ។

ជាទូទៅ ដំណើរការស្នើសុំគោលការណ៍ធានាចំណាយត្រូវចាប់ផ្តើមឡើងដោយអង្គភាពថវិកា ដែលជាប្រតិបត្តិករកម្មវិធី អនុកម្មវិធី ឬសកម្មភាពនៃក្រសួង ស្ថាប័ននិងមន្ទីរជំនាញរាជធានីខេត្ត ។ រយៈពេលនៃការអនុវត្តចំណាយចាប់ពីដំណាក់កាលសុំគោលការណ៍ រហូតដល់ការប្រគល់ទទួលទំនិញ សំណង់ឬសេវាត្រូវការពេលវេលាច្រើនខែ ។ ដូច្នេះក្រសួង ស្ថាប័ននិងអង្គភាព ថវិកាត្រូវរូតរះលើកសំណើរសុំគោលការណ៍ចំណាយជាមុនដើម្បីទទួលបានទំនិញ សំណង់ ឬសេវា ប្រើប្រាស់ទាន់ពេលវេលា ។ ការលើកសំណើរសុំចំណាយនេះត្រូវអនុលោមតាមគោលចំណុចសំខាន់បួនគឺ ៖

(១) ឥណទានស្នើសុំស្របតាមតម្រូវការបរិមាណ គុណភាព តម្លៃនិងយថាប្រភេទនៃទំនិញ សំនង់ ឬសេវាជាក់ស្តែង

(២) កម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងលទ្ធផលរំពឹងទុក

(៣) ខ្ទង់មាតិកាថវិកាចំណាយ និង

(៤) ពេលវេលា សម្រាប់អនុវត្តការងារ ឬ គម្រោង ។

[8] រាជរដ្ឋាភិបាលកម្ពុជា, ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ, មាត្រា ៦៤ និងមាត្រា ៦៥ និងអនុក្រឹត្យលេខ ៨១អនក្រ.បកចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥

អង្គភាពថវិកាត្រូវលើកសំណើរសុំគោលការណ៍ចំណាយថវិកា ទៅរដ្ឋមន្ត្រី ប្រធានស្ថាប័ន និងមន្ទីរជំនាញរាជធានីខេត្ត ដែលជាអាណាប័កដើមខ្សែ ឬអាណាប័កផ្ទេរសិទ្ធ តាម រយៈអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួងស្ថាប័នរបស់ខ្លួនអំពីតម្រូវការទំនិញ សំណង់ឬសេវា ផ្សេងទៀត សម្រាប់ប្រើប្រាស់ក្នុងអង្គភាពថវិការបស់ខ្លួន (គំនូសតាង១) និង(គំនូសតាង២)។

*តារាងទី៣៖ កិច្ចដំណើរការស្នើសុំគោលការណ៍ធានាចំណាយ*

**ថ្នាក់ដឹកនាំ**
**ក្រសួងស្ថាប័ន**
អាណាប័កដើមខ្សែ ឬជំនួសពិនិត្យនិងសម្រេច
ចុះហត្ថលេខា

**អគ្គនាយកដ្ឋាន/អគ្គនាយកដ្ឋានហិរញ្ញវត្ថុ**
ពិនិត្យផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្រសួងស្ថាប័នសាមី ដើម្បីពិនិត្យនិងសម្រេច
ចុះហត្ថលេខាដាក់ជូន កសហវ

**អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ**
- ត្រួតពិនិត្យវាយតម្លៃតម្រូវការជាក់ស្តែងរបស់អង្គភាពថវិកា
- បូកសរុបគម្រោងស្នើសុំចំណាយថវិការបស់អង្គភាពថវិកាចំនុះ
- រៀបចំលិខិតស្នើសុំគោលការណ៍ចំណាយទៅសហករ
- បំពេញសាលាប័ត្រកត់ត្រាចំណាយតាមដានឥណទាន

**អង្គភាពថវិកា**
- ពិនិត្យតម្រូវការទំនិញសំណង់សេវាកម្ម និងសេវាទីប្រឹក្សា និងចំណាយផ្សេងៗរបស់ការិយាល័យនៃអង្គភាពក្នុងផែនការលទ្ធកម្ម
- រៀបចំគម្រោងស្នើសុំចំណាយថវិកា

*ប្រភព ៖ ការរៀបចំផែនការថវិកាឆ្នាំ ២០១៦*

### ១.៥.២.២ រជ្ជទេយ្យករចំណូល

រជ្ជទេយ្យករចំណូល ជាអ្នកប្រមូលចំណូលរជ្ជទេយ្យជាសាច់ប្រាក់ ឬជាមូលប្បទានប័ត្រ ឬដោយបង្វែរចូលគណនីទោលរបស់រតនាគារ ។ រជ្ជទេយ្យករចំណូលត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីរាជការ ដែលមានលក្ខណៈសម្បត្តិល្អ និងមានការយល់ដឹងច្បាស់លាស់អំពីកិច្ចបញ្ជិកាគណនេយ្យ ដែលអាចគ្រប់គ្រងលើរជ្ជទេយ្យចំណូល ។

រជ្ជទេយ្យករចំណូល និងរជ្ជទេយ្យករចំណូលរងស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អាណាប័ករបស់ខ្លួន ឬប្រធានអង្គភាពថវិកាដែលជាអាណាប័កផ្ទេរសិទ្ធិ និងគណនេយ្យករសាធារណៈ ហើយត្រូវទទួលខុសត្រូវផ្ទាល់ខ្លួនផ្នែករដ្ឋបាល ផ្នែករដ្ឋប្បវេណី ផ្នែកព្រហ្មទណ្ឌ និងជាប្រាក់កាសចំពោះការរក្សាការពារមូលនិធិដែលខ្លួនទទួលបាននិងការរក្សាទុកលិខិតយុត្តិការ ព្រមទាំងការកាន់កាប់បញ្ជីគណនេយ្យនៃកិច្ចប្រតិបត្តិការរជ្ជទេយ្យចំណូល ។

ការស្នើតែងតាំងរជ្ជទេយ្យករចំណូល និងរជ្ជទេយ្យករចំណូលរង ត្រូវអនុលោមតាមប្រការ៤ ប្រការ៥ និងប្រការ៦ នៃប្រកាសលេខ ១៨៩០សហវ.ប្រកចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៥ ស្ដីពីនីតិវិធី នៃការគ្រប់គ្រងរជ្ជទេយ្យករចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ។

កិច្ចដំណើរការអនុវត្ត និងគ្រប់គ្រងរជ្ជទេយ្យចំណូលរបស់រជ្ជទេយ្យករចំណូល និងរជ្ជទេយ្យករចំណូលរង ត្រូវអនុលោមតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន ។

- **មុខសញ្ញានៃរជ្ជទេយ្យចំណូល មានជាអាទិ៍៖**
  - ផលដែលទទួលនៅពេលប្រគល់ឯកសារជាផ្លូវការ ឬក្នុងការបំពេញបែបបទផ្សេងៗ
  - ផលបានមកពីការលក់ឯកសារ និងសម្ភារៈផ្សេងៗ
  - សិទ្ធចូល (សកម្មភាព ភាពយន្ត ទេសចរណ៍ វប្បធម៌)
  - ចំណូលបានមកពីការត្រួតពិនិត្យ ឬការងារបំពេញ
  - សំណងតម្លៃសេវាកម្មដែលបានផ្ដល់
  - ពិន័យពីបទល្មើសចរាចរ និងបទល្មើសផ្សេងៗទៀត
  - ចំណូលផ្សេងៗដែលកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិជាធរមាន
- **ការប្រមូលចំណូលដោយរជ្ជទេយ្យករ**
  - ក្រោយពីបានប្រកាសតែងតាំងរួចរជ្ជទេយ្យករត្រូវបើកគណនីនៅអគ្គនាយកដ្ឋានរតនាគារ ជាតិសម្រាប់ថ្នាក់ជាតិ ឬនៅរតនាគារជាតិរាជធានីខេត្ត ក្រុងសម្រាប់ថ្នាក់ក្រោមជាតិ

- ចំនួន១ច្បាប់ ជូនទៅអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគាររតនាគាររាជធានី ខេត្ត ក្រុងដើម្បី ទុកជាឯកសារ ។
- ចំនួន១ច្បាប់ជូនទៅអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ឬមន្ទីរសេដ្ឋ កិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ក្រុងដើម្បីទុកជាឯកសារ ។
- រដ្ឋទេយ្យករត្រូវប្រមូលប្រាក់ដោយផ្អែកលើតារាងតម្លៃដែលបានកំណត់ជាធរមាន ។
- រដ្ឋទេយ្យករអាចប្រមូលជាសាច់ប្រាក់ ឬជាមូលប្បទានប័ត្រឬដោយបង្វែរ

### ១.៥.២.៣ រដ្ឋទេយ្យករបុរេប្រទាន និងរដ្ឋទេយ្យករបុរេប្រទានរង

ដើម្បីបង្កើនប្រសិទ្ធិភាព និងភាពស័ក្តសិទ្ធភាព នៃការគ្រប់គ្រងនិងការត្រួតពិនិត្យតាមដាន ការអនុវត្តចំណាយថវិកាតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់ថវិកាកម្មវិធី ប្រព្រឹត្តទៅដោយរលូនប្រកប ដោយតម្លាភាព, គណនេយ្យភាព, ការសន្សំសំចៃ និងការឆ្លើយតាមតម្រូវការទាន់ពេលវេលាទៅ តាមកម្មវិធី , អនុកម្មវិធី និងចង្កោមសកម្មភាព ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមធ្វើការណែនាំនូវ និតិវិធីស្តីពីការបង្កើតតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានសម្រាប់ថវិកាកម្មវិធីដូចតទៅ ៖

- **រដ្ឋទេយ្យបុរេប្រទាន**

**រដ្ឋទេយ្យករបុរេប្រទាន** ៖ គឺជាអ្នកទទួលខុសត្រូវផ្ទាល់ និងជាប្រាក់កាសនូវការរក្សាមូលនិធិ ដែលខ្លួនទទួលបាន ឬមូលនិធិទាំងឡាយណាដែលបានបុរេប្រទានពីរតនាគារ រក្សាទុកលិខិតយុត្តិ ការ ព្រមទាំងកាន់កាប់គណនេយ្យប្រតិបត្តិការ ។ រដ្ឋទេយ្យករបុរេប្រទានស្ថិតនៅក្រោមការត្រួត ពិនិត្យរបស់អាណាប័ករបស់ខ្លួន ឬប្រធានអង្គភាពថវិកា ដែលជាអាណាប័កផ្ទេរសិទ្ធិ និងគណ នេយ្យករសាធារណៈ ហើយត្រូវទទួលខុសត្រូវផ្ទាល់ខ្លួនផ្នែករដ្ឋបាល ផ្នែករដ្ឋប្បវេណី និងផ្នែកព្រហ្ម ទណ្ឌ។ រដ្ឋទេយ្យបុរេប្រទាន គឺជាចំណាយលើដំណើរការរដ្ឋបាលដែលមានលក្ខណៈជាប្រចាំបន្ទាន់មានចំនួនទឹកប្រាក់តិច និងមិនរងចាំការបោះផ្សាយអាណត្តិបើកប្រាក់តាមនីតិវិធីធម្មតាបាន ។ មុខ សញ្ញាចំណាយតាមរដ្ឋទេយ្យបុរេប្រទានរួមមាន ៖

- ចំណាយចាំបាច់ជាប្រចាំសម្រាប់ការងាររដ្ឋបាល រួមមានជាអាទិ៍ ការទិញសម្ភារៈតិចតួច និងការជួសជុលតូចតាច
- ចំណាយសម្រាប់សង្គ្រោះជាបន្ទាន់និងពិសេស
- ចំណាយសម្រាប់ប្រាក់បេសសកម្មនៅក្នុង និងក្រៅប្រទេស
- ចំណាយសម្រាប់លាភការរបស់បុគ្គលិក ។

- **ការបង្កើតរជ្ជទេយ្យបុរេប្រទាន និងការតែងតាំងរជ្ជទេយ្យបុរេប្រទាន**

ការតែងតាំងរជ្ជទេយ្យករបុរេប្រទាន អនុលោមតាមប្រការ៩ និង ១០នៃប្រកាសលេខ១៩៣៧ សហវ.ប្រកចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤[9] ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។ ប្រកាសអន្តរ ក្រសួងឬ ដីកាស្តីពីការតែងតាំងរជ្ជទេយ្យករបុរេប្រទានត្រូវផ្ញើជូនគណនេយ្យករសាធារណៈ និងអភិបាលហិរញ្ញវត្ថុ ។

កិច្ចដំណើរការអនុវត្ត និងការគ្រប់គ្រងចំណាយតាមរជ្ជទេយ្យបុរេប្រទានត្រូវអនុ-លោមតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន ។

- **រជ្ជទេយ្យបុរេប្រទានរង**

រជ្ជទេយ្យបុរេប្រទានរង ៖ គឺអ្នកទទួលខុសត្រូវ និងជាជំនួយការរបស់រជ្ជទេយ្យតាមរយៈការចាំបាច់រជ្ជទេយ្យបុរេប្រទានរងត្រូវបានបង្កើតឡើងដោយប្រកាសដូចគ្នាទៅនិងរជ្ជទេយ្យបុរេប្រទានដែលត្រូវបានតែងតាំងដោយប្រកាសរបស់អន្តរក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងស្ថាប័នសាមី តាមរយៈអគ្គនាយកដ្ឋានរតនាគារជាតិ។ ចំពោះមន្ទីរជំនាញរាជធានី ខេត្តនៃក្រសួងស្ថាប័នដែលអនុវត្តថវិកាមិនមែនកម្មវិធី រជ្ជទេយ្យករបុរេប្រទាន និងរជ្ជទេយ្យករបុរេប្រទានរង ត្រូវបានតែងតាំងដោយដីការបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត តាមរយៈមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុនិងរតនាគាររាជធានី ខេត្ត ។

- **ការទទួលខុសត្រូវ និងតួនាទីរបស់រជ្ជទេយ្យបុរេប្រទាន**

អនុលោមតាមមាត្រា ២៥ នៃអនុក្រឹត្យលេខ ៨២អនក្រ.បកចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥[10] រជ្ជទេយ្យករបុរេប្រទានរងត្រូវទទួលខុសត្រូវផ្ទាល់ខ្លួនផ្នែករដ្ឋបាល ផ្នែករដ្ឋប្បវេណី ផ្នែក-ព្រហ្មទណ្ឌ និងជាប្រាក់កាសចំពោះទុកដាក់រក្សានូវមូលនិធិ ដែលខ្លួនបានទទួលបានចំណាយ និងការរក្សាទុកដាក់ថែរក្សាលិខិតយុត្តិការ ព្រមទាំងការកាន់កាប់បញ្ជីគណនេយ្យនៃកិច្ចប្រតិបត្តិការ ។

រាល់ដំណើរនៃការការដកសាច់ប្រាក់ រជ្ជទេយ្យបុរេប្រទាននៅជុំបង្វិលដំបូងរជ្ជទេយ្យករបុរេប្រទាន អាចស្នើសុំដកប្រាក់រជ្ជទេយ្យបុរេប្រទានស្មើ ឬតិចជាងចំនួនទឹកប្រាក់បង្វិល តាមរយៈប័ណ្ណដកឥណទានដែលមានចុះហត្ថលេខា ត្រឹមត្រូវ ដោយពុំចាំបាច់បញ្ជាក់អំពីមុខសញ្ញាចំណាយ ពុំចាំបាច់ទទួលទិដ្ឋាការរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ឬទទួលការបញ្ជាពីអាណាប័កណាឡើយ ។

[9]ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ប្រកាសស្តីពីការបង្កើតរជ្ជទេយ្យបុរេប្រទាន និងរជ្ជទេយ្យបុរេប្រទានរងប្រចាំឆ្នាំ២០១៥
[10]ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, សារាចរស្តីពីការបង្កើតរជ្ជទេយ្យបុរេប្រទានប្រចាំឆ្នាំ២០១៥

ប៉ុន្តែចំពោះការចំណាយរបស់រជ្ជទេយ្យបុរេប្រទាន ជាគោលការណ៍ រជ្ជទេយ្យបុរេ-ប្រទានត្រូវចំណាយជាសាច់ប្រាក់ដោយមានសក្ខីប័ត្របញ្ជាក់ ត្រឹមត្រូវ ។មុននឹងធ្វើការចំណាយជាសាច់ប្រាក់ រជ្ជទេយ្យករបុរេប្រទានត្រូវបានស្នើសុំគោលការណ៍ ចំណាយរជ្ជទេយ្យករបុរេប្រទានត្រូវអនុវត្តការទូទាត់ចំណាយ ដោយតម្រូវឱ្យអ្នកទទួលប្រាក់ចុះ ហត្ថលេខាបញ្ជាក់អំពីការបានទទួលគ្រប់ចំនួនលើសក្ខីប័ត្រ ។

រាល់ប័ណ្ណចំណាយ ត្រូវភ្ជាប់មកជាមួយនូវគោលការណ៍ចំណាយវិក្កយបត្រ ឬសក្ខីបត្រចំណាយដែលរជ្ជទេយ្យករបុរេប្រទានបានធ្វើការទូទាត់ ដោយមានការបញ្ជាក់ទទួលស្គាល់ពីអាណាប័ក ឬពីអ្នកដែលទទួលបានការផ្ទេរសិទ្ធពីអាណាប័ក ។

អនុញ្ញាតឱ្យរជ្ជទេយ្យករបុរេប្រទានយក វិក្កយបត្រ ឬសក្ខីបត្រចំណាយដែលបានចុះកាល បរិច្ឆេទរយៈពេលយូរ ៣០ថ្ងៃ មុនពេលមានសាច់ប្រាក់ក្នុងបេឡារជ្ជទេយ្យបុរេប្រទាន មកធ្វើជា លិខិតយុត្តិការចំណាយដើម្បីបោះផ្សាយអាណត្តិនិយ័តកម្ម ប៉ុន្តែប័ណ្ណចំណាយបានចុះកាលបរិច្ឆេទ នៅពេលក្រោយពេលបានបំពេញបេឡាសាច់ប្រាក់រជ្ជទេយ្យបុរេប្រទាន ។ ក្នុងករណីវិក័យ-បត្រ ឬ សក្ខីបត្រចំណាយបានចុះកាលបរិច្ឆេទ លើសពី ៣០ថ្ងៃ មុនពេលមានសាច់ប្រាក់ក្នុងបេឡាររជ្ជទេយ្យបុរេប្រទានត្រូវរាយការណ៍ជូនអាណាប័ក ឬអាណាប័កផ្ទេរសិទ្ធិ ដើម្បីស្នើសុំគោលការណ៍ដោយឡែកពីអភិបាលហិរញ្ញវត្ថុ និងគណនេយ្យករសាធារណៈ ។ ចំនួនទឹកប្រាក់សម្រាប់មួយប័ណ្ណចំណាយ ត្រូវបានកំណត់ដូចខាងក្រោម ៖

១,៥០០,០០០(មួយលានប្រាំរយពាន់)រៀលជាអតិបរមាសម្រាប់ថវិកាមិនមែនកម្មវិធីលើកលែងតែចំណាយពិសេសរបស់រាជរដ្ឋាភិបាលនិងចំណាយដែលមានរបបកំណត់ច្បាស់លាស់ដែលត្រូវទូទាត់តាមការចំណាយជាក់ស្តែង ដោយមិនកំណត់ចំនួនទឹកប្រាក់ក្នុងមួយប័ណ្ណចំណាយ ។

៥,០០០,០០០ (ប្រាំលាន) រៀលជាអតិបរមា សម្រាប់ថវិកាកម្មវិធី លើកលែងតែចំណាយ ពិសេសរបស់រាជរដ្ឋាភិបាលចំណាយលើប្រាក់បេសសកម្មក្នុង និងក្រៅប្រទេស ចំណាយរៀបចំវគ្គ បណ្តុះបណ្តាលនិងសិក្ខាសាលា និងចំណាយដែលមានរបបកំណត់ច្បាស់លាស់ ដែលត្រូវទូទាត់ តាមការចំណាយជាក់ស្តែង ដោយមិនកំណត់ចំនួនទឹកប្រាក់ក្នុងមួយប័ណ្ណចំណាយ ។

រជ្ជទេយ្យករបុរេប្រទាន ឬរជ្ជទេយ្យករបុរេប្រទាន ត្រូវជៀសវាងដាច់ខាតនូវការបំបែកប័ណ្ណចំណាយទៅតាមទីកន្លែង ឬគោលដៅចំណាយ ពេលវេលា ទឹកប្រាក់ចំណាយ និងសមាសធាតុ នៃមុខសញ្ញាចំណាយ ក្នុងគោលបំណងគេចវេសការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ ។ ប្រសិនបើ អាណាប័ក ពិនិត្យឃើញថាលិខិតយុត្តិការចំណាយត្រឹមត្រូវហើយ អាណាប័កត្រូវបោះ

ផ្សាយ អាណត្តិនិយ័តកម្ម ដើម្បីទូទាត់ចំណាយរដ្ឋទេយ្យបុរេប្រទាន រួចផ្ញើទៅអភិបាលហិរញ្ញវត្ថុ ដើម្បីផ្តល់ទិដ្ឋាការ ។ ប៉ុន្តែក្នុងករណីដែលអាណាប័ក ពិនិត្យឃើញថា លិខិតយុត្តិការចំណាយមួយចំនួនពុំ មានលក្ខណៈត្រឹមត្រូវទេ អាណាប័កត្រូវបញ្ជូនលិខិតយុត្តិការចំណាយនោះ ទៅរដ្ឋទេយ្យករបុរេ ប្រទានវិញ ដើម្បីធ្វើការកែតម្រូវ ។

នាពេលដំណាច់ឆ្នាំ ក្នុងករណីមានប្រាក់រដ្ឋទេយ្យបុរេប្រទាននៅសល់ រដ្ឋទេយ្យករបុរេប្រទាននៅសល់ រដ្ឋទេយ្យករបុរេប្រទានត្រូវយកប្រាក់ដែលនៅសល់នោះ មកបង់ជូនគណនេយ្យករសាធារណៈវិញ ដើម្បីចុះកិច្ចបញ្ជិកាជម្រះបញ្ជី យ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំថវិកាដើម្បីទូទាត់ ជម្រះបញ្ជីរដ្ឋទេយ្យបុរេប្រទានឱ្យបានទាន់ក្នុងឆ្នាំថវិកា ។

## ១.៥.២.៤ ភ្នាក់ងារបើកផ្តល់ និងភ្នាក់ងារបើកផ្តល់ជំនួស

ភ្នាក់ងារបើកផ្តល់ ត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីរាជការ ដែលមានលក្ខណៈសម្បត្តិល្អ និងមានការយល់ដឹងច្បាស់លាស់អំពីកិច្ចបញ្ជិកាគណនេយ្យ ដែលអាចគ្រប់គ្រងលើការបើក ប្រាក់បៀវត្ស និងប្រាក់អន្តរគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ជូនមន្ត្រីរាជការ ។

មន្ត្រីបើកផ្តល់ ជាអ្នកអនុវត្តចំណាយ ដែលបានកំណត់ដោយប្រកាស នៅក្រោមលក្ខខណ្ឌដូចគ្នាដូចបានចែង ដូចដែលបានចែងសម្រាប់ គណនេយ្យករសាធារណៈមន្ត្រីបើកផ្តល់ត្រូវធ្វើការទូទាត់ចំណាយដោយការផ្ទេរប្រាក់ ឬមូលប្បទានប័ត្រទៅចូលគណនីរបស់មន្ត្រីរាជការនៅតែនាគារឬជាសាច់ប្រាក់សុទ្ធ ។ ជារឿយៗមន្ត្រីបើកផ្តល់ដាក់ជូនគណនេយ្យករ នូវសក្ខីប័ត្រដើម្បីទូទាត់ចំណាយផ្សេងៗក្នុងគោលដៅបំពេញបុរេប្រទាននេះឡើងវិញ ព្រមទាំងដើម្បីទូទាត់ចំណាយ និងរាយការណ៍ជូនអាណាប័ក ក្នុងរយៈពេលយ៉ាងយូរបំផុត មួយខែរាប់ចាប់ពីថ្ងៃទូទាត់លើចំណាយ ។

*តារាងទី៤៖ កិច្ចដំណើរការនៃការអនុវត្តរបស់ភ្នាក់ងារបើកផ្តល់*



ទាំងនេះគឺជាកិច្ចដំណើរការនៃការអនុវត្ត និងការទទួលខុសត្រូវរបស់ភ្នាក់ងារបើកផ្តល់ ៖

1. ត្រូវរងចាំអាណិត្តបៀវត្សមន្ត្រីរាជការពីក្រសួងមុខងារ និងសាធារណៈ

2. បន្ទាប់ពីទទួលបានអាណិត្តមុខងារពីក្រសួងមុខងារ ត្រូវយកអាណិត្តមុខងារមកភ្ជាប់ជាមួយអាណត្តិបើកប្រាក់ (ក្នុងការរៀបចំអាណិត្តបើកប្រាក់ត្រូវមាន អាណិត្តមុខងារ, អាណិត្តបើកប្រាក់, សាកលប័ត្រ,ដីកាបញ្ជូន, ដីកាអមលិខិតយុត្តិការ, កំណត់បង្ហាញ, លិខិតទៅឯកឧត្តមទេសរដ្ឋមន្ត្រី, តារាងចំណាយលម្អិត, ដីកាបញ្ចេញអាណិត្ត ។

3. ត្រូវឱ្យប្រធានអង្គភាពជាអ្នកស៊ីញ៉េត្រង់ចំណុច (អាណាប័ក) ។

4. បន្ទាប់ពីដំណើរការនៃការស៊ីញ៉េរួចហើយត្រូវបញ្ជូនឯកសារទៅកុងកឺឡឺ ឬមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុដើម្បីត្រួតពិនិត្យ។

5. បន្ទាប់ពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុត្រួតពិនិត្យរួចរាល់ មន្ត្រីត្រួតពិនិត្យទាំងនោះត្រូវស៊ីញ៉េលើអាណិត្តនោះ ដែលបញ្ជាក់ថាបានត្រួតពិនិត្យរួចរាល់។

6. បន្ទាប់មកត្រូវបញ្ជូនឯកសារទាំងនោះទៅការិយាល័យហិរញ្ញកិច្ច ដើម្បីឱ្យខាងការិយាល័យហិរញ្ញកិច្ចបញ្ចូលឯកសារទាំងនោះចូលក្នុងប្រព័ន្ធ FTMS (ប្រព័ន្ធត្រួតពិនិត្យហិរញ្ញវត្ថុ)។

7. បន្ទាប់ពីខាងការិយាល័យហិរញ្ញកិច្ចបញ្ចូលរួចរាល់ហើយ ការិយាល័យហិរញ្ញិកិច្ចជាអ្នកវាយតួលេខបៀវត្សទៅលើប្រព័ន្ធដើម្បីទូទាត់ ។

8. បន្ទាប់ពីបញ្ចូលនិងទូទាត់រួចរាល់ហើយ គេនិងមានលេខដាក់បញ្ជាក់នៅលើអាណិត្ត ដែលបញ្ជាក់ថាប្រាក់បៀវត្សបានចូលរួចរាល់ហើយ ។

9. ក្រោយពីបានចារលេខនៅលើអាណិត្តរួចរាល់ឯកសារទាំងនោះ ត្រូវបញ្ជូនទៅកាន់ប្រធានការិយាល័យហិរញ្ញកិច្ចដែលជាអ្នកសម្រេចចុងក្រោយ ។

10. បន្ទាប់មកត្រូវបញ្ចូលប្រាក់ ទៅរតនាគារជាតិដោយភ្ជាប់មកជាមួយលិខិតបង្វែរបៀវត្សទៅចូលកុងធនាគារអេស៊ីលីដា

11. បន្ទាប់មករតនាគារជាតិ និងចេញជាសែកដែលមានបញ្ជាក់ថាកាត់ពន្ធបៀវត្សរួចជាស្រេចដើម្បីឱ្យមន្ត្រីបើកផ្តល់បញ្ជូនឯកសារទៅកាន់ធនាគារជាតិ ហើយធនាគារជាតិនិងដាក់បន្តឱ្យទៅធនាគារអេស៊ីលីដា ។

12. នៅចុងបញ្ចប់ បន្ទាប់ពីសែកបញ្ជូនទៅដល់ធនាគារអេស៊ីលីដាហើយ ខាងភ្នាក់ងារបើកផ្តល់និងមានលិខិតមួយទៅកាន់ធនាគារអេស៊ីលីដា ដើម្បីឱ្យធនាគារអេស៊ីលីដាបង្វែរសាច់ប្រាក់ចូលក្នុងកុងធនាគារមន្ត្រីនីមួយៗ ។ ( ក្នុងករណីដែលមានមន្ត្រីរាជការណាម្នាក់មិនបានទទួល ភ្នាក់ងារបើកផ្តល់ត្រូវតែធ្វើការសាកសួរទៅកាន់ធនាគារថាហេតុអ្វីបានជាប្រាក់ខែមិនបានចូលក្នុងកុងធនាគារមន្ត្រីម្នាក់នោះ ។

## ១.៦ ការរៀបចំសំណើរសុំចំណាយ និងការទូទាត់ចំណាយ

### ១.៦.១ដំណើរការនៃការស្នើសុំចំណាយ

បន្ទាប់ពីឥណទានចំណាយត្រូវបានអនុម័តដោយច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ និងត្រូវបានវិភាជន៍លម្អិត ស្ថិតក្រោមឱវាទនៃក្រសួង ស្ថាប័នអាចចាប់ផ្តើមរៀបចំសំណើរសុំចំណាយថវិកាស្របតាមសៀវភៅ វិភាជន៍ថវិកា គម្រោងចំណាយក្នុងពេលរៀបចំថវិកា ស្របតាមផែនការលទ្ធកម្មសាធារណៈ តាមសកម្ម ភាពថវិកាកម្មវិធី និងតាមតម្រូវការចាំបាច់ក្នុងការចំណាយ ។

ជាទូទៅដំណើរការស្នើសុំគោលការណ៍ធានាចំណាយត្រូវចាប់ផ្តើមឡើងពីអង្គភាពថវិកា ដែលជាប្រតិបត្តិករកម្មវិធី អនុកម្មវិធី ឬសកម្មភាពនៃក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ។ រយៈពេលនៃការអនុវត្តចំណាយ ចាប់ពីដំណាក់កាលស្នើសុំគោលការណ៍ រហូតដល់ការប្រគល់ទទួលទំនិញ សំណង់ ឬសេវា ត្រូវការពេលវេលាច្រើនខែ ។ ដូច្នេះក្រសួង ស្ថាប័ន និងអង្គភាពថវិកាត្រូវរូតរះលើក សំណើសុំគោលការណ៍ចំណាយជាមុនដើម្បីទទួលបានទំនិញ សំណាងឬសេវាប្រើប្រាស់ទាន់ពេល វេលា ។ ការលើកសំណើសុំគោលការណ៍ចំណាយនេះ ត្រូវអនុលោមតាមគោលចំនុចសំខាន់បួន គឺ (១) ឥណទានស្នើសុំស្របតាមតម្រូវការបរិមាណ គុណភាពតម្លៃ និងយថាប្រភេទនៃទំនិញ សំណង់ ឬសេវាជាក់ស្តែង (២) កម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងលទ្ធផលរំពឹងទុក (៣) ខ្ទង់មាតិកាថវិកា ចំណាយនិង (៤) ពេលវេលាសម្រាប់អនុវត្តការងារ ឬគម្រោង ។

អង្គភាពថវិកាត្រូវលើកសំណើសុំគោលការណ៍ចំណាយថវិកាទៅរដ្ឋមន្ត្រី ប្រធានស្ថាប័ន និងមន្ទីរជំនាញ រាជធានី ខេត្ត ដែលជាអាណាប័កដើមខ្សែ ឬអាណាប័កផ្ទេរសិទ្ធិ តាមរយៈអង្គភាពទទួលបន្ទុក ហិរញ្ញវត្ថុនៃក្រសួង ស្ថាប័នរបស់ខ្លួនអំពីតម្រូវការទំនិញ សំណង់ ឬសេវាផ្សេងៗសម្រាប់ប្រើប្រាស់ក្នុង អង្គភាពថវិការបស់ខ្លួន (គំនូសតាងទី ២ និងទី ៣)

ចំពោះអង្គភាពថវិកា ជាមន្ទីរជំនាញ ដែលជាខ្សែបណ្តោយរបស់ក្រសួងស្ថាប័ននៅតាមរាជធានី ខេត្តត្រូវដាក់សំណើទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានីខេត្ត តាមរយៈការិយាល័យគណនេយ្យ នៃមន្ទីរជំនាញរបស់ខ្លួន (គំនូសតាងទី ៤) ។

### ការរៀបចំ និងការអនុវត្តកម្មវិធីចំណូល ចំណាយ

ដើម្បីឱ្យការអនុវត្តថវិកាប្រកបដោយភាពជឿទុកចិត្តបាន និងប្រព្រឹត្តទៅដោយរលូនជាពិសេសដើម្បីធានាការឆ្លើយតបទៅនឹងតម្រូវការសាច់ប្រាក់បានទាន់ពេលវេលាគ្រប់ក្រសួង ស្ថាប័ន និងមន្ទីរ ជំនាញរាជធានី ខេត្តទាំងអស់ ត្រូវពង្រឹងភាពជាម្ចាស់ក្នុងការរៀបចំកម្មវិធីចំណូលចំណាយប្រចាំត្រី មាសសម្រាប់រយៈពេលពេញ ១ ឆ្នាំដែលមានបែងចែកលម្អិតទៅតាមខែ និងទៅ

តាមគំរូដែលរៀបចំ ឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (តារាងឧបសម្ព័ន្ធទី ១១ដល់ទី ១៤) ដោយឈរលើមូលដ្ឋាន នៃតម្រូវការចំណាយជាក់ស្តែង (តាមប្រតិទិននៃផែនការសកម្មភាពការងារ និងផែនការលទ្ធកម្ម) និង ក្នុងក្របខ័ណ្ឌនៃឥណទានដែលត្រូវបានកំណត់ដោយ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ។ ក្រសួង ស្ថាប័នត្រូវផ្ញើកម្មវិធីចំណូល ចំណាយដែលបានរៀបចំមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា) ។ ដោយឡែកមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ ត្រូវផ្ញើកម្មវិធីចំណូល ចំណាយដែលបានរៀបចំ ទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុមួយច្បាប់ ដើម្បីឱ្យមន្ទីរ សេដ្ឋកិច្ចនិង ហិរញ្ញវត្ថុបូកសរុប រួចផ្ញើមកនាយកដ្ឋានីយកម្មនៃអគ្គនាយកដ្ឋានថវិកា និងទៅក្រសួង ស្ថាប័នដែលជាខ្សែបណ្តាយរបស់ខ្លួនមួយច្បាប់សម្រាប់ការគ្រប់គ្រង និងតាមដានការអនុវត្ត ។ ក្រោយ ពីទទួលបានកម្មវិធីចំណូល ចំណាយដែលស្នើដោយក្រសួងស្ថាប័នរាជធានី ខេត្ត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវពិនិត្យ និងវាយតម្លៃលើអាទិភាពនៃតម្រូវការ និងលទ្ធភាពចំណូលដែលអាចប្រមូលបាន ដើម្បីដាក់ចេញជាកម្មវិធីចំណូលចំណាយប្រចាំត្រីមាសទៅតាមមាតិកាថវិការសម្រាប់ការអនុវត្ត ។

ការរៀបចំចំណូល ចំណាយប្រចាំត្រីមាសឱ្យបានកាន់តែត្រឹមត្រូវ និងសុក្រឹតព្រមទាំងការ អនុវត្តឱ្យបានម៉ឺងម៉ាត់តាមកម្មវិធីចំណូល ចំណាយនេះគឺជាប្រការចាំបាច់បំផុត ។ ដូច្នេះគ្រប់ក្រសួង ស្ថាប័ន មន្ទីរជំនាញ រាជធានី ខេត្ត អគ្គនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបាន អនុវត្តឱ្យបានម៉ឺងម៉ាត់នូវអភិក្រមការងារដូចខាងក្រោម ៖

**ការរៀបចំកម្មវិធីចំណូល ចំណាយប្រចាំត្រីមាស**

- នៅរៀងរាល់ថ្ងៃទី២០នៃខែនាចុងត្រីមាសនីមួយៗ អគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោម ជាតិ ក្រសួងស្ថាប័ន និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវផ្ញើមកនាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយក ដ្ឋានថវិកា និងអគ្គនាយកដ្ឋានរតនាគារជាតិ នូវរបាយការណ៍ប៉ាន់ស្មានអនុវត្តកម្មវិធីចំណូល ចំណាយ ប្រចាំត្រីមាសកំពុងអនុវត្តដោយឆ្លុះបញ្ចាំងពីការអនុវត្តជាក់ស្តែងប្រចាំខែទី១និង ខែទី២ និងការប៉ាន់ស្មានអនុវត្តខែទី១៣ ជាមួយនិងសំណើកែសម្រួលគម្រោងថវិកាចំណូល ចំណាយប្រចាំត្រីមាសបន្ទាប់ ប្រសិនបើចាំបាច់ ។

- ដោយឡែកមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ ត្រូវផ្ញើរបាយការណ៍ប៉ាន់ស្មានអនុវត្តកម្មវិធី ចំណូល ចំណាយប្រចាំត្រីមាសកំពុងអនុវត្ត ដោយឆ្លុះបញ្ចាំងពីការអនុវត្តជាក់ស្តែងប្រចាំខែទី១ និងខែទី២ និង ការប៉ាន់ស្មានអនុវត្តប្រចាំខែទី៣ ជាមួយនិងសំណើកែសម្រួល

គម្រោងកម្មវិធីចំណូល ចំណាយប្រចាំ ត្រីមាសបន្ទាប់ប្រសិនបើចាំបាច់ ទៅមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី១៥ នៃខែនាចុងត្រី មាសនីមួយៗ ដើម្បីទុកពេលវេលាឱ្យមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុបូកសរុប រួចផ្ញើមកនាយកដ្ឋានថវិកានីយកម្ម នៃអគ្គនាយកដ្ឋានថវិកា និងអង្គភាព គ្រប់គ្រងសាច់ប្រាក់ឱ្យបានមុនថ្ងៃទី២០ នៃខែ នាចុងត្រី មាសនីមួយៗ ។

- នៅរៀងរាល់ថ្ងៃទី២៥នៃខែនាចុងត្រីមាសនីមួយៗ អគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ ត្រូវរៀបចំពិភាក្សាជាមួយអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានរតនាគារជាតិ និងអគ្គនាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បី រៀបចំកម្មវិធីចំណូល ចំណាយថវិកាថ្នាក់ជាតិសម្រាប់ត្រីមាសបន្ទាប់ ។ ផ្អែកលើមូលដ្ឋាននៃកម្មវិធី ចំណូល ចំណាយនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ( នាយកដ្ឋានថវិកានីយកម្ម នៃអគ្គនាយកដ្ឋានថវិកា) ត្រូវរៀបចំប្រកាសកម្មវិធីចំណូល ចំណាយសម្រាប់ត្រីមាសបន្ទាប់ ទៅតាមមាតិកាថវិកាក្នុង កម្រិតឥណទានអតិបរមាសម្រាប់ក្រសួង ស្ថាប័ននីមួយៗ និងមន្ទីរជំនាញរាជធានីខេត្តនីមួយៗ ដោយ ចម្លងជូននាយកដ្ឋានរតនាគារជាតិ ។

### ១.៦.២ ចំណាយបន្ទុកបុគ្គលិក

ប្រភេទចំណាយបន្ទុកបុគ្គលិក( ជំពូក ៦៤) មានដូចជា លាភការ ប្រាក់បំណាច់ រង្វាន់ផ្សេងៗ និងប្រាក់វិភាជន៍សង្គមសម្រាប់អំណាចសាធារណៈ បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍ បុគ្គលិកមិនមែនក្រប ខ័ណ្ឌ បុគ្គលិកអណ្តែតដែលមានទិដ្ឋាការពីក្រសួងមុខងារសាធារណៈ ។ ក្នុងមុខចំណាយខាងលើដែលមានគោលរបប និងគោលការណ៍កំណត់ត្រូវអនុញ្ញាតឱ្យអនុវត្តតាមនីតិវិធីចំណាយព្រម ។

ចំពោះចំណាយលើប្រាក់បៀវត្ស មុននឹងផ្តល់ទិដ្ឋាការអាណត្តិបើកប្រាក់ ឯកសារលិខិតយុត្តិការត្រូវមានទិដ្ឋាការពីក្រសួងមុខងារសាធារណៈ ។ នាយកដ្ឋានបុគ្គលិកដែលជាទូទៅដែលជាប្រត្តិបត្តិករ មួយនៃកម្មវិធី គាំទ្រទូទៅនៃក្រសួង ស្ថាប័ន មានភារកិច្ចរៀបចំបោះផ្សាយអាណត្តិបើកប្រាក់ និងចុះ ហត្ថលេខារបស់អាណាប័កដើមខ្សែ ឬអាណាប័កផ្ទេរសិទ្ធ ដើម្បីដាក់ជូនអភិបាលហិរញ្ញវត្ថុចុះទិដ្ឋាការ លើអាណត្តិបើកប្រាក់ឱ្យបានក្នុងសប្តាហ៍ទី ៣ នៃខែនីមួយៗ )

នីតិវិធីណែនាំលម្អិតសម្រាប់ការបើកបៀវត្ស មានចែងក្នុងសារាចររបស់រាជរដ្ឋាភិបាលលេខ ០១សរ ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៤ ស្តីពីការកំណត់នីតិវិធីសម្រាប់ការបើកផ្តល់បៀវត្សសម្រាប់មន្ត្រីស៊ីវិល ។

ក្នុងករណី ចំពោះចំណាយបន្ទុកបុគ្គលិក ដូចជា លាភការ ប្រាក់បំណាច់ រង្វាន់ផ្សេងៗ និង ប្រាក់វិភាជន៍សង្គមសម្រាប់អំណាចសាធារណៈ បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍ បុគ្គលិកមិនមែនក្រប

ខណ្ឌ និងបុគ្គលិកបណ្ដែត ដែលមិនមានគោលការណ៍កំណត់ជាមុន គឺតម្រូវឱ្យមានការស្នើសុំគោលការណ៍ និងធានាចំណាយជាមុនសិន ។

**១.៦.៣ ចំណាយក្រៅបន្ទុកបុគ្គលិក**

ចំណាយក្រៅបន្ទុកបុគ្គលិកផ្សេងៗទៀត ជាប្រភេទចំណាយមានគោលការណ៍ច្បាស់លាស់ដូចជា ៖

- ទូទាត់ចំណាយការប្រើប្រាស់ទឹក និងអគ្គីសនី ដែលផ្គត់ផ្គង់ដោយអាជ្ញាធរស្វយ័តរដ្ឋាករទឹក និងអគ្គិសនីកម្ពុជាដែលមានវិក័យបត្រផ្លូវការ
- ទូទាត់ចំណាយការប្រើប្រាស់ទូរស័ព្ទ ទូរសារនិងថ្លៃសេវាបញ្ញើប្រៃសណីយ៍ និងហិបការទូត ដែលផ្ដល់សេវាពីរដ្ឋ
- ចំណាយបង់ពន្ធ ( ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានយន្តរបស់រដ្ឋ )
- ចំណាយលើការបង់វិភាគទានឱ្យអង្គការអន្តរជាតិ ដែលមានការសម្រេចពីរាជរដ្ឋាភិបាល
- ចំណាយសម្រាប់បណ្ដាស្ថានទូត និងស្ថានអគ្គកុងស៊ុលដែលនៅក្រៅប្រទេសនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដូចជាចំណាយថ្លៃឈ្នួលស្ថានទូត និងផ្ទះមន្ត្រីការទូត និងចំណាយដំណើរការទូទៅរបស់ស្ថានទូត និងស្ថានអគ្គកុងស៊ុល
- ទូទាត់សោហ៊ុយចំណាយបេសសកម្មទៅក្រៅប្រទេស ( បណ្ដាប្រទេសអាស៊ាន )
- ចំណាយផ្សេងៗទៀតដែលមានគោលរបបច្បាស់លាស់ ។
- ប្រភេទចំណាយខាងលើដែលមានវិក័យបត្ររួម និងមានចរិតចំណាយរ៉ាប់រងសម្រាប់ អង្គភាពថវិកាច្រើន អង្គភាពទទួលបន្ទុកហិរញ្ញត្រូវរៀបចំឯកសារលិខិតយុត្តិការ និងការបោះផ្សាយអាណត្តិបើកប្រាក់ ស្នើចុះទិដ្ឋាការពីអភិបាលហិរញ្ញវត្ថុ ។ ដោយឡែកចំណាយណាដែលជាបន្ទុកផ្ទាល់របស់អង្គភាពថវិកានោះ អង្គភាពថវិកាត្រូវរៀបចំលិខិតស្នើសុំទៅអាណាប័កតាមរយៈអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុដើម្បីទូទាត់ ។ បែបបទនីតិវិធីលម្អិតសម្រាប់មុខចំណាយខាងលើ ក្រសួង ស្ថាប័ន ត្រូវអនុវត្តតាមសៀវភៅគោលការណ៍ណែនាំស្ដីពីនិតីវិធីចំណាយនិងបែបបទ ត្រួតពិនិត្យហិរញ្ញវត្ថុសម្រាប់ថវិកាចរន្តថ្នាក់ជាតិ ដែលប្រកាសដាក់ឱ្យអនុវត្តដោយប្រកាសលេខ៥៨០ សហវប្រក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៣ លើកលែងតែក្នុងករណីមានបទដ្ឋានគតិយុត្ត ឬបទប្បញ្ញត្តិកំណត់ដោយឡែក ។

ក្នុងករណីចំពោះចំណាយបន្ទុកបុគ្គលិកផ្សេងទៀត ចំពោះពាក់ព័ន្ធជាមួយសេវាកម្ម (ជំពូក៦១) ចំណាយសម្រាប់អត្ថប្រយោជន៍សង្គម (ជំពូក៦២) ឧបត្ថម្ភកធន (ជំពូក៦៥) ដែលមិនតម្រូវឱ្យ អនុ

វត្ថុកិច្ចលទ្ធកម្មសាធារណៈ ប៉ុន្តែមិនមានគោលការណ៍កំណត់ច្បាស់លាស់ គឺតម្រូវឱ្យស្នើសុំ គោលការណ៍ធានាចំណាយជាមុនសិន ទើបអនុញ្ញាតទូទាត់បាន ពិសេសត្រូវអនុវត្តចំណាយដោយអនុលោមតាមខ្លឹមសារនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០០៨ ត្រង់មាត្រា ៦៤ និងអនុក្រឹត្យលេខ ៨១ អនក្រ.បកចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើកលែងតែមានបទដ្ឋានគតិយុត្ត និងបទប្បញ្ញត្តិកំណត់ដោយឡែក ។

ជាទូទៅ ដំណើរការស្នើសុំគោលការណ៍ធានាចំណាយត្រូវចាប់ផ្តើមពីអង្គភាពថវិកាដែលជាប្រត្តិបត្តិករកម្មវិធី/អនុកម្មវិធីនៃក្រសួង ស្ថាប័ន ។

អង្គភាពថវិកាត្រូវលើកសំណើសុំគោលការណ៍ចំណាយថវិកាទៅរដ្ឋមន្ត្រី ឬប្រធាន ស្ថាប័នដែលជាអាណាប័កដើមខ្សែ តាមរយៈអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុរបស់ខ្លួន អំពីតម្រូវការចំណាយសម្រាប់ប្រើប្រាស់ក្នុងអង្គភាពថវិការបស់ខ្លួនតាមមាតិកាសេដ្ឋកិច្ច និងតាមកម្មវិធី/អនុកម្មវិធី/ចង្កោមសកម្មភាព ។

ចំពោះអង្គភាពថវិកា ជាមន្ទីរជំនាញរាជធានី ខេត្ត ដែលជាខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ននៅតាមរាជធានី ខេត្ត ត្រូវដាក់សំណើទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលជាអភិបាល ហិរញ្ញវត្ថុដើម្បីពិនិត្យ និងចុះទិដ្ឋាការ ។

ចំពោះមន្ទីរជំនាញដែលមានអង្គភាពក្រោមឱវាទច្រើន អង្គភាពនីមួយៗត្រូវដាក់សំណើទៅប្រធានមន្ទីរជំនាញរបស់ខ្លួនតាមរយៈអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុដើម្បីបូកសរុប និងរៀបចំសំណើរួមដាក់ជូនអភិបាលហិរញ្ញវត្ថុពិនិត្យ និងចុះទិដ្ឋាការ ។

សំណើសុំគោលការណ៍ធានាចំណាយអាចលើកសម្រាប់មួយករណីៗ ឬប្រមូលផ្តុំចំណាយតាមសកម្មភាពការងារ ។ លិខិតស្នើសុំគោលការណ៍ចំណាយថវិកាត្រូវភ្ជាប់មកជាមួយនូវគម្រោងចំណាយដែលមានបញ្ជាក់ពីតម្រូវការចំណាយ ប្រភេទចំណាយតាមមាតិកា តាមកម្មវិធី/អនុកម្មវិធី និងពេលវេលានៃការអនុវត្តសកម្មភាពឬគម្រោង និងត្រូវផ្អែកលើសៀវភៅថវិកាដែលបានវិភាជន៍តាមមាតិកាសេដ្ឋកិច្ច និងតាមកម្មវិធី/អនុកម្មវិធី/ចង្កោមសកម្មភាព ។

បន្ទាប់ពីទទួលបានទិដ្ឋាការធានាចំណាយ និង/ឬក្រោយពីប្រតិបត្តិការចំណាយ (ចំពោះចំណាយមួយចំនួន) អង្គភាពថវិកាត្រូវប្រមូលឯកសារលិខិតយុត្តិការទាំងអស់រួមទាំងរបាយការណ៍ចំណាយប្រគល់ឱ្យអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុដើម្បីពិនិត្យ (និងបូកសរុបក្នុងករណីមានអង្គភាពថវិកាច្រើន) និងរៀបចំបោះផ្សាយអាណត្តិបើកប្រាក់ទូទាត់ ។ចំណាយទាំងឡាយត្រូវធ្វើស្របតាមគោលការណ៍ និងបទដ្ឋានដែលមានជាធរមាន ។

ក្នុងករណីប្រធានមន្ទីរជំនាញ ដែលជាអាណាប័កផ្ទេរសិទ្ធពិនិត្យឃើញថា លិខិតយុត្តិការទាំងនោះត្រឹមត្រូវហើយ អាណាប័កត្រូវចុះហត្ថលេខាលើអាណត្តិត្រូវចុះហត្ថលេខាលើអាណត្តិបើកប្រាក់ ឬអាណត្តិនិយ័តកម្មរួចផ្ញើទៅអភិបាលហិរញ្ញវត្ថុដើម្បីផ្តល់ទិដ្ឋាការលើអាណត្តិ ។

## ១.៧ ការកត់ត្រាសន្និធិឥណទាន

ក្នុងការអនុវត្តថវិកាកម្មវិធី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានគិតគូរៀបចំអនុវត្តនៅក្នុងទិសកែទម្រង់ជាក់លាក់ណាមួយដើម្បីធានាឱ្យការរៀបចំការអនុវត្ត និងការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ ការអនុវត្តថវិកាតាមបរិបទថ្មីកាន់តែប្រសើរជាងមុន យ៉ាងណាមិញចំពោះការកត់ត្រា សន្និធិរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសុទ្ធតែមានគោលការណ៍, ប្រព័ន្ធគ្រប់គ្រង ទិន្នន័យយ៉ាង ជាក់លាក់ដើម្បីបង្កើតប្រសិទ្ធភាពនៃការប្រើប្រាស់ឥណទាន អង្គភាពថវិកានីមួយៗមានតួនាទីដូច ខាងក្រោម ៖

- ធ្វើបច្ចុប្បន្នភាពសន្និធិឥណទាន តាមរយៈចង្កោមសកម្មភាពដែលស្ថិតនៅក្រោមកម្មវិធី និងអនុកម្មវិធីនីមួយៗ
- ការកត់ត្រាសន្និធិឥណទានតាមរយៈ ការកត់ត្រាតាមមាតិកាសេដ្ឋកិច្ច
- ការតាមដានស្ថានភាពនៃការធានាចំណាយ អាណត្តិបោះផ្សាយ និងការបើកសាច់ប្រាក់ពីរតនាគារ
- រៀបចំរបាយការណ៍បានទាន់ពេលវេលា និងត្រឹមត្រូវជនអាណាប័ក និងអគ្គនាយកដ្ឋាន ថវិកា
- ពង្រឹងប្រសិទ្ធភាព និងសិក្តិសិទ្ធភាពនៃការប្រើប្រាស់ឥណទានរបស់អង្គភាពថវិកាបានទាន់ពេលវេលាក្នុងឆ្នាំសារពើពន្ធនីមួយៗ ។
- ជម្រុញការយកចិត្តទុកដាក់លើចលនាឥណទាន និងការប្រើប្រាស់សន្និធិឥណទានដែលសល់ក្នុងឆ្នាំឱ្យមានប្រសិទ្ធភាពលើការបង្កើតលទ្ធផលជាក់ស្តែង ដែលអាចវាស់វែងបានក្រោមអនុកម្មវិធី និងគោលនយោបាយរបស់ក្រសួង ។

## ១.៨ ការធ្វើចលនាឥណទាន[11]

### ១.៨.១ ការស្នើសុំធ្វើនិយ័តកម្មឥណទាន

ក្នុងគោលការណ៍ណែនាំស្តីពីនីតិវិធីការអនុវត្តថវិកាកម្មវិធី មិនអនុញ្ញាតឱ្យអនុវត្តចំណាយលើសពីឥណទានដែលបានបែងចែកនិងវិភាជន៍សម្រាប់កម្មវិធីនីមួយៗឡើយ លើកលែងតែមានតម្រូវការផ្ទេរឥណទាន ឬនិយ័តកម្មដែលត្រូវបានអនុវត្តតាមនីតិវិធីដែលមានជាធរមាន ។

ការធ្វើចលនាឥណទាន ៖ ក្នុងពេលអនុវត្តជាក់ស្តែង តម្រូវការថវិកាមិនអាចមានការប្រែប្រួលតាមអាទិភាពនៃការងារ និងពេលវេលាទេជាហេតុតម្រូវឱ្យមានភាពចាំបាច់ ត្រូវផ្ទេរឥណទានពីចង្កោមសកម្មភាពមួយទៅចង្កោមសកម្មភាពមួយទៀត និងពីខ្ទង់ចំណាយមួយទៅខ្ទង់ចំណាយមួយទៀត ដើម្បីបំពេញតម្រូវការជាក់ស្តែង ។ ចំពោះការធ្វើចលនាឥណទាននេះ អង្គភាពថវិកានីមួយៗ តម្រូវឱ្យធ្វើចលនាឥណទាននៅក្នុងអង្គភាពនីមួយៗ នៅដើមត្រីមាសទី២ នៃឆ្នាំអនុវត្តថវិកាគឺមានន័យថា ត្រូវធ្វើនៅក្រោយពេលត្រីមាសទី ១ ត្រូវបានបញ្ចប់សព្វគ្រប់ ។

#### ១.៨.១.១ និយ័តកម្មឥណទានថវិកាសម្រាប់រដ្ឋបាលថ្នាក់កណ្តាល

និយ័តកម្មអនុគណនី ឬគណនីតែមួយនៅក្នុងជំពូកតែមួយ ឆ្លងពីចង្កោមសកម្មភាពមួយទៅចង្កោមសកម្មភាពមួយទៀត នៃអនុគណនីតែមួយ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើររបស់អគ្គលេខាធិការដ្ឋាន និងត្រូវចម្លងជូនអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានរតនាគារជាតិ ។

និយ័តកម្មផ្ទៃក្នុងក្នុងគណនីតែមួយ នៅក្នុងជំពូកតែមួយ ចង្កោមសកម្មភាពតែមួយ ឬឆ្លងពីចង្កោមសកម្មភាពមួយទៅចង្កោមសកម្មភាពមួយទៀត នៃអនុកម្មវិធីតែមួយត្រូវកំណត់ប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់អគ្គលេខាធិការដ្ឋាន និងត្រូវចម្លងជូនអគ្គនាយកដ្ឋានរតនាគារជាតិ ។ អង្គភាពថវិកាត្រូវស្នើសុំមករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមរយៈអគ្គលេខាធិការដ្ឋាន ។

និយ័តកម្មផ្ទៃក្នុងជំពូកតែមួយ ចង្កោមសកម្មភាពតែមួយ ឬឆ្លងពីចង្កោមសកម្មភាពមួយទៅចង្កោមសកម្មភាពមួយទៀត នៃអនុគណនីតែមួយ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើររបស់អគ្គលេខាធិការដ្ឋាន និងត្រូវចម្លងជូនអគ្គនាយក

[11] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍នាំស្តីនីតិវិធីអនុវត្តថវិកាកម្មវិធី

ដ្ឋានថវិកា និងអគ្គនាយកដ្ឋានរតនាគារជាតិ ។ អង្គភាពថវិកាត្រូវស្នើសុំមករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈអគ្គលេខាធិការដ្ឋាន ។

ការផ្ទេរឥណទាន ពីជំពូកមួយទៅជំពូកមួយទៀត ក្នុងចង្កោមសកម្មភាពតែមួយ ឬឆ្លងពីចង្កោមសកម្មភាពមួយ ទៅចង្កោមសកម្មភាពមួយទៀតនៃអនុគណនីតែមួយត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ អគ្គលេខាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ អគ្គលេខាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវស្នើសុំមកអគ្គនាយកដ្ឋានថវិកា។

ការផ្ទេរឥណទាន ពីគណនីមួយទៅអនុគណនីមួយទៀត នៅផ្ទៃក្នុងជំពូកតែមួយ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ អគ្គលេខាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវស្នើមកកាន់អគ្គនាយកដ្ឋានថវិកា ។

ការផ្ទេរឥណទាន ពីអនុកម្មវិធីមួយទៅអនុកម្មវិធីមួយទៀតឆ្លងពីជំពូកមួយទៅជំពូកមួយទៀតត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ អគ្គលេខាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវស្នើសុំមកអគ្គនាយកដ្ឋានថវិកា ( សម្រាប់អគ្គនាយកដ្ឋានថវិកាអ្នករៀបចំ )

**១.៨.១.២ និយ័តកម្មឥណទានថវិកាសម្រាប់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

និយ័តកម្មផ្ទៃក្នុងជំពូកតែមួយ ចង្កោមសកម្មភាពតែមួយ នៃអនុកម្មវិធីតែមួយ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានីខេត្ត និងត្រូវចម្លងជូនអគ្គលេខាធិការដ្ឋាន , អគ្គនាយកដ្ឋានថវិកា និងរតនាគាររាជធានីខេត្ត ។

និយ័តកម្មផ្ទៃក្នុងជំពូកតែមួយ ឆ្លងពីចង្កោមសកម្មភាពតែមួយទៅចង្កោមសកម្មភាពមួយទៀត នៃអនុកម្មវិធីតែមួយត្រូវកំណត់ដោយសេចក្តីប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវស្នើសុំមកអគ្គនាយកដ្ឋានថវិកា ។

ការផ្ទេរឥណទានពីជំពូកមួយ ទៅជំពូកមួយទៀត នៅក្នុងចង្កោមសកម្មភាពតែមួយ ឬឆ្លងពីចង្កោមសកម្មភាពតែមួយទៅចង្កោមសកម្មភាពមួយទៀត ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ អគ្គលេខាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវស្នើសុំមកអគ្គនាយកដ្ឋានថវិកា ។

### ១.៨.២ ការផ្ទេរ និងនិយ័តកម្មឥណទានដែលមិនអនុញ្ញាតលើអនុគណនី

សិទ្ធអំណាចដែលបានផ្តល់ជូនខាងលើដល់រដ្ឋមន្ត្រីក្រសួង ស្ថាប័ន និងមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរាជធានី ខេត្តក្នុងការផ្ទេរឥណទាន និងនិយ័តកម្មឥណទាននៃថវិកាកម្មវិធីរបស់រដ្ឋបាលកណ្តាល និងថវិកាកម្មវិធីរបស់មន្ទីរជំនាញរាជធានីខេត្ត នៃក្រសួងស្ថាប័ននីមួយៗមិនត្រូវបាន អនុញ្ញាតលើអនុគណនីមួយចំនួនដូចខាងក្រោម ៖

- ជំពូក ៦៤ (បៀវត្ស និងប្រាក់បំណាច់)
  - ៦៤០២៥ : ប្រាក់បំប៉នជីវភាពពិសេស
  - ៦៤០៣៣ : រង្វាន់
  - ៦៤០៥១ : មន្ត្រីមានជម្ងឺ
- ជំពូក ៦០ (ការទិញ)
  - ៦០០២១ : សម្ភារការិយាល័យ និងការបោះពុម្ព
  - ៦០០៣៤ : ពូជសត្វ ឱសថ និងវត្ថុធាតុសម្រាប់បសុពេទ្យ (ពេទ្យសត្វ)
  - ៦០០៥១ : សម្ភារៈ និងបរិក្ខារបច្ចេកទេស
  - ៦០០៥៤ : សម្ភារៈ និងឧបករណ៍ដឹកជញ្ជូន
  - ៦០០៧២ : សម្ភារៈបរិក្ខារពេទ្យ
- ជំពូកទី ៦១ (សេវាកម្ម)
  - ៦១០៥២ : ការថែទាំ និងការជួសជុលអាគារ និងប្រាសាទ
  - ៦១០៥៣ : ការថែទាំ និងការជួសជុលផ្លូវលំ ស្ពាន និងលូ
  - ៦១០៥៥ : ការថែទាំប្រព័ន្ធធារាសាស្ត្រ
- ជំពូក ៦២ (អត្ថប្រយោជន៍សង្គម)
  - ៦២០២២ : ឱសថ
  - ៦២០២៨ : ជំនួយសង្គមផ្សេងៗ
  - ៦២០៣១ : ឧបត្ថម្ភសហគមន៍

## ១.៩ ការត្រួតពិនិត្យនិងតាមដានការអនុវត្តថវិកាកម្មវិធី[12]

របាយការណ៍អនុវត្តថវិកា គឺជាឧបករណ៍សំខាន់សម្រាប់ផ្តល់ព័ត៌មាន និងសម្រាប់ធ្វើជាមូលដ្ឋានវាយតម្លៃលទ្ធផលសម្រេចបានទាំងទិដ្ឋភាពហិរញ្ញវត្ថុ និងទិដ្ឋភាពគោលនយោបាយ/ យុទ្ធសាស្ត្ររបស់ក្រសួងស្ថាប័ននីមួយៗ ។ ទន្ទឹមគ្នានេះរបាយការណ៍នេះក៏ជាមូលដ្ឋានគ្រឹះសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ឆ្នាំសារពើពន្ធ និងផែនការយុទ្ធសាស្ត្រថវិកា រយៈពេលមធ្យម

ដើម្បីមានមូលដ្ឋានត្រួតពិនិត្យនិងតាមដានការអនុវត្តថវិកាកម្មវិធីក្រសួងស្ថាប័នដែលអនុវត្តថវិកាកម្មវិធីមានកាតព្វកិច្ចរៀបចំរបាយការណ៍ពីរប្រភេទ៖ (១)របាយការណ៍ហិរញ្ញវត្ថុនិង (២) របាយការណ៍សមិទ្ធិកម្ម។

### ១.៩.១របាយការណ៍ហិរញ្ញវត្ថុនៃការអនុវត្តថវិកាកម្មវិធី

របាយការណ៍ហិរញ្ញវត្ថុ គឺឆ្លុះបញ្ចាំងអំពីកិច្ចដំណើរការដែលក្រសួងស្ថាប័ននិងអង្គភាពសាធារណៈប្រហាក់ប្រហែលគ្រប់គ្រង និងចាត់ចែងធនធានថវិការបស់រដ្ឋ។ របាយការណ៍ហិរញ្ញវត្ថុវិភាគអំពីស្ថានភាពអនុវត្តថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា (ជំពូកគណនីនិងអនុគណនី) ដោយបង្ហាញព័ត៌មានអំពីកញ្ចប់ឥណទានថវិកាដែលត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ ការធ្វើចលនាឥណទានថវិកាការប្រើប្រាស់ និងសមតុល្យឥណទានថវិកាទាំងការធានាចំណាយនិងទាំងការបោះផ្សាយបើកប្រាក់ ក្នុងការិយបរិច្ឆេទនៃឆ្នាំអនុវត្តថវិការបស់ក្រសួងស្ថាប័ននិងអង្គភាពសាធារណៈប្រហាក់ប្រហែល ។ របាយការណ៍ហិរញ្ញវត្ថុក៏ត្រូវបង្ហាញអំពីលទ្ធផលសម្រេចបានក្នុងឆ្នាំសារពើពន្ធធៀបជាមួយនឹងលទ្ធផលអនុវត្តនៅឆ្នាំមុនៗ ។

ក្រសួងស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល តម្រូវឱ្យធ្វើរបាយការណ៍តាមគំរូរួម និងតាមទម្រង់នៃប្រភេទរបាយការណ៍នីមួយៗដូចមានភ្ជាប់ នៅក្នុងតារាងឧបសម្ព័ន្ធទី១៦ដល់ទី២៣ ។ របាយការណ៍ហិរញ្ញវត្ថុទាំងអស់ត្រូវធ្វើឡើងនិងផ្ញើមក្រសួងសេដ្ឋកិច្ចនិងហរិញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកានិងអគ្គនាយកដ្ឋានរតនាគារជាតិ) តាមការិយបរិច្ឆេទដូចខាងក្រោម ៖

- របាយការណ៍ចំណូល-ចំណាយប្រចាំខែតាមចំណាត់ថ្នាក់សេដ្ឋកិច្ច ត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមថ្ងៃទី១០នៃខែបន្ទាប់

[12]ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍នាំស្តីនីតិវិធីអនុវត្តថវិកាកម្មវិធី

- របាយការណ៍ចំណាយប្រចាំត្រីមាសនៃការអនុវត្តកម្មវិធីអនុវកម្មវិធីនិងចង្កោមសកម្មភាពទៅតាមជំពូកចំណាយត្រូវផ្ញើរមកយ៉ាងយូរបំផុត ត្រឹមថ្ងៃទី១៥នៃខែនៅដើមត្រីមាសបន្ទាប់ ។
- របាយការណ៍ចំណាយប្រចាំឆមាសនៃ ការអនុវត្តកម្មវិធីអនុវកម្មវិធីនិងចង្កោមសកម្មភាពទៅតាមជំពូកចំណាយ ត្រូវផ្ញើរមកយ៉ាងយូរបំផុត១៥ថ្ងៃបន្ទាប់ពីបញ្ចប់នៃឆមាសនីមួយៗ។
- របាយការណ៍ចំណូល-ចំណាយសម្រាប់ការត្រួតពិនិត្យ ពាក់កណ្តាលឆ្នាំតាមចំណាត់ថ្នាក់សេដ្ឋកិច្ចត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមថ្ងៃទី ១៥ នៃខែកក្កដា ។
- របាយការណ៍ចំណូល-ចំណាយប្រចាំឆ្នាំ តាមចំណាត់ថ្នាក់សេដ្ឋកិច្ចត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមថ្ងៃទី ១៥ ខែ មករាឆ្នាំបន្ទាប់ ។
- របាយការណ៍ចំណាយប្រចាំឆ្នាំនៃ ការអនុវត្តកម្មវិធីអនុកម្មវិធី និងចង្កោមសកម្មភាពទៅតាមជំពូកចំណាយត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹមថ្ងៃទី ១៥ ខែមករា ឆ្នាំបន្ទាប់។

### ១.៩.២របាយការណ៍សមិទ្ធិកម្មនៃការអនុវត្តថវិកាកម្មវិធី

របាយការណ៍សមិទ្ធិកម្ម គឺឆ្លុះបញ្ចាំងអំពីការវាស់វែងលទ្ធផលនិងវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តចង្កោមសកម្មភាពអនុវកម្មវិធី និងកម្មវិធីដើម្បីឈានឆ្ពោះទៅសម្រេចគោលបំណងគោលនយោបាយរបស់ក្រសួងស្ថាប័ន ។ ព័ត៌មាននេះអាចជាបច្ច័យនាំទៅដល់ការសម្រេចចិត្តដើម្បីផ្លាស់ប្តូរយុទ្ធសាស្ត្រកម្មវិធីកែសម្រួលទំហំថវិកា ឬផ្លាស់ប្តូររបៀបគ្រប់គ្រងកម្មវិធី។

ក្នុងន័យនេះ ដើម្បីធានាបានគណនេយ្យភាព និងការទទួលខុសត្រូវចំពោះលទ្ធផលនៃចំណាយសាធារណៈពិសេស ដើម្បីធានាប្រសិទ្ធិភាពនៃការអនុវត្តថវិកាក្រសួងស្ថាប័ននិងមន្ទីរជំនាញរាជធានីខេត្តទាំងអស់ត្រូវតាមដានការ អនុវត្តថវិការបស់ខ្លួនជាប្រចាំនិងធ្វើរបាយការណ៍អំពីវឌ្ឍនភាពលើសូចនាករលទ្ធផលក្នុងឆ្នាំជាចាំបាច់ និងសូចនាករលទ្ធផលចុងក្រោយតាមដែលអាចធ្វើបានដោយអនុលោមតាមទម្រង់តារាងរួម ដែលបានពណ៌នានៅក្នុងតារាងឧបសម្ព័ន្ធទី២៤និងទី២៥។

របាយការណ៍សមិទ្ធកម្មទាំងអស់ត្រូវធ្វើឡើង និងផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកកម្មនៃអគ្គនាយកដ្ឋានថវិកានិងអគ្គនាយកដ្ឋានរតនាគារជាតិ) តាមការិយបរិច្ឆេទដូចខាងក្រោម ៖

- របាយការណ៍សមិទ្ធកម្មប្រចាំឆមាស ត្រូវផ្ញើមកយ៉ាងយូរបំផុត១៥ថ្ងៃបន្ទាប់ពីបញ្ចប់នៃឆមាសនីមួយៗ ។
- របាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ ត្រូវផ្ញើមកយ៉ាងយូរបំផុតត្រឹម ថ្ងៃទី១៥ខែមករាឆ្នាំបន្ទាប់ ។

# ជំពូកទី២

# ស្ថានភាពទូទៅរបស់

# ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# ជំពូកទី ២

# ស្ថានភាពទូទៅរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ២.១ ប្រវត្តិក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបានបង្កើតឡើងនៅក្នុងអាណត្តិទី១ នៃរាជរដ្ឋាភិបាលកម្ពុជា នៅថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលមានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជាក្នុងគោលដៅទ្រទង់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងលើកតម្កើងជីវភាពប្រជាជន ដោយឈរលើគោលការណ៍សេដ្ឋកិច្ចទីផ្សារ និងសមធម៌សង្គម ។ បេសកកម្មនេះត្រូវធ្វើឡើង តាមរយៈការរៀបចំ និងការអនុវត្តន៍អោយបានត្រឹមត្រូវនូវគោលនយោបាយក្របខ័ណ្ឌច្បាប់ និងបទបញ្ញាទាំងឡាយដែលទាក់ទងនឹងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ទ្រព្យសម្បត្តិរដ្ឋ កិច្ចការវិនិយោគ និងឧស្សាហកម្មហិរញ្ញវត្ថុព្រមទាំងច្បាប់ និងបទបញ្ញាពាក់ព័ន្ធផ្សេងទៀត ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបានបង្កើតឡើងដោយមានមុខងារ និងភារកិច្ចដូចខាងក្រោម ៖[13]

- គ្រប់គ្រង និងសម្របសម្រួលកិច្ចការកែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ពង្រឹងអភិបាលកិច្ចល្អទៅលើអ្វីដែលពាក់ព័ន្ធនឹងការគ្រប់គ្រងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ
- ធ្វើការបែងចែក និងបែងចែកឡើងវិញនូវផលទុនជាតិតាមរយៈការប្រមូលចំណូល និងកម្មវិធីនីយកម្ម និងថវិកានីយកម្មនៃចំណាយសាធារណៈ
- កសាងប្រព័ន្ធហិរញ្ញវត្ថុអោយឯកភាពទូទាំងប្រទេស ហើយធានាអនុវត្តប្រព័ន្ធនេះអោយបានត្រឹមត្រូវតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ និងច្បាប់ហិរញ្ញវត្ថុសំរាប់គ្រប់គ្រងឆ្នាំនីមួយៗ ព្រមទាំងច្បាប់ពាក់ព័ន្ធ និងបទបញ្ញាដទៃទៀត ។
- រៀបចំកសាងសេចក្តីព្រាងច្បាប់ និងបទបញ្ញាផ្សេងៗសម្រាប់ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជាលក្ខណៈប្រចាំឆ្នាំនីមួយៗ ឬជាលក្ខណៈអចិន្ត្រៃយ៍
- រៀបចំ និងគ្រប់គ្រងថវិការដ្ឋ
- រៀបចំ និងអនុវត្តគោលនយោបាយចំណូលថវិកាជាតិ

[13]រាជរដ្ឋាភិបាលកម្ពុជា, អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ,លេខ ០៤ អនក្រ.បក ,២០ មករា ២០០០, មាត្រា៣

- ប្រមូលសារពើពន្ធ និងមិនមែនសារពើពន្ធ បង់ចូលបេឡាថវិការដ្ឋ ធ្វើតារាងតុល្យភាព និង វិភាគគណនីនៃប្រតិបត្តិការហិរញ្ញវត្ថុ
- ពិនិត្យ និងចុះទិដ្ឋាការលើចំណាយរបស់ក្រសួង និងស្ថាប័នរដ្ឋនានា
- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- វិភាគតាមដាន និងព្យាករណ៍ស្ថានភាពសេដ្ឋកិច្ចក្នុងរយៈពេលខ្លី មធ្យម និងរយៈពេលវែង និងដាក់ចេញនូវវិធានការដើម្បីតម្រង់ទិស និងកែលម្អការគ្រប់គ្រងសេដ្ឋកិច្ច
- ចូលរួមចំណែកអភិវឌ្ឍគ្រប់គ្រង និងត្រួតពិនិត្យកិច្ចការឧស្សាហកម្មហិរញ្ញវត្ថុរួមមានកិច្ចការធានារ៉ាប់រង ទីផ្សារមូលបត្រ ឆ្នោត ឡូតូ កាស៊ីណូ បេឡាសោធនិវត្តន៍ និង សេវាហិរញ្ញវត្ថុផ្សេងៗទៀត
- សហការជាមួយក្រសួង និង ស្ថាប័នពាក់ព័ន្ធដើម្បីដឹកនាំ និងចូលរួមក្នុងការរៀបចំអនុវត្តន៍គោលនយោបាយយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលលើកិច្ចការសហប្រតិបត្តការអន្តរជាតិក្នុងវិស័យសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងកិច្ចការសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងសេដ្ឋកិច្ចក្នុងក្របខ័ណ្ឌអាស៊ាន
- ចូលរួមក្នុងការកសាងការងារកៀរគរជំនួយ ព្រមទាំងរៀបចំផែនការខ្ចី និងសងបំណុលបរទេសហើយតាមដាន និងត្រួតពិនិត្យលើការអនុវត្តផែនការទាំងនោះ
- បំពេញមុខងារអធិការកិច្ច លើផ្នែកហិរញ្ញវត្ថុសារធារណៈ
- បណ្តុះបណ្តាល និងធ្វើវិក្រឹត្យការជាប្រចាំនូវមុខជំនាញសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដល់មន្ត្រីក្រសួង និងក្រសួងស្ថាប័នពាក់ព័ន្ធ ។

## ២.២ រចនាសម្ព័ន្ធរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ[14]

រចនាសម្ព័ន្ធស្ថាប័ននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើង និងដាក់អោយដំណើរការក្នុងក្របខ័ណ្ឌស្ថានប័ន និងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីទ្រទ្រង់ការបំពេញមុខងារ និងបេសកកម្មរបស់ខ្លួនដែលកំណត់ដោយច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន។ រចនាសម្ព័ន្ធនេះ កំនត់បានជាអភិក្រមការងារមួយដែលមានលក្ខណៈប្រទាក់ក្រឡាទាំងក្នុងក្របខ័ណ្ឌក្រសួងផ្ទាល់នៅថ្នាក់កណ្តាល និង ថ្នាក់មូលដ្ឋាន ព្រមទាំងជាមួយក្រសួង ស្ថាប័នក្រៅផងដែរ ។

[14]ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កម្រងអត្ថបទគតិយុត្តសម្រាប់ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ភ្នំពេញ៖ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០១០) ១៣-៦៦៣

រចនាសម្ព័ន្ធគ្រប់គ្រង និងរដ្ឋបាលទាំងនៅថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន ត្រូវបានរៀបចំផ្អែកតាមអនុក្រឹត្យរបស់រាជរដ្ឋាភិបាលសម្រាប់ថ្នាក់នាយកដ្ឋានឡើង និងតាមប្រកាសក្រសួងផ្ទាល់សម្រាប់ថ្នាក់ការិយាល័យចុះ។ ក្រសួងត្រូវបានដឹកនាំដោយប្រធានស្ថាប័នមួយរូបអមដោយរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការមួយចំនួនដែលជាឥស្សរជននយោបាយ និងដោយឡែកកម្រិតផ្នែករដ្ឋបាល ដោយរាប់ចាប់ពីមុខងារគ្រប់គ្រងអគ្គលេខាធិការដ្ឋាន និងអគ្គនាយកដ្ឋានចុះក្រោមត្រូវបំពេញដោយ មន្ត្រីរាជការក្របខ័ណ្ឌនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ដោយផ្អែកតាមបទដ្ឋានគតិយុត្តបច្ចុប្បន្ន រចនាសម្ព័ន្ធក្រសួងនៅថ្នាក់កណ្តាលរួមមានអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន ខុទ្ទកាល័យ នាយកដ្ឋាន អគ្គាធិការដ្ឋាន វិទ្យាស្ថាន និងអង្គភាពមួយចំនួនទៀត ដោយឡែកអង្គភាពមូលដ្ឋាន រួមមានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រតនាគាររាជធានីខេត្ត សាខាពន្ធដារ និងសាខាគយនិងរដ្ឋាករ ទន្ទឹមនេះក្រសួងក៏បានបង្កើតអោយមានអង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ លើចំណាយថវិកាតាមបណ្តាក្រសួង ស្ថាប័នផងដែរ ។ ក្រៅពីអង្គភាពខាងដើមដោយហេតុតម្រូវការការអនុវត្តន៍មុខងាររបស់ខ្លួន ក្រសួងបានបង្កើតអោយមានជាគណៈកម្មាធិការ គណៈកម្មការ ឬអនុគណៈកម្មាធិការមួយចំនួនដើម្បីគាំទ្រដល់ការអនុវត្តន៍កម្មវិធីកែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងជាក្រុមប្រឹក្សាជាតិគណនេយ្យផងដែរ ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចាប់ផ្តើមអនុវត្តថវិកាកម្មវិធីពេញលេញនៅឆ្នាំ ២០១៥[15]ស្តីពីការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ ។ ការត្រួតពិនិត្យនិងការវាយតម្លៃការអនុវត្តថវិកា ដែលរួមមានទាំងការត្រួតពិនិត្យលើ ទិដ្ឋភាពហិរញ្ញវត្ថុ និងទិដ្ឋភាពសមិទ្ធកម្ម ត្រូវបានរៀបចំឡើងដោយអគ្គលេខាធិការដ្ឋាននៃក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ (កសហវ.) ក្នុងមុខងារជាអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ ដើម្បីសម្រេចបានពេញ មួយជុំនៃវដ្តថវិកា ស្របតាមគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធីឆ្នាំ ២០១៥[16] ដែលត្រូវបានដាក់ឲ្យអនុវត្តដោយសេចក្តីប្រកាសលេខ ១៩១១ សហវ. ប្រកចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ។ រចនាសម្ព័ន្ធក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (សូមមើលឧបសម្ព័ន្ធទី១) ។

[15] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, សេចក្តីប្រកាសស្តីពីការចាប់ផ្តើមអនុវត្តថវិកាកម្មវិធីពេញលេញ ឆ្នាំ២០០៨

[16] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, សៀវភៅគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធីឆ្នាំ ២០១៥

*តារាងទី៥៖ រចនាសម្ព័ន្ធគោលបំណងគោលនយោបាយនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឆ្នាំ២០១៦*



## ២.៤ ភារកិច្ច និងការទទួលខុសត្រូវ[17]

ដើម្បីរួមចំណែកអនុវត្តគោលបំណងគោលនយោបាយទាំងពីរនេះក្រសួងបានដាក់ចេញនូវកម្មវិធីចំនួន៥និងអនុកម្មវិធីចំនួន២១រួមមាន៖

### ២.៤.១ កម្មវិធីទី១ពង្រឹងនិងបង្កើនប្រសិទ្ធិភាពនៃការគ្រប់គ្រងសេដ្ឋកិច្ច

- អនុកម្មវិធី១.១៖ ពង្រឹងនិងបង្កើតការរៀបចំអភិវឌ្ឍវិភាគព្យាករណ៍តាមដាន និងវាយតម្លៃលើការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈប្រកបដោយសុក្រឹតភាព (អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ) ។
- អនុកម្មវិធី១.២៖ ការរៀបចំអនុសាសន៍ ការវិភាគការព្យាករណ៍ការតាមដាននិងការវាយតម្លៃ ការអនុវត្តក្របខណ្ឌគោលនយោបាយក្របខណ្ឌយុទ្ធសាស្ត្រ និងគោលនយោបាយសេដ្ឋកិច្ចពលកម្មផលិតភាពពលកម្ម និងភាពប្រកួតប្រជែង (លេខាធិការដ្ឋានគណៈកម្មាធិការផលិតភាពកម្ពុជា) ។
- អនុកម្មវិធី១.៣៖ គាំទ្រប្រមុខរាជរដ្ឋាភិបាលក្នុងការរៀបចំអនុវត្ត និងវាយតម្លៃរបៀបវារៈគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍសង្គម-សេដ្ឋកិច្ច (ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ) ។

### ២.៤.២ កម្មវិធីទី២៖ពង្រឹងនិងបង្កើនប្រសិទ្ធិភាពនៃការគ្រប់គ្រងការត្រួតពិនិត្យនិងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ

- អនុកម្មវិធីទី២.១៖ គ្រប់គ្រង ត្រួតពិនិត្យ អភិវឌ្ឍវិស័យឧស្សាហកម្មហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ)
- អនុកម្មវិធីទី២.២៖ ពង្រឹង និងបង្កើតប្រសិទ្ធិភាព និងស័ក្តិសិទ្ធិភាពនៃការរៀបចំនិងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រអភិវឌ្ឍក្របខណ្ឌគតិយុត្តការត្រួតពិនិត្យ ការដោះស្រាយវិវាទ កាអនុវត្តការពិនិត្យតាមដាននិងការវាយតម្លៃលើការអនុវត្តប្រព័ន្ធគណនេយ្យ និងសវនកម្ម (ក្រុមប្រឹក្សាជាតិគណនេយ្យ) ។

[17]ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, សៀវភៅផែនការយុទ្ធសាស្ត្រថវិកា ឆ្នាំ២០១៦-២០១៨

- អនុកម្មវិធីទី២.៣៖ ពង្រឹង និងបង្កើតប្រសិទ្ធភាព នៃការគ្រប់គ្រងត្រួតពិនិត្យនិងអភិវឌ្ឍវិស័យមូលបត្រប្រកបដោយគណនេយ្យ និងសវនកម្ម (គណៈកម្មការមូលបត្រកម្ពុជា) ។

**២.៤.៣កម្មវិធីទី៣ ៖ពង្រឹងនិងបង្កើនស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាពនៃការគ្រប់គ្រងការកៀរគរចំណូលថវិកាជាតិនិងទ្រព្យសម្បត្តិរដ្ឋ**

- អនុកម្មវិធី៣.១៖ គ្រប់គ្រងអនុវត្តត្រួតពិនិត្យតាម និងវាយតម្លៃលើកាប្រមូលចំណូល-គយ និងរដ្ឋាករ (អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា) ។
- អនុកម្មវិធី៣.២៖ គ្រប់គ្រង និងពង្រឹងការកៀរគរចំណូលពន្ធដារ (អគ្គនាយកដ្ឋានពន្ធដារ)
- អនុកម្មវិធី៣.៣៖ គ្រប់គ្រងសម្របសម្រួល និងត្រួតពិនិត្យការប្រមូលចំណូលមិនមែនសារពើពន្ធ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (អគ្គនាយកដ្ឋានទ្រព្យរដ្ឋ និងចំណូលមិនមែនសារពើពន្ធ)

**២.៤.៤ កម្មវិធីទី៤ ៖ពង្រឹងនិងបង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងចំណាយសាធារណៈ**

- អនុកម្មវិធីទី៤.១៖ការគ្រប់គ្រង និងរៀបចំថវិកាជាតិនិងត្រួតពិនិត្យតាមដានការអនុ-វត្តថវិកាថ្នាក់ជាតិ(អគ្គនាយកដ្ឋានថវិកា)
- អនុកម្មវិធីទី៤.២៖គាំទ្រសម្របសម្រួលគ្រប់គ្រង និងវាយតម្លៃលើការងារថវិកា និងការងារកែទម្រង់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ)
- អនុកម្មវិធីទី៤.៣៖ ការគាំទ្រសម្របសម្រួល និងគ្រប់គ្រងលទ្ធកម្មសាធារណៈ (អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)
- អនុកម្មវិធីទី៤.៤៖ ពង្រឹងការគ្រប់គ្រងសាច់ប្រាក់ប្រព័ន្ធកត់ត្រា និងរបាយការណ៍ហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាជាតិ)
- អនុកម្មវិធីទី៤.៥៖ ការគ្រប់គ្រងតាមដាន និងត្រួតពិនិត្យលើកាវៀបចំ និងអនុវត្តហិរញ្ញប្បទានសហប្រតិបត្តិការ និងគ្រប់គ្រងបំណុលសាធារណៈ (អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល)

**២.៤.៥ កម្មវិធីទី៥៖ ពង្រឹងនិងបង្កើនស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាពនៃការគាំទ្រទូទៅនិងការធានាគណនេយ្យភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

- អនុកម្មវិធីទី៥.១៖ ទ្រទ្រង់កម្មវិធីកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្ពោះទៅកាន់ស្តង់ដាអន្តរជាតិ។
  (អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ)
- អនុកម្មវិធីទី៥.២៖ គាំទ្រកិច្ចដំណើរការ និងការអនុវត្តមុខងារនិងភារកិច្ចរបស់ថ្នាក់ដឹកនាំនិងអង្គភាពក្រោមឳវាទក្រសួង។
  (អគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ)
- អនុកម្មវិធីទី៥.៣៖ ពង្រឹង និងបង្កើតស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាពនៃការគ្រប់គ្រងវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅរាជធានី-ខេត្ត។
  (មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត)
- អនុកម្មវិធីទី៥.៤៖ អនុវត្តមុខងារអធិការកិច្ចហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។ (អគ្គាធិការដ្ឋាន)
- អនុកម្មវិធីទី៥.៥៖ ពង្រឹងនិងបង្កើតស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃការរៀបចំនិងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍមុខងារសវនកម្មផ្ទៃក្នុងក្របខណ្ឌស្តង់ដារសវនកម្មផ្ទៃក្នុង និងធ្វើសវនកម្មលើស័ក្តិ-សិទ្ធភាពនៃដំណើរការប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង
  (អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង )
- អនុកម្មវិធីទី៥.៦៖ ពង្រឹងនិងបង្កើតស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាគាំទ្រលើការបណ្តុះបណ្តាល និងវិក្រឹត្តការសមត្ថភាពមន្ត្រីរាជការលើកជំនាញគ្រប់គ្រងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរួមទាំងបច្ចេកទេសវិទ្យាព័ត៌មានពាក់ព័ន្ធជូនកសហរ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ
  (វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ)
- អនុកម្មវិធីទី៥.៧៖ រៀបចំអនុវត្តនិងគ្រប់គ្រងការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព
  (អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍)

# ជំពូកទី៣

# ការអនុវត្តវិភាគកម្មវិធី និងការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ

# ជំពូកទី៣
# លទ្ធផលនៃការអនុវត្តថវិកាកម្មវិធី និងការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ

ឆ្លងកាត់តាមការធ្វើកំណែទម្រង់ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨ មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានកំពុងបន្តបេសកម្មរបស់ខ្លួនក្នុងគោលដៅមួយប្រកបដោយភាពវិជ្ជមាន និងទស្សនៈវិស័យខ្ពស់បំផុត ។ ទន្ទឹមនឹងនេះផងដែរ ដើម្បីសម្រេចបាននូវគោលដៅកែសម្រួលប្រព័ន្ធហិរញ្ញវត្ថុដែលបានដាក់ចេញនេះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក៏បានដាក់ចេញនូវប្រព័ន្ធកម្ម-វិធីថវិកាមួយដែលមាន ការរៀបចំថវិកា ផែនការយុទ្ធសាស្ត្រថវិកាបីឆ្នាំរំកិល និងកញ្ចប់ថវិកាប្រចាំឆ្នាំ។

ដើម្បីធ្វើការត្រួតពិនិត្យវាយតម្លៃការអនុវត្តថវិកាប្រចាំឆ្នាំ ២០១៦របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបាន យើងត្រូវសិក្សាលើទិដ្ឋភាព៖

- គម្រោងចំណូល-ចំណាយថវិការយៈពេលមធ្យម (៣ឆ្នាំរំកិល) របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់ឆ្នាំ ២០១៦-២០១៨ ដោយយកឥណទានឆ្នាំ ២០១៥ មកធ្វើការប្រៀបធៀប
- ធ្វើការបកស្រាយលើទិដ្ឋភាពចំណាយសម្រាប់ថវិកាប្រចាំឆ្នាំ ២០១៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមមាតិកាកម្មវិធី
- វិភាគអំពីរបាយនៃការបោះផ្សាយអាណត្តិបើកប្រាក់/អាណត្តិនិយ័តកម្ម ទូទាត់ចំណាយតាមខែ
- ធ្វើវិភាគលើចលនាឥណទាន របស់អង្គភាពថវិកាថ្នាក់កណ្តាល ប្រចាំឆ្នាំ២០១៦

សូមបញ្ជាក់ថាៈ តួលេខអនុវត្តនៅក្នុងរបាយការណ៍នេះ ជាតួលេខបណ្តោះអាសន្ន គិតត្រឹមថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧ ។ តួលេខអាចប្រែប្រួលក្រោយការពិនិត្យផ្ទៀងផ្ទាត់ដោយ អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល អគ្គនាយកដ្ឋានរតនាគារជាតិ ជាមួយនឹងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

## ៣.១ផែនការយុទ្ធសាស្ត្រថវិកា២០១៦-២០១៨

### ៣.១.១ ផ្នែកចំណូល




*(ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ "របាយការណ៍ស្តីពីការត្រួតពិនិត្យវាយតម្លៃការអនុវត្តថវិកាឆ្នាំ២០១៦")*

ការគម្រោងចំណូលឆ្នាំ ២០១៦មានចំនួនទាបជាងច្បាប់ឆ្នាំ២០១៥ ។ នេះក៏ដោយសារក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមើលឃើញថាការគម្រោងចំណូលមូលធន និងចំណូលក្រៅស្រុកធ្លាក់ចុះជាបន្តគ្នាក្នុងឆ្នាំ ២០១៧ និង ២០១៨ បើធៀបនឹងឥណទានឆ្នាំ ២០១៥ ។ ប៉ុន្តែចំណូលសរុបកើនឡើងស្មើកម្រិតឥណទានច្បាប់ឆ្នាំ ២០១៥ នៅក្នុងឆ្នាំ ២០១៨។ គម្រោងចំណូលសារពើពន្ធកើនឡើងប្រមាណ ២២% ក្នុងឆ្នាំ ២០១៦ និងបន្តកើនឡើង ៨%ក្នុងមួយឆ្នាំ ក្នុងឆ្នាំ២០១៧-២០១៨ ។

## ៣.១.២ ផ្នែកចំណាយ




*(ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ "របាយការណ៍ស្តីពីការត្រួតពិនិត្យវាយតម្លៃការអនុវត្តថវិកា ឆ្នាំ២០១៦")*

យោងតាមក្រាបបញ្ជាក់ថា និន្នាការនៃការគ្រោងចំណាយថវិការបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្នាំ២០១៥-២០១៨ នៅតែបន្តកើនឡើងជារៀងរាល់ឆ្នាំ ។ ក្នុងនោះយើងឃើញថាក្នុងកម្មវិធីទី៤ មានការចំណាយធ្លាក់ចុះ ក៏ព្រោះតែថវិការភាគច្រើននៃកម្មវិធីមួយនេះពឹងផ្អែកភាគច្រើនទៅលើកថវិកាដៃគូរ។ ដូច្នេះហើយឆ្លងកាត់តាមគ្រោងចំណូលបានឱ្យដឹងថា ចំណូលថវិកាដៃគូរនិងចំណូលមូលធនមាននិន្នាការធ្លាក់ចុះ ដូច្នេះទើបកម្មវិធីដែលធ្លាប់ចាយថវិកាដៃគូរត្រូវកាត់បន្ថយការចំណាយ ។

ដូច្នេះគម្រោងចំណាយឆ្នាំ ២០១៦ កើនឡើងលើសច្បាប់ឆ្នាំ ២០១៥ ប្រមាណ ២៤% និងបន្តកើនឡើងក្នុងអត្រា ១០%ក្នុងមួយឆ្នាំ ពីឆ្នាំ២០១៦ដល់ ឆ្នាំ២០១៨ នៅក្នុងគ្រប់កម្មវិធី នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ៣.២ លទ្ធផលនៃការអនុវត្តចំណាយរួមក្រសួងតាមមាតិកម្មវិធី

ក្រាហ្វិកទី៣៖ ការអនុវត្តចំណាយថវិការបស់ កសហវ. ប្រចាំឆ្នាំ២០១៦ តាមកម្មវិធី




*(ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ "របាយការណ៍ស្តីពីការត្រួតពិនិត្យវាយតម្លៃការអនុវត្តថវិកាឆ្នាំ២០១៦")*

ឥណទានថ្មីចំនួន៦០២,១ប៊ីលានរៀល (បន្ថែមឥណទានប្រមាណ១០០ប៊ីលានរៀលក្នុងនោះ៨០ប៊ីលានរៀលសម្រេប់អនុវត្តវិធានការរបស់រាជរដ្ឋាភិបាលលើបញ្ហាស្រូវអង្ករក្នុងត្រីមាសទី៤ ឆ្នាំ២០១៦) ។ចំណាយនៅក្នុងកម្មវិធីទី៤ទាបដោយហេតុថាមុខសញ្ញាចំណាយវិភាគទានដល់អង្គការអន្តរជាតិក្នុងជំពូក៦៥ដែលមានលក្ខណៈជាការវិនិយោគត្រូវបានថ្នាក់ដឹងនាំផ្តល់ការណែនាំឱ្យប្តូរទៅប្រើជំពូក២៦វិញ។ ក្នុងនោះកម្មវិធីទី១ បានអនុវត្តចំណាយធៀបនឹងឥណទានថ្មីបានសម្រេចចំនួន ៩០% កម្មវិធីទី២ បានអនុវត្តចំណាយធៀបនឹងឥណទានថ្មីបានសម្រេចចំនួន ៨៣% កម្មវិធីទី៣ បានអនុវត្តចំណាយធៀបនឹងឥណទានថ្មីបានសម្រេចចំនួន ៩៨% កម្មវិធីទី៤ បានអនុវត្តចំណាយធៀបនឹងឥណ ទានថ្មីបានសម្រេចចំនួន ៦៤% និងកម្មវិធីទី៥ បានអនុវត្តចំណាយធៀបនឹងឥណទានថ្មីបានសម្រេចចំនួន ៩៤% ។ការអនុវត្តចំណាយជារួមបានចំនួន៥៧៦,៣ប៊ីលានរៀលស្មើនឹងប្រមាណ៩៦%នៃឥណទានថ្មី ។

## ៣.៣ លម្អិតលទ្ធផលនៃការអនុវត្តចំណាយ នៅតាមអង្គភាពថវិកាថ្នាក់មូលដ្ឋាន

ក្រាបហ្វិចទី៦៖ លទ្ធផលនៃការអនុវត្តចំណាយថវិកា ឆ្នាំ២០១៦ នៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជធានី ខេត្ត




*(ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ "របាយការណ៍ស្តីពីការត្រួតពិនិត្យវាយតម្លៃការអនុវត្តថវិកា ឆ្នាំ២០១៦")*

ការអនុវត្តចំណាយនៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានល្អក្នុងរង្វង់ពី ៨៥-១០០% នៃឥណទានថ្មី។ ក្នុងនោះមន្ទីរសេដ្ឋកិច្ចខេត្តដែលអនុវត្តចំណាយបានល្អបំផុតក្នុងចន្លោះពី៩៦%-១០០% រួមមាន៖

- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តកែបអនុវត្តចំណាយសម្រេចបាន៩៩.៥%
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តព្រះវិហារអនុវត្តចំណាយសម្រេចបាន៩៨.៧%
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តប៉ៃលិនអនុវត្តចំណាយសម្រេចបាន៩៨.៦%
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តកំពង់ឆ្នាំងអនុវត្តចំណាយសម្រេចបាន៩៨.១%
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តព្រះសីហនុអនុវត្តចំណាយសម្រេចបាន៩៧.៥%
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តព្រៃវែងអនុវត្តចំណាយសម្រេចបាន៩៧.៤%
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តស្វាយរៀងអនុវត្តចំណាយសម្រេចបាន៩៧.១%
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តបន្ទាយមានជ័យអនុវត្តចំណាយសម្រេចបាន៩៦.៨%
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តកំពង់ស្ពឺអនុវត្តចំណាយសម្រេចបាន៩៦.២%

## ៣.៤ របាយនៃការបោះផ្សាយអាណត្តិបើកប្រាក់ទូទាត់ចំណាយតាមខែ




*(ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ "របាយការណ៍ស្តីពីការត្រួតពិនិត្យវាយតម្លៃការអនុវត្តថវិកា ឆ្នាំ២០១៦")*

ទិន្នន័យនៃការបោះផ្សាយអាណត្តិជាក់ស្តែងបង្ហាញថា ការទូទាត់ចំណាយមួយភាគធំប្រមូលផ្តុំនៅចុងឆ្នាំនៃការអនុវត្តថវិកា ដោយមានអាណត្តិចំនួន ៤៤៤/១,០៤៦ អាណត្តិ ឬប្រមាណ ៤២% នៃអាណត្តិ ត្រូវបានបោះផ្សាយនៅក្នុងខែធ្នូ ឆ្នាំ២០១៦ ។ ចំណែកការអនុវត្តកិច្ចលទ្ធកម្ម មានភាពយឺតយ៉ាវ ដោយអាណត្តិទូទាត់កិច្ចលទ្ធកម្មទើបចាប់ផ្តើមបោះផ្សាយដំបូងនៅក្នុងខែមិថុនា ឆ្នាំ ២០១៦ ហើយភាគច្រើនប្រមូលផ្តុំនៅជំណាច់ឆ្នាំ នាំឱ្យប៉ះពាល់ដល់ការផ្គត់ផ្គង់ទំនិញ និងសេវា ។

## ៣.៥ ចលនាឥណទាន




*(ប្រភពៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ "របាយការណ៍ស្តីពីការត្រួតពិនិត្យវាយតម្លៃការអនុវត្តថវិកាឆ្នាំ២០១៦")*

សរុបចលនាឥណទាន ក្នុងឆ្នាំ២០១៦ របស់អង្គភាពថវិកាថ្នាក់កណ្តាលមានចំនួន៧១ដង ក្នុងនោះរួមមាន៖

- និយ័តកម្មផ្ទៃក្នុងជំពូកមានចំនួន ៣៦ ដង
- និយ័តកម្មឆ្លងគណនីជំពូកមានចំនួន ១៧ ដង
- បន្ថែមជំពូក៦៤ មានចំនួន ០៩ ដង
- និងបន្ថែមដោយផ្ទេរពីជំពូក ៦៩ ចំនួន ០៩ដង។

ដោយឡែកសម្រាប់ឆ្នាំ ២០១៥ សរុបចលនាឥណទានចំនួន ៩៩ដងប៉ុណ្ណោះ ។ កាលណាមានចលនាឥណទានច្រើនដង បង្ហាញឱ្យឃើញថាការរៀបចំថវិកានៅមានកម្រិតឡើយ ។ សូមបញ្ជាក់ថាចំពោះអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធនិងអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈពុំដែលស្នើសុំធ្វើចលនាឥណទានឡើយ ។

## ៣..៦ វិភាគអំពីចំណុចខ្លាំង និងចំណុចខ្សោយ

ក្រោយពីបានបញ្ចប់កម្មសិក្សា អស់រយៈពេលមួយខែកន្លងមកនេះ និងការសិក្សាស្រាវជ្រាវពីស្ថានភាពជាក់ស្តែងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ យើងខ្ញុំបានធ្វើការត្រួតពិនិត្យនូវការសកម្មភាពជាក់ស្តែង និងការអនុវត្តថវិកាកម្មវិធីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងរយៈពេលកន្លងមក យើងអាចធ្វើការទាញយកបាននូវចំណុចខ្លាំង និងចំណុចខ្សោយមួយចំនួនដូចតទៅ ៖

### ៣.៦.១ចំណុចខ្លាំង ៖

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទើបតែបង្កើតឡើងនៅក្នុងឆ្នាំ ១៩៩៦ ប៉ុន្តែក្រសួងអាចសម្រេចបានលទ្ធផលនូវបេសសកម្មរបស់ខ្លួនបានជាច្រើនដូចជា ការកៀរគរ ប្រាក់ចំណូលសម្រាប់ចំណាយដែលចាំបាច់ និងសន្សំសំចៃ ការអនុវត្តកំណែទម្រង់របស់រដ្ឋាភិបាល ការចូលរួម អនុវត្តថវិកាកម្មវិធីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានសម្រេចនូវបេសកម្មរបស់ខ្លួនជាច្រើន និងបានបំពេញ តួនាទីគ្រប់គ្រងវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅកម្ពុជាអោយមានដំណើរការល្អ ទៅមុខឥតឈប់ឈរ និងបំរើសេវាសាធារណៈជាច្រើនដល់ប្រជាជនកម្ពុជា ។ ជាពិសេសក្រសួងបានចូលរួមរៀបចំគោលនយោបាយជាតិជាច្រើន ដើម្បីលើកកម្ពស់សេដ្ឋកិច្ចប្រទេសកម្ពុជា ឱ្យមានកំនើនទៅមុខ ឥតឈប់ឈរ ។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាស្ថាប័នមួយដែលមាន រចនាសម្ព័ន្ធ និងការអនុវត្តថវិកាបានជោគជ័យ និងស្របតាមសូចនាករដែលបានគ្រោងរបស់រដ្ឋាភិបាល ព្រមទាំងការសម្រេចបាននូវសមិទ្ធផលជាច្រើនស្របតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានខិតខំបង្កើតជាវគ្គបណ្តុះបណ្តាលទាំងក្នុង និងក្រៅប្រទេស និងសិក្ខាសាលាផ្សេងៗ ដើម្បីបំប៉នទៅដល់អង្គភាពថវិកាទាំងឡាយណាដែលអនុវត្តថវិកាដើម្បីឱ្យអង្គភាពថវិកាទាំងនោះ អនុវត្តថវិកាបានត្រឹមត្រូវតាមសូចនាករ និងចំណាយចំមុខចំណាយត្រឹមត្រូវតាមការគ្រោងទុកនាដើមឆ្នាំ។
- ការរៀបចំថវិកាកម្មវិធីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានដំណើរការនៃការអនុវត្តយ៉ាងជាក់លាក់ តាមរយៈការគ្រោងកញ្ចប់ថវិកាបីឆ្នាំរំកិល ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងការគ្រោងកញ្ចប់ថវិកា ដែលមានអគ្គនាយកដ្ឋានថវិកាចំនួន ២១ នៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលជាប្រតិបត្តិករសម្រាប់អនុវត្តថវិកាកម្មវិធីនេះ ។

- រាល់ការចំណាយក្នុងការអនុវត្តថវិកា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានប្រព័ន្ធគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុយ៉ាងជាក់លាក់គឺប្រព័ន្ធ FMIS (Financial Management Information System) មានន័យថារាល់ការចំណាយរបស់អង្គភាពណាមួយដែលអនុវត្តថវិកាកម្មវិធី អាចចំណាយទៅបានលុះណាតែ មានផែនការ និងស្របតាមកញ្ចប់ថវិកាដែលបានគ្រោងនាដើមឆ្នាំ និងចំណាយត្រឹមត្រូវជៀសវាងចំណាយមិនចាំបាច់នានា ។
- ចំពោះការអនុវត្តកញ្ចប់ថវិកាសម្រាប់ចំណាយនាឆ្នាំបន្តបន្ទាប់ អាចសម្រេចកញ្ចប់ថវិកាសម្រាប់ចំណាយនាឆ្នាំបន្តបន្ទាប់បាន លុះណាតែមានការសម្រេចពីប្រជុំជាច្រើនកម្រិតដូចនេះអាចសរបញ្ជាក់បានថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានផែនការនៃការអនុវត្តថវិកាយ៉ាងត្រឹមត្រូវក្នុងការសម្រេចនូវកំណែទម្រង់ហិរញ្ញវត្ថុសារធារណៈរបស់រដ្ឋាភិបាល តាមរយៈការអនុវត្តថវិកា កម្មវិធីបានយ៉ាងត្រឹមត្រូវ មានភាពសន្សំសំចៃ និងច្បាស់លាស់ ។

### ៣.៦.២ ចំណុចខ្សោយ

- នៅរាល់ពេលដែលគ្រោងកញ្ចប់ថវិកាសម្រាប់ការចំណាយនៅឆ្នាំថ្មី គឺនៅមានភាពយឺតយ៉ាវត្រង់ថាកញ្ចប់ថវិកាដែលបានគ្រោងសម្រាប់ចំណាយនាឆ្នាំថ្មី មិនទាន់បានអនុម័ត ហើយតារាងឧបសម្ព័ន្ធនៅមានភាពយឺតយ៉ាវ ។
- ការគ្រោងកញ្ចប់ថវិកានាដើមឆ្នាំ មិនទាន់ត្រឹមត្រូវមួយរយភាគរយ ដូចទៅនឹងអ្វីដែលបានគ្រោងជាហេតុធ្វើអោយមាននិយ័តភាពថវិកាច្រើនដង ។
- នាដើមឆ្នាំ២០១៦ ការបង្កើតរជ្ជទេយ្យបុរេប្រទាន សម្រាប់អង្គភាពថវិកានៃ កសហវ. មានភាពយឺតយ៉ាវ ដោយមូលហេតុកង្វះការណែនាំច្បាស់លាស់អំពីទម្រង់ និងបែបបទនៃការចុះហត្ថ-លេខាលើតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ពីអគ្គនាយកដ្ឋានជំនាញពាក់ព័ន្ធ ។
- ការបោះផ្សាយអាណត្តិបើកប្រាក់បង្គរនៅចុងឆ្នាំ
- ការផ្តល់ជូនសម្ភារៈការិយាល័យពុំទាន់ពេលវេលា
- វិធាន និងនីតិវិធីអនុវត្តថវិកាកម្មវិធីនៅពុំទាន់ពេញលេញ ពាក់ព័ន្ធកិច្ចសម្របសម្រួលជាមួយអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធ
- គុណភាពនៃការរៀបចំនៅមានកម្រិត ទាំងផ្នែកហិរញ្ញវត្ថុ និងសមិទ្ធកម្ម
- ភាពជាម្ចាស់ក្នុងការចូលរួមនៃអង្គភាពថវិកាមួយចំនួននៅមានកម្រិត

# សេចក្ដីសន្និដ្ឋាន
# និងអនុសាសន៍

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវពីប្រធានបទស្តីពី "ការអនុវត្តថវិកាកម្មវិធីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួចមកឃើញថាវាគឺជា មធ្យោបាយមួយដ៏មានប្រសិទ្ធភាពសម្រាប់គាំទ្រយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដើម្បីជម្រុញឱ្យមានឃើញពីតម្លាភាពនៃការប្រើប្រាស់ថវិការបស់រដ្ឋ។ ដើម្បីឱ្យមានសុក្រិត្យភាពនេះ រដ្ឋាភិបាលបានដាក់ចេញវឌ្ឍនភាពនៃការកែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលមានអភិក្រម ៤ដំណាក់កាលក្នុង ៤ជំហាន រួមមាន៖ ដំណាក់កាលទី១ (២០០៥-២០០៨) ជំហានទី១ ភាពជឿទុកចិត្តនៃថវិកា ដំណាក់កាលទី២ (២០០៩-២០១៥) ជំហានទី២ គណនេយ្យភាពហិរញ្ញវត្ថុ ដំណាក់កាលទី៣ ជំហានទី៣ (២០១៦-២០២០) ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងដំណាក់កាលទី៤ ជំហានទី៤ (២០២០-២០២៥) គណនេយ្យភាពចំពោះសមិទ្ធកម្ម។ ក្នុងន័យផងដែរសម្រាប់ឆ្នាំ២០១៦ ការអនុវត្តថវិការបស់រដ្ឋាភិបាលបានឆ្លុះបញ្ចាំងឱ្យឃើញពីភាពស៊ីគ្នានៃគោលបំណងគោលនយោបាយរបស់រដ្ឋាភិបាល ដែលបានដាក់ចេញនូវគោលបំណងគោលនយោបាយទី១ និងគោលបំណងគោលនយោបាយទី២ ចែកចេញជា កម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាព ។

នៅពេលរដ្ឋាភិបាលធ្វើផែនការយុទ្ធសាស្ត្រថវិកា ការគ្រោងកញ្ចប់ថវិកា ចំណូល-ចំណាយបានត្រឹមត្រូវ នោះវានឹងផ្តល់ផលត្រឡប់មកវិញឱ្យឃើញតាមរយៈ ចំណូលជាតិមានការកើនឡើង ទោះបីជាខ្វះការឧបត្ថម្ភធនពីដៃគូរអភិវឌ្ឍន៍ ក៏រដ្ឋនៅមានលទ្ធភាពគ្រប់គ្រាន់សម្រាប់បន្តយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ការបន្តកើនឡើងនៃសេដ្ឋកិច្ចជាតិ តាមរយៈយុទ្ធសាស្ត្រពង្រឹងផ្នែកអប់រំកាន់តែមានកម្រិតខ្ពស់ សេវាសាធារណៈកាន់តែមានប្រសិទ្ធភាព កាន់បន្ថយភាពក្រីក្រ និងអំពើពុករលួយទាំងនេះហើយ សុទ្ធសឹងជាផលនៃថវិកាកម្មវិធី ។ ហេតុដែលស្តែងចេញឱ្យឃើញលទ្ធផល ដូចខាងលើ ព្រោះក្នុងដំណាក់កាលរៀបចំកញ្ចប់ថវិកាយើងឃើញថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដាក់ឱ្យអង្គភាពថវិកានីមួយៗ ធ្វើសេចក្តីព្រាងពីចំណាយជាអាទិភាពរបស់ខ្លួន ទើបដាក់ចូលក្នុងកិច្ចប្រជុំកម្រិតថ្នាក់បច្ចេកទេស ដែលដឹកនាំដោយអគ្គនាយកដ្ឋានថវិកា និងបន្តដាក់ចូលក្នុងកិច្ចប្រជុំកម្រិតថ្នាក់ដឹកនាំ ដឹកនាំដោយឯកឧត្តមទេសរដ្ឋមន្ត្រី ដាក់ជូនរដ្ឋសភាដើម្បីអនុម័តថវិកាប្រចាំឆ្នាំ ។ ទន្ទឹមនឹងនេះក៏បង្កើតឱ្យមានវិន័យក្នុងការគ្រប់គ្រងហិញ្ញវត្ថុសាធារណៈ (តុល្យភាព/ ចីរភាព) បង្កើតប្រសិទ្ធភាពវិភាជ(វិភាជចំគោលដៅអាទិភាព) និងបង្កើនប្រសិទ្ធភាពបច្ចេកទេស និងប្រតិបត្តិ

ការចំណាយ ។ វាក៏ជាប្រព័ន្ធថវិកាមួយផ្តោតលើធាតុចូល និងគ្រប់គ្រងដែលផ្តោតលើ ធាតុចេញ (លទ្ធផល/សមិទ្ធកម្ម) និងមានលក្ខណៈវិសហាមជ្ឈការ និងវិមជ្ឈការសមស្រប ។

ចំពោះការអនុវត្តថវិកាកម្មវិធីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រចាំឆ្នាំ២០១៦ សង្កេតឃើញថា មានភាពល្អប្រសើរ។ នៅតាមបណ្តាអង្គភាពថវិកាបានអនុវត្តចំណាយរបស់ខ្លួនបានល្អច្រើនពោលគឺ លើសពី ៨៥% នៃឥណទានថ្មី ។ ទន្ទឹមនឹងនេះក៏លេចឡើងនូវបញ្ហាមួយចំនួនដែលរារាំងក្នុងដំណាក់កាលអនុវត្តផងដែរ ដូចជា ការយឺតយ៉ាវក្នុងការទូទាត់ ការយល់ដឹង និងជំនាញរបស់មន្ត្រីនៅមានកម្រិត ខ្វះបទពិសោធន៍ និងការយល់ដឹងពីនីតិវិធីនៃការទូទាត់ថវិកា នីតិវិធីនៃការទូទាត់ថវិកាមានច្រើនដំណាក់កាល ធ្វើឱ្យមានការលំបាកក្នុងការ ផ្គត់ផ្គង់ទំនិញ និងសេវាកម្ម ។ ពិបាកនឹងព្យាករណ៍ រាល់សកម្មភាពដែលអាចកើតឡើងជាក់ស្តែង សកម្មភាពខ្លះមិនបានគ្រោងតែត្រូវចំណាយ ធ្វើឱ្យចង្អោមសកម្មភាពខ្លះថវិកាច្រើន ដែលតម្រូវឱ្យ ធ្វើបែបបទសម្រាប់ធ្វើនិយ័តកម្មថវិកា ។ ទំហំ នឹងការងារក្នុងនាយកដ្ឋានខ្លះមានការកើនឡើងខ្ពស់ ។

សរុបសេចក្តី ការអនុវត្តថវិកាកម្មវិធីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិតជាទទួលបានផលល្អប្រសើរច្រើន និងមានចំណុចខ្វះខាតមួយចំនួនតូច ដែលក្រសួងនឹងបន្តប៉ះប៉ូវថែមចំណុចទាំងនោះឱ្យភាពប្រសើរឡើង ។ មិនត្រឹមតែប៉ុណ្ណោះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏ជាត្រីវិស័យមួយសម្រាប់បង្ហាញផ្លូវសម្រាប់ក្រសួង ស្ថាប័ននានាមានភាពក្មេងខ្ចី ដែលបានតែកំពុងអនុវត្តថវិកាកម្មវិធីនេះ ។ និយាយជារួម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កំពុងតែរៀនខ្លួនឯងផង និងជួយបង្រៀនដល់ក្រសួង ឬស្ថាប័ននានាផងដែរ ។

## ២. ការផ្តល់អនុសាសន៍

ជាការពិតណាស់ នៅពេលមានការកែទម្រង់ ឬការផ្លាស់ប្តូរថ្មីវាពិតជាស្តែងចេញឱ្យឃើញ ពីបញ្ហាជាច្រើនស្របគ្នានឹងប្រយោជន៍ដែលកំពុងរង់ចាំនៅខាងមុខជាប្រាកដ ។ តួយ៉ាងការកែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលមានការធ្វើថវិកាកម្មវិធីជាយុទ្ធសាស្ត្រសម្រាប់គាំទ្រគោលនយោបាយជាតិ ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបន្តដំណើរឆ្ពោះទៅមុខជានិច្ច ទោះមានអ្វីកើតឡើង ក៏ត្រូវពុះពារឆ្លង និងកែលម្អរជាបណ្តើរៗ ។ ទន្ទឹមនឹងនេះដើម្បីធ្វើឱ្យ ការអនុវត្តថវិកាកម្មវិធីកាន់តែមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពថែមទៀតនោះយើងខ្ញុំសូមផ្តល់ អនុសាសន៍ក្នុងន័យស្ថាបនាដូចខាងក្រោម៖

- ការពង្រឹងបន្ថែមលើកម្រិតមន្ត្រីជំនាញផ្នែកថវិកាតាមបណ្តាអង្គភាពថវិកា ដោយមានជាការរៀបចំជាសិក្ខាសាលា ឬការប្រជុំពិភាក្សា និងវគ្គបណ្តុះបណ្តាលជាដើម។
- ការធ្វើកញ្ចប់ថវិកាសង្គ្រោះចាំបាច់មួយសម្រាប់គាំទ្រតម្រូវការជាអាទិភាពលេចឡើង ដោយគ្មានគម្រោងចំណាយក្នុងកម្មវិធី
- សម្រួលនីតិវិធីក្នុងការទូទាត់ចំណាយផ្សេង
- ការធ្វើឱ្យប្រាកដពីតម្រូវការ និងអាទិភាព វាអាចប៉ះពាល់នៅពេលថវិកាលើសមិនបានធ្វើការចំណាយ ឬចំណាយខុសគោលដៅអាទិភាព
- សុំឱ្យគ្រប់អង្គភាពថវិកាដៅស្ងូចនាករគន្លឹះ សមស្របនឹងរយៈពេលកំណត់។

# ឯកសារយោង

**ឯកសារយោង**


- សៀវភៅគោលការណ៍ណែនាំ ស្តីពីគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិការបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, សៀវភៅផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ២០១៦
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, សៀវភៅកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល ឆ្នាំ២០១៦-២០១៨
- សៀវភៅការអនុវត្ត ការវាយតម្លៃ ការត្រួតពិនិត្យការអនុវត្តថវិកាកម្មវិធីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, សេចក្តីប្រកាសលេខ២៤៩ សហវ.ប្រកចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការបង្កើតក្រុមលទ្ធកម្ម
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, សារាចរស្តីពីការបង្កើតរជ្ជទេយ្យបុរេប្រទានប្រចាំឆ្នាំ២០១៥
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ប្រកាសស្តីពីកិច្ចលទ្ធកម្មសាធារណៈឆ្នាំ ២០១៥- ២០១៦
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ប្រកាសស្តីពីការបង្កើតរជ្ជទេយ្យបុរេប្រទាន និងរជ្ជទេយ្យបុរេប្រទានរងប្រចាំឆ្នាំ២០១៥
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សារាចរណ៍ណែនាំស្តីពីការរៀបចំផែនការថវិកាប្រចាំឆ្នាំ ២០១៥- ២០១៨
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ប្រកាសស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ប្រកាសស្តីសិទ្ធអំណាច និងការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិកាកម្មវិធីរបស់អង្គភាពថវិកា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ប្រកាសស្តីពីការកែសម្រួលប្រការ ៤ ប្រការ ៥ ប្រការ ១៤ ប្រការ ១៦ និងប្រការ១៧ នៃ ប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៤ ស្តីពីនីតិវិធីចំណាយតាម រជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, សារាចរណ៍ណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ ២០១៥

# ឧបសម្ព័ន្ធ

# អង្គការលេខរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ០៤ ស.ជណន

# សារាចរណែនាំ

## ស្ដីពី

## ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦

### ១. សេចក្ដីផ្ដើម

មាត្រា៣៩ នៃច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បានចែងអំពីប្រតិទិនសម្រាប់រៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំជា៣ដំណាក់កាលគឺ (១)- **ដំណាក់កាលទី១:** ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ពីខែមីនាដល់ខែឧសភា (២)- **ដំណាក់កាលទី២:** ការរៀបចំកញ្ចប់ថវិកា ពីខែមិថុនា ដល់ខែកញ្ញា និង (៣)- **ដំណាក់កាលទី៣:** ការអនុម័តថវិកា ពីខែតុលា ដល់ ខែធ្នូ។ សម្រាប់ដំណាក់កាលទី១នេះ រាជរដ្ឋាភិបាលតាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដាក់ចេញរួចហើយនូវក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ដើម្បីឱ្យក្រសួង ស្ថាប័ននីមួយៗមានមូលដ្ឋានសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦ និងការលើកគម្រោងថវិកាប្រចាំឆ្នាំ២០១៦។ ហេតុនេះសម្រាប់ជំហានបន្ទាប់នៃដំណាក់កាលទី១ រាជរដ្ឋាភិបាលត្រូវដាក់ចេញនូវសារាចរណែនាំស្ដីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦នេះ ដើម្បីផ្ដល់គោលការណ៍ណែនាំ និងមគ្គុទ្ទេសក៍បច្ចេកទេសសំខាន់ៗសម្រាប់ជាជំនួយដល់គ្រប់ក្រសួង ស្ថាប័នក្នុងការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រថវិកាប្រចាំឆ្នាំ ដែលជាផែនការថវិការយៈពេលមធ្យមបីឆ្នាំរំកិលដែលក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលស្ថិតក្រោមក្រសួង ស្ថាប័ននីមួយៗត្រូវរៀបចំក្នុងដំណាក់កាលដំបូងនៃដំណើរការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ។ ដោយឡែកចំពោះការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានសារាចរណែនាំដោយឡែកមួយទៀតស្របតាមច្បាប់ស្ដីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១។

ផែនការយុទ្ធសាស្ត្រថវិកាក៏ជាឧបករណ៍ដ៏សំខាន់មួយសម្រាប់÷ (១)-ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ (២)-បង្កើនសុក្រឹតភាពក្នុងការគណនាតម្រូវការថវិកា (៣)-ជាមូលដ្ឋានសម្រាប់ពន្យល់និងធ្វើអំណះអំណាងលើតម្រូវការថវិកា (៤)-ធានានិរន្តរភាពនៃកម្មវិធី/យុទ្ធសាស្ត្រអាទិភាពរបស់ក្រសួង ស្ថាប័ន ដើម្បីសម្រេចគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័នដែលបានដាក់ចេញ និង (៥)-ជាមូលដ្ឋានសម្រាប់វាយតម្លៃលើអាទិភាពក្នុងការកំណត់កញ្ចប់ថវិកា និងការវិភាជថវិកាប្រចាំឆ្នាំ។ ដូច្នេះ ផែនការយុទ្ធសាស្ត្រថវិកាត្រូវឆ្លុះបញ្ចាំងឱ្យឃើញច្បាស់អំពីគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ននីមួយៗ ភាពច្បាស់លាស់នៃកម្មវិធី/យុទ្ធសាស្ត្រអាទិភាព សូចនាករ និង គោលដៅសូចនាករសម្រាប់វាស់វែងលទ្ធផលនៃការអនុវត្តថវិកា

ដើម្បីចូលរួមចំណែកសម្រេចគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញក្នុង “**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣**” និងផែនការសកម្មភាពដែលបានដាក់ចេញក្នុង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**។ ក្នុងន័យនេះ ក្រសួង ស្ថាប័នមួយត្រូវមានផែនការយុទ្ធសាស្ត្រថវិកាតែមួយ ដែលគ្របដណ្តប់ទាំងថវិការដ្ឋបាលកណ្តាល និងថវិកាមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទក្រសួង ស្ថាប័ននោះ។

ទន្ទឹមនឹងនេះ ភាពគ្រប់ជ្រុងជ្រោយនៃថវិកា តាមរយៈសមាហរណកម្មពិតប្រាកដរវាងថវិកាចរន្ត និងថវិកាមូលធន ព្រមទាំងរវាងថវិកាជាតិ និង ថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ គឺជាកត្តាមិនអាចខ្វះបានឡើយដើម្បីធ្វើឱ្យផែនការយុទ្ធសាស្ត្រថវិកាមានគុណភាពនិងអាចក្លាយជាឧបករណ៍ និងយន្តការជាក់ស្តែងសម្រាប់ការលើកកម្ពស់ប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធិក្នុងការវិភាជនិងគ្រប់គ្រងថវិកា។ ក្នុងន័យនេះ ***ក្រសួង ស្ថាប័ននីមួយៗចាំបាច់ត្រូវរៀបចំក្រុមការងារថវិការបស់ខ្លួនដែលមានសមាសភាពមកពី នាយកដ្ឋានថវិកា/ហិរញ្ញវត្ថុ/និងគណនេយ្យ នាយកដ្ឋានផែនការ អង្គភាពជំនាញ និងអង្គភាពគ្រប់គ្រងគម្រោង*** មានដំណើរការដោយសកម្មប្រកបដោយការទទួលខុសត្រូវ។ **ក្រុមការងារថវិកា** ត្រូវខិតខំធានាឱ្យធនធានទាំងអស់ ក៏ដូចជាសកម្មភាពការងារទាំងអស់របស់ក្រសួង ស្ថាប័នខ្លួន ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងរចនាសម្ព័ន្ធនៃផែនការយុទ្ធសាស្ត្រថវិកា សំដៅធានាឱ្យការវិភាជថវិកាមានប្រសិទ្ធភាព (ចំសេចក្តីត្រូវការពិតប្រាកដ) និងមានតុល្យភាពក្នុងការវិភាជថវិកាទៅតាមនិងរវាងគោលបំណងគោលនយោបាយ និងរវាងកម្មវិធី/យុទ្ធសាស្ត្រអាទិភាព នៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័នដែលបានរៀបចំ។

ចាប់តាំងពីត្រូវបានដាក់ឱ្យអនុវត្តជាលើកដំបូងក្នុងឆ្នាំ២០០៨ មកទល់នឹងពេលនេះការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ជារួមត្រូវបានកែលម្អជាលំដាប់។ ទោះជាយ៉ាងនេះក្តី ការងារនេះនៅតែមិនទាន់បានដល់កម្រិតដែលរាជរដ្ឋាភិបាលចង់បាននៅឡើយទេ ជាពិសេសក្រសួង ស្ថាប័នចាំបាច់ត្រូវកែលម្អថែមទៀតនូវផែនការយុទ្ធសាស្ត្រថវិកាស្របទៅតាមស្មារតី និងលទ្ធផលនៃការរៀបចំថវិកាឆ្នាំ២០១៥កន្លងទៅ។ លើសពីនេះនៅពេលដែលកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បាននិងកំពុងស្ថិតក្នុងដំណាក់កាលទី២ថ្មីនៃការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ និងការត្រៀមចូលដំណាក់កាលទី៣គឺការបង្កើនការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងស្របតាម “ទិសដៅជាយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា២០១៣-២០២០” ដែលជាទិសដៅនៃការផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រងថវិកាជាជំហានៗ ពីការផ្តោតលើធាតុចូលនិងមជ្ឈការ ឆ្ពោះទៅរកប្រព័ន្ធថវិកាថ្មីគឺការផ្តោតលើលទ្ធផលឬសមិទ្ធកម្ម និងវិមជ្ឈការ ក្រសួង ស្ថាប័នអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកា ត្រូវបានបង្កើនពីចំនួន១០ នៅឆ្នាំ២០១៥ ដល់ចំនួន២៥ នៅឆ្នាំ២០១៦ រួមមាន÷

- ក្រសួងចំនួន១០ អនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកា ក្នុងឆ្នាំ២០១៥រួមមាន÷ ក្រសួងអប់រំ យុវជននិងកីឡា, ក្រសួងសុខាភិបាល, ក្រសួងកិច្ចការនារី, ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិង សំណង់, និងក្រសួងយុត្តិធម៌។
- ក្រសួង ស្ថាប័នថ្មីចំនួន ១៥ និងមន្ទីរជំនាញរាជធានី ខេត្តពាក់ព័ន្ធ ដែលត្រូវបានដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកានៅឆ្នាំ២០១៦ ហើយដែលត្រូវចាប់ផ្តើមរៀបចំថវិកា-

កម្មវិធីនៅឆ្នាំ២០១៥ ស្របតាមប្រតិទិននៃការរៀបចំថវិកាប្រចាំឆ្នាំ រួមមាន÷ តុលាការកំពូល, សាលាឧទ្ធរណ៍, អគ្គលេខាធិការដ្ឋានរដ្ឋសភា, អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា, អាជ្ញាធរសវនកម្មជាតិ, អង្គភាពប្រឆាំងអំពើពុករលួយ, ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, ក្រសួងទេសចរណ៍, ក្រសួងពាណិជ្ជកម្ម, ក្រសួងធនធានទឹកនិងឧតុនិយម, ក្រសួងព័ត៌មាន, រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល, ក្រសួងបរិស្ថាន, ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា, និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

ស្របតាមទស្សនទាននៃការគ្រប់គ្រងថវិកាផ្អែកលើលទ្ធផល/សមិទ្ធកម្ម សិទ្ធិអំណាចក្នុងការគ្រប់គ្រងថវិកា និងលើការអនុវត្តថវិកា នឹងត្រូវផ្ទេរជាបណ្តើរៗពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទៅក្រសួងសាមី ចំណែកឯសិទ្ធិនៃការទទួលខុសត្រូវក៏ត្រូវផ្ទេរជាបណ្តើរៗដែរ ពីនាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួង ស្ថាប័ន ទៅអង្គភាពថវិការបស់ក្រសួង ស្ថាប័ន។ ក្នុងន័យនេះ ក្រសួង ស្ថាប័នទាំងនេះកាន់តែមានភាពចាំបាច់បំផុតក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាប្រកបដោយគុណភាព។

ក្នុងបរិការណ៍នេះ ដើម្បីជួយឱ្យក្រសួង ស្ថាប័នក្នុងការយកចិត្តទុកដាក់លើកកម្ពស់គុណភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦ ឱ្យបានប្រសើរថែមទៀត រាជរដ្ឋាភិបាលសូមធ្វើការណែនាំដល់គ្រប់ក្រសួងស្ថាប័ន ដូចតទៅ÷

## ២. ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ

ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ មានតួនាទីផ្តល់ជាទស្សនវិស័យទូលំទូលាយនៃការអភិវឌ្ឍសេដ្ឋកិច្ច និងកំណត់ពីការរំពឹងទុកផ្នែកគោលនយោបាយដែលរាជរដ្ឋាភិបាលមានលទ្ធភាពអាចនឹងសម្រេចបាន ហើយតាមរយៈនេះបង្កើតបានជាលំហថវិការួម សម្រាប់ក្រសួង-ស្ថាប័នពាក់ព័ន្ធអាចកំណត់ទិសដៅការងាររយៈពេលខ្លី និងមធ្យមរបស់ខ្លួន។ ទន្ទឹមនឹងនេះ ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ក៏កំណត់អំពីលទ្ធភាពផ្នែកធនធាន និងអាទិភាពគោលនយោបាយចម្បងៗដើម្បីសម្រេចគោលដៅរួមរបស់រាជរដ្ឋាភិបាល។ ដូចនេះអាចនិយាយបានថា នៅក្នុងដំណើរការនៃការរៀបចំផែនការថវិកា ការកំណត់ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ គឺជាយន្តការពីលើចុះក្រោម ចំណែកឯការរៀបចំផែនការយុទ្ធសាស្ត្រថវិកា គឺជាយន្តការពីក្រោមឡើងលើ។ យន្តការទាំងពីរនេះ គឺមានភាពចាំបាច់មិនអាចខ្វះបាន ដើម្បីធានាប្រសិទ្ធភាព និងភាពប្រាកដប្រជាអំពីលទ្ធភាពថវិកា និងការរៀបចំថវិកា។ នៅក្នុងន័យនេះ ដើម្បីជាមូលដ្ឋានសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦ រាជរដ្ឋាភិបាលសូមគូសរំលេចនូវខ្លឹមសារស្នូលនៃក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដូចខាងក្រោម÷

### ២.១. ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

ផ្អែកលើនិន្នាការសេដ្ឋកិច្ចឆ្នាំកន្លងទៅ ស្ថានភាពល្អប្រសើរនៃសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសកល និងសកម្មភាពសេដ្ឋកិច្ចដ៏រស់រវើកដើមឆ្នាំនេះ កំណើនសេដ្ឋកិច្ចឆ្នាំ២០១៥ ត្រូវបានព្យាករថាអាចសម្រេចបានក្នុងរង្វង់៧% ដូចតាមការគ្រោងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥។ ចំពោះកំណើនសេដ្ឋកិច្ច

សម្រាប់ឆ្នាំ២០១៦វិញ តាមការព្យាករអាចនឹងបន្តសម្រេចបានក្នុងរង្វង់៧%។ កំណើននេះនឹងបានមកពីកំណើនវិស័យកសិកម្មប្រមាណ៤,៣% វិស័យឧស្សាហកម្មអាចនឹងមានកំណើនប្រមាណ៩,៦% ដែលក្នុងនោះវិស័យវាយនភណ្ឌនឹងអាចសម្រេចបានប្រមាណ៨,៤% និងវិស័យសេវាកម្មគ្រោងថាអាចនឹងសម្រេចបានកំណើនប្រមាណតែ៦,៥% ប៉ុណ្ណោះ។

អតិផរណានៅឆ្នាំ២០១៥ តាមការព្យាករនឹងរក្សាបានក្នុងកម្រិត៣,៥%គឺដូចទៅនឹងការព្យាករក្នុងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ហើយនឹងបន្តរក្សាកម្រិតថេរក្នុងរង្វង់៣,៥% ដដែលក្នុងឆ្នាំ២០១៦។ អត្រាប្តូរប្រាក់នៅឆ្នាំ២០១៥ តាមការប៉ាន់ស្មាននឹងមានតម្លៃជាមធ្យម៤ ០៥០រៀល ក្នុង១ដុល្លារអាមេរិក ដូចគ្នានឹងការព្យាករក្នុងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥។ តាមការព្យាករនៅឆ្នាំ២០១៦ អត្រាប្តូរប្រាក់មធ្យមប្រចាំឆ្នាំនឹងនៅតែមានតម្លៃ៤០៥០រៀលក្នុង១ដុល្លារអាមេរិក ដែលកម្មវត្ថុចម្បងគឺដើម្បីរក្សាតុល្យភាពនៃការប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុក ការប្រកួតប្រជែងជាមួយដៃគូពាណិជ្ជកម្មលើពិភពលោក និងការបង្កើនជំនឿទៅលើការប្រើប្រាស់រូបិយប័ណ្ណក្នុងស្រុក។

ឱនភាពគណនីចរន្តនៅឆ្នាំ២០១៥ តាមការប៉ាន់ស្មាននឹងមានកម្រិត១០,៣%នៃផ.ស.ស គឺបានប្រសើរឡើងធៀបនឹងឆ្នាំ២០១៤ ដែលមានកម្រិត១១,២%នៃផ.ស.ស។ ទន្ទឹមនេះ តាមការព្យាករនៅឆ្នាំ២០១៦ ឱនភាពគណនីចរន្តនឹងបន្តធ្លាក់ចុះទៀតមកត្រឹម៩,៧%នៃផ.ស.ស។ និន្នាការនៃការធ្លាក់ចុះឱនភាពគណនីចរន្ត ដោយសារសមត្ថភាពនាំចេញរបស់កម្ពុជាមានការកើនឡើងជាលំដាប់ ទន្ទឹមនឹងផលិតផលនិងវត្ថុធាតុដើមមួយចំនួនចាប់ផ្តើមមានមូលដ្ឋានផលិតនៅក្នុងស្រុកជំនួសការនាំចូលជាបណ្តើរៗ។ នៅឆ្នាំ២០១៥ ទុនបម្រុងនឹងមានទំហំ៥ ១៤៤លានដុល្លារអាមេរិក និងអាចកើនឡើងលើសពី៥ ៧៣៩លានដុល្លារអាមេរិក នៅឆ្នាំ២០១៦ ដែលធានាបានប្រមាណជាង៤,៥ ខែ នៃការនាំចូលទំនិញ និងសេវាប្រើប្រាស់ក្នុងស្រុក។

## ២.២ ក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

ដោយផ្អែកលើមូលដ្ឋាននៃ **"យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣"** និង **"ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨"** គោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ឆ្នាំ២០១៦-២០១៨ ត្រូវបានកំណត់គោលដៅសំខាន់ៗដូចតទៅ÷

- បន្តធានាអនុវត្តគោលនយោបាយដើម្បីជំរុញកំណើន ការងារ សមធម៌និងប្រសិទ្ធភាពដើម្បីបន្តកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និង បែងចែកផ្លែផ្កានៃកំណើនប្រកបដោយសមធម៌ដល់គ្រប់ស្រទាប់វណ្ណៈនៃប្រជាជន
- បន្តធានាសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយបរិយាប័ន្ន និងចីរភាព ព្រមទាំងធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងស្ថិរភាពហិរញ្ញវត្ថុ ក្នុងបរិការណ៍នៃអត្រាអតិផរណាទាបនិងអត្រាប្តូរប្រាក់មានស្ថិរភាព
- បន្តផ្តល់អាទិភាពដល់ការតម្លើងប្រាក់បៀវត្សរបស់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធឆ្ពោះទៅសម្រេចគោលដៅឱ្យបានជាង ១ លានរៀលនៅឆ្នាំ២០១៨ ដោយផ្សារភ្ជាប់ទៅនឹងការកែទម្រង់ប្រព័ន្ធបៀវត្ស និង ការកែទម្រង់រដ្ឋបាលសាធារណៈ ពិសេសការអនុវត្តកម្មវិធីជាតិ

កំណែទម្រង់រដ្ឋបាលសារណៈ២០១៥-២០១៨, ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ

- បន្តធានាអនុវត្តកម្មវិធីកែទម្រង់ចាំបាច់នានារបស់រាជរដ្ឋាភិបាលឱ្យមានលក្ខណៈស៊ីជម្រៅ និងទទួលបានលទ្ធផលជាផ្លែផ្កាជាក់ស្តែងជាបណ្តើរៗ រួមមាន ការកែទម្រង់ប្រព័ន្ធកងកម្លាំងប្រដាប់-អាវុធ ការកែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ការកែទម្រង់ប្រព័ន្ធយុត្តិធម៌និងតុលាការ ការកែទម្រង់ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ
- បន្តជំរុញការអភិវឌ្ឍធនធានមនុស្សតាមរយៈការលើកកម្ពស់គុណភាពអប់រំ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនិងបច្ចេកទេស ព្រមទាំងការលើកកម្ពស់សេវាសុខាភិបាល
- បន្តជំរុញការលើកទឹកចិត្តក្នុងការងារស្រាវជ្រាវ និងការអភិវឌ្ឍផ្នែកបច្ចេកទេស និងវិទ្យាសាស្ត្រ
- បង្កើនប្រសិទ្ធភាពនៃការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធចាំបាច់ទាំងផ្នែករឹង និងផ្នែកទន់សម្រាប់គាំទ្រកំណើន និងការអភិវឌ្ឍ
- ធានាការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ប្រកបដោយប្រសិទ្ធភាព
- បន្តការជំរុញការអភិវឌ្ឍវិស័យកសិកម្ម ជាពិសេសបន្តធានាការអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ ការចិញ្ចឹមសត្វ និងវារីវប្បកម្ម ព្រមទាំងផលិតកម្មម្ហូបអាហារ
- ពង្រឹង និងពង្រីកលំហថវិកា រួមទាំងយន្តការគ្រប់គ្រងវិបត្តិដើម្បីទប់ទល់វិបត្តិកលិយុគ និងហានិ-ភ័យផ្សេងៗដែលអាចកើតមានឡើងជាយថាហេតុ ជាពិសេសបំពេញឡើងវិញនូវប្រាក់បញ្ញើរដ្ឋ ព្រមទាំងកាត់បន្ថយការពឹងផ្អែកលើហិរញ្ញប្បទានក្រៅប្រទេស
- បន្តពង្រឹងការអនុវត្តគោលនយោបាយគ្រប់គ្រងបំណុលសាធារណៈឱ្យស្ថិតក្នុងកម្រិតមួយដែលអាចគ្រប់គ្រងបាន និងប្រកបដោយចីរភាព
- បន្តពង្រឹងស្ថាប័នជាតិ និងប្រព័ន្ធអភិបាលកិច្ច ដើម្បីធានាប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព និងធានាបានសមធម៌សង្គម ហើយផ្តល់ឱកាសស្មើគ្នា និងប្រកបដោយសមធម៌
- លើកកម្ពស់គុណភាព ពង្រីកការទទួលបាន ភាពពេញចិត្ត និងប្រសិទ្ធភាពនៃសេវាសាធារណៈ
- ធានាបន្តការពារឱ្យបានទាំងស្រុងនូវអធិបតេយ្យ និងបូរណភាពទឹកដី ដើម្បីបន្តរក្សាសន្តិភាព សន្តិសុខ សុវត្ថិភាព សេរីភាព ប្រជាធិបតេយ្យ និងសុភមង្គលជូនប្រជាពលរដ្ឋ។

ដើម្បីសម្រេចបានតាមគោលដៅខាងលើ រាជរដ្ឋាភិបាលបានកំណត់គោលដៅស្ទូចនាករហិរញ្ញវត្ថុសាធា-រណៈ ដូចខាងក្រោមនេះ÷

- ធានាកំណើនចំណូលចរន្តប្រចាំឆ្នាំបន្ថែម០,៥ពិន្ទុភាគរយនៃផ.ស.ស ដើម្បីឈានទៅសម្រេចឱ្យបាន១៧,៣៥% នៃផ.ស.ស នៅ២០១៦ ក្នុងនោះ គម្រោងសម្រាប់ថ្នាក់ជាតិ គឺ ១៦,៤២% នៃផ.ស.ស និងគម្រោងសម្រាប់ថ្នាក់ក្រោមជាតិ គឺ០,៩៣% នៃផ.ស.ស។ ចំណូលពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រូវគ្រោងសម្រេចឱ្យបាន៨,៤២%នៃផ.ស.ស ចំណូលពីអគ្គនាយកដ្ឋានពន្ធដារ ត្រូវគ្រោងសម្រេចឱ្យបាន៦,៥៩% នៃផ.ស.ស និង ចំណូលមិនមែនសារពើពន្ធនិងចំណូលពន្ធផ្សេងទៀត ត្រូវគ្រោងសម្រេចឱ្យបាន២,៣៥% នៃ

ផ.ស.ស។ ឈរលើមូលដ្ឋាននេះ ចំណូលក្នុងស្រុកសរុបសម្រាប់ឆ្នាំ២០១៦ ត្រូវគ្រោងសម្រេចឱ្យបានស្មើនឹង ១៧,៥១% នៃផ.ស.ស។

○ ចំណាយសរុបនៅឆ្នាំ ២០១៦ នឹងកំណត់ក្នុងរង្វង់ ២១,២៨% នៃផ.ស.ស ក្នុងនោះចំណាយសម្រាប់រដ្ឋបាលថ្នាក់ជាតិគ្រោង២០,៣៤% នៃផ.ស.ស និង ចំណាយសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិគ្រោង ១,៥៦%នៃផ.ស.ស (ឧបត្ថម្ភធនដល់ថ្នាក់ក្រោមជាតិ ចំនួន ០,៦៣% នៃផ.ស.ស)។ ចំណាយចរន្តសរុបត្រូវគ្រោងក្នុងកម្រិត១៣,២៨%នៃផ.ស.ស ដែលចំណាយបន្ទុកបុគ្គលិកគ្រោងប្រមាណ៤៨,៤៨%នៃចំណាយចរន្តសរុប (ពោលគឺមិនឱ្យលើស ៥០%) ឬស្មើប្រមាណ៦,៤៤% នៃផ.ស.ស ដោយផ្ដោតអាទិភាពលើការបង្កើនបៀវត្សសម្រាប់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ដើម្បីបង្កើនផលិតភាពការងារ និងពង្រឹងការផ្ដល់សេវាសាធារណៈ ទន្ទឹមនឹងការគិតគូរផងដែរចំពោះចំណាយមិនមែនបៀវត្សមួយចំនួន ពិសេសតម្រូវការចំណាយសម្រាប់ទ្រទ្រង់ដល់ការកែទម្រង់នានា ព្រមទាំងតម្រូវការចំណាយក្នុងការអនុវត្តគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាល។ ទន្ទឹមនេះដែរ ចំណាយមូលធនគ្រោងប្រមាណជា៨,០% នៃផ.ស.ស សម្រាប់ឆ្នាំ២០១៦។

○ ក្នុងគម្រោងក្របខណ្ឌចំណូល និងចំណាយខាងលើ អតិរេកថវិកាចរន្តសម្រាប់ឆ្នាំ២០១៦ ត្រូវស្មើនឹង៤,០៧%នៃផ.ស.ស ចំណែកឱនភាពថវិកាសរុបត្រូវបានកាត់បន្ថយត្រឹម ៣,៧៧%នៃផ.ស.ស។ ទំហំតុល្យភាពខាងលើគឺអាចធានាបាននូវចីរភាពថវិកា ដែលជាគន្លឹះរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចសម្រាប់ផ្ដល់ភាពអនុគ្រោះដល់កំណើន ជាពិសេសបង្កើននូវលំហថវិកា។ ក្របខណ្ឌហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៤-២០១៨ មានជូនភ្ជាប់ជាឧបសម្ព័ន្ធនៃសារាចរនេះ។

ដើម្បីធានាបាននូវការអនុវត្តទៅតាមគោលដៅខាងលើ និងដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៥ ការគ្រោងថវិកាឆ្នាំ២០១៦ និងពេលខាងមុខ ត្រូវរៀបចំឡើងលើមូលដ្ឋានយុទ្ធសាស្ត្រ និងក្របខណ្ឌនៃវិធានការ ដូចខាងក្រោម÷

**ផ្នែកចំណូល**

ជារួម ក្នុងកិច្ចខិតខំប្រឹងប្រែងប្រមូលចំណូលទៅតាមគោលដៅកំណត់ខាងលើ រាជរដ្ឋាភិបាលពុំមានគោលការណ៍បង្កើតប្រភេទពន្ធថ្មី ឬដំឡើងអត្រាពន្ធនិងអាករបន្ថែមដល់ប្រជាជន និងធុរជននោះទេ ពោលគឺរាជរដ្ឋាភិបាលនឹងផ្ដោតលើការពង្រឹងការអនុវត្តគោលនយោបាយ និងច្បាប់ដែលមានស្រាប់ តាមរយៈការអនុវត្តវិធានការយ៉ាងម៉ឺងម៉ាត់ និងមុតស្រួច ទាំងតាមវិធានការរដ្ឋបាល និងវិធានការគោលនយោបាយទាំងសម្រាប់រយៈពេលខ្លី និងមធ្យម ជាពិសេសការលើកកម្ពស់វប្បធម៌បង់ពន្ធ ការបង្ក្រាបអំពើរត់ពន្ធ និងការគេចវេសពន្ធគ្រប់រូបភាពឱ្យដល់ឫសគល់ ព្រមទាំងការកែលម្អអភិបាលកិច្ចក្នុងការប្រមូលចំណូល ទាំងក្នុងផ្នែកគយ និងផ្នែកពន្ធដារ ព្រមទាំងផ្នែកមិនមែនសារពើពន្ធ ក្នុងនោះ រួមមានទាំងការកែសម្រួល និងការធ្វើសាមញ្ញកម្មនៃសេវាបង់ពន្ធ ពិសេសតាមរយៈការជំរុញអនុវត្តនូវ **យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨**។

**ក. ផ្នែកចំណូលគយ និងរដ្ឋាករ**

- បន្តពង្រឹងវិធានបង្ការ ទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធគយគ្រប់រូបភាព
- បន្តពង្រឹងការប្រកាសគយ តាមរយៈការពង្រឹងការគ្រប់គ្រងឯកសារនាំចេញ-នាំចូល និងការផ្ទៀង-ផ្ទាត់តម្លៃគិតពន្ធគយ ពិសេសចំពោះមុខទំនិញវេទយិតលើចំណូលពន្ធគយមួយចំនួន

- ពង្រឹងការកំណត់ និងធ្វើចំណាត់ថ្នាក់ហានិភ័យ តាមរយៈការកែលម្អប្រព័ន្ធគ្រប់គ្រងហានិភ័យ និងពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មានសម្ងាត់គយ
- ពង្រឹងប្រសិទ្ធភាព និងពង្រីកវិសាលភាពនៃការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ ដើម្បីបង្កើនអនុលោមភាពនៃការបំពេញកាតព្វកិច្ចបង់ពន្ធអាករគយឱ្យបានត្រឹមត្រូវ
- សិក្សា និង វាយតម្លៃពីលទ្ធភាពនៃការអនុវត្តឱ្យបានពេញលេញនូវកាតព្វកិច្ចប្រកាសតម្លៃគិតពន្ធគយលើទំនិញនាំចេញ- នាំចូល ក្រោមរបបអនុគ្រោះពន្ធតាមតម្លៃចម្លងការដើម្បីធ្វើឱ្យប្រសើរឡើងនូវការកំណត់ពន្ធគយ និងដើម្បីបញ្ចៀសនូវការបាត់បង់ចំណូល
- ជំរុញការប្រើប្រាស់ប្រព័ន្ធអាស៊ីគូដាឱ្យអស់សក្តានុពល ដើម្បីធានាឱ្យប្រព័ន្ធអាស៊ីគូដាអាចអនុវត្តបានទាំងស្រុងនូវមុខងារទាំងអស់ និងដើម្បីពង្រីកវិសាលភាពនៃការប្រើប្រាស់ប្រព័ន្ធនេះ
- ជំរុញការដាក់ឱ្យអនុវត្តប្រព័ន្ធបញ្ជរជាតិតែមួយឱ្យបានពេញលេញតាមបទប្បញ្ញត្តិជាធរមាន
- បន្តពង្រឹងយន្តការសហប្រតិបត្តិការរវាងគយនិងវិស័យឯកជន
- វាយតម្លៃរៀងរាល់ត្រីមាសលើការបាត់បង់ចំណូលពន្ធអាករគយ ពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន និងប្រទេសដៃគូផ្សេងទៀត និងស្នើឡើងនូវវិធានការសមស្រប
- រៀបចំផែនការអភិវឌ្ឍស្ថាប័ន កែលម្អការត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីកែទម្រង់គយ
- បន្តពង្រឹងក្រមសីលធម៌ និងកិរិយាមាយាទមន្ត្រីគយ។

**ខ. ផ្នែកចំណូលពន្ធដារ**

- បន្តពង្រឹងការចុះបញ្ជីពន្ធដារតាមប្រព័ន្ធថ្មី និងបន្តធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសទាំងអស់ដែលបានចុះបញ្ជីពន្ធដារក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង និងប្រមូលចំណូល
- បន្តពង្រឹង និងកែលម្អការផ្តល់សេវាដល់អ្នកជាប់ពន្ធ
- បន្តកែលម្អការចាត់ចែងលិខិតប្រកាសពន្ធ ដោយផ្តោតការយកចិត្តទុកដាក់លើ÷
  - (១)- ការរៀបចំយន្តការឱ្យអ្នកជាប់ពន្ធអាចដាក់លិខិតប្រកាសតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងបង់ប្រាក់ពន្ធតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីកាត់បន្ថយបន្ទុកចំណាយ និងពេលវេលារបស់អ្នកជាប់ពន្ធ និងរដ្ឋបាលសារពើពន្ធ
  - (២)- អនុវត្តវិធានការលុបចោលការចុះបញ្ជី ឬដកវិញ្ញាបនបត្រអាករលើតម្លៃបន្ថែមជាបណ្តោះអាសន្នចំពោះអ្នកជាប់ពន្ធ ដែលមិនបានដាក់លិខិតប្រកាសអាករលើតម្លៃបន្ថែមក្នុងរយៈពេល ៣ខែជាប់គ្នា
  - (៣)- កំណត់អត្រាគោលដៅនៃការដាក់លិខិតប្រកាស ឱ្យបានខ្ពស់ជាអតិបរមាបន្ទាប់ពីបានធ្វើការលុបឈ្មោះអ្នកជាប់ពន្ធចេញពីបញ្ជី ដើម្បីវាយតម្លៃហានិភ័យអ្នកជាប់ពន្ធឱ្យបានទាន់ពេលវេលា
- បន្តពង្រឹងប្រសិទ្ធភាព និង ធ្វើឱ្យប្រសើរឡើងនូវការធ្វើសវនកម្មពន្ធដារ ទាំងសវនកម្មមានកម្រិត និងសវនកម្មពេញលេញ ដោយផ្តោតលើ÷
  - (១)- កែលម្អវិធីសាស្ត្រកំណត់ហានិភ័យដែលមានស្រាប់ រួមទាំងជ្រើសរើសក្រុមហ៊ុនធំៗជាអាទិភាពក្នុងការធ្វើសវនកម្ម និងរៀបចំសារាចរណែនាំដើម្បីដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវស្តង់ដារ

រួមដែលមានកំណត់ត្រាបង្ហាញពីឥរិយាបថហានិភ័យរបស់អ្នកជាប់ពន្ធ ដើម្បីប្រើជាការជ្រើសរើសអ្នកជាប់ពន្ធដែលត្រូវធ្វើសវនកម្ម

(២)- រៀបចំរបាយការណ៍លទ្ធផលសវនកម្ម និងផ្តល់មតិត្រលប់វិញ ដើម្បីផ្ទៀងផ្ទាត់ការកំណត់ហានិភ័យ មុនពេលចុះសវនកម្មកន្លងមកសម្រាប់កែលម្អវិធីសាស្ត្រកំណត់ហានិភ័យនៅពេលក្រោយ និងធ្វើការវាយតម្លៃឥរិយាបថអ្នកជាប់ពន្ធ

(៣)- ជំរុញការអនុវត្តកាតព្វកិច្ចផ្តល់របាយការណ៍ហិរញ្ញវត្ថុ ដែលធ្វើសវនកម្មដោយស្នងការគណនេយ្យឯករាជ្យ ដើម្បីពង្រឹងការគោរពច្បាប់និងបន្ថយបន្ទុកសវនកម្ម

(៤)- រៀបចំសារាចរណែនាំស្តីពីការធ្វើសវនកម្មលើវិស័យសំខាន់ៗមួយចំនួន រួមមានៈ ធនាគារ សំណង់ ដឹកជញ្ជូន និងទូរគមនាគមន៍ ដើម្បីឱ្យសវនករងាយស្រួលក្នុងការអនុវត្តសវនកម្ម និងបង្កើនប្រសិទ្ធភាពសវនកម្ម។

- បង្កើតការិយាល័យស៊ើបអង្កេតបទល្មើសពន្ធដារ និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់មន្ត្រីស៊ើបអង្កេតបទល្មើសពន្ធដារ
- អនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការតឹងទារបំណុលពន្ធ ដែលមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ ដូចជាការរឹបអូស ឬការឃុំគ្រងទ្រព្យសម្បត្តិរបស់អ្នកជាប់បំណុលពន្ធ និងការប្តឹងអ្នកជំពាក់បំណុលពន្ធទៅតុលាការ
- ជំរុញការបង្កើនចំណូលពីអាករលើតម្លៃបន្ថែម តាមរយៈ÷

(១)- រៀបចំកែប្រែអនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែម ដោយបន្ថយកម្រិតផលរបរប្រចាំឆ្នាំសម្រាប់សហគ្រាសជាប់ពន្ធតាមរបបស្វ័យប្រកាស ដើម្បីពង្រីកមូលដ្ឋានយកពន្ធ និងបង្កើនចំណូលអាករលើតម្លៃបន្ថែម និងពន្ធដទៃទៀត

(២)- បញ្ឈប់ការលើកលែងអាករលើតម្លៃបន្ថែមលើវិស័យដែលមិនមានចែង ក្នុងច្បាប់ស្តីពីសារពើពន្ធ។

- ពង្រឹងការគ្រប់គ្រងរបបម៉ៅការ និងជំរុញការអនុវត្តរបបស្វ័យប្រកាស តាមរយៈ÷

(១)- រៀបចំបទប្បញ្ញត្តិសម្រាប់អ្នកជាប់ពន្ធតាមរបបម៉ៅការ ដោយតម្រូវឱ្យបង់ពន្ធប៉ាតង់ប្រចាំឆ្នាំ រួមបញ្ចូលទាំងការបង់ប្រាក់អាករលើផលរបរ និងពន្ធលើប្រាក់ចំណេញក្នុងមួយឆមាសម្តង ឬមួយឆ្នាំម្តង ដើម្បីបន្ថយបន្ទុករបស់អ្នកជាប់ពន្ធ និងផ្ទេរមន្ត្រីទៅបម្រើការងារនៅកន្លែងដែលមានចំណូលខ្ពស់

(២)- រៀបចំ និងដាក់ឱ្យអនុវត្តនូវរបបស្វ័យប្រកាសបំព្រួញ និងតម្រូវឱ្យអនុវត្តកាតព្វកិច្ចកាន់បញ្ជីគណនេយ្យ ដែលមានលក្ខណៈសាមញ្ញសម្រាប់អ្នកជាប់ពន្ធក្នុងរបបនេះ។

- ពិនិត្យឡើងវិញចំពោះការលើកទឹកចិត្តពន្ធក្នុងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធការវិនិយោគ
- ពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ពិសេសអាជ្ញាធរមូលដ្ឋាន ក្នុងការប្រមូលពន្ធលើអចលនទ្រព្យ
- បន្តពង្រឹងកម្មវិធីផ្សព្វផ្សាយ និងការអប់រំពន្ធ ដើម្បីលើកកម្ពស់វប្បធម៌បង់ពន្ធ
- បញ្ចប់ការរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងធនធានមនុស្ស

- បន្តពង្រឹងក្រមសីលធម៌ និងកិរិយាមាយាទមន្ត្រីពន្ធដារ។

**គ.ផ្នែកចំណូលមិនមែនសារពើពន្ធ**

- ពង្រឹងប្រសិទ្ធភាពនៃការប្រមូល និងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដោយធ្វើសវនកម្មក្រសួង ស្ថាប័ន និងអង្គភាពនៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលប្រមូលចំណូលប្រភេទនេះ ពិសេសរៀបចំ និងដាក់ឱ្យអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- ពង្រឹងការគ្រប់គ្រង ការប្រើប្រាស់ និងចាត់ចែងទ្រព្យសម្បត្តិរដ្ឋ តាមរយៈការធ្វើសវនកម្មលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង ស្ថាប័ន និងអង្គភាពនៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ពិសេសរៀបចំ និងដាក់ឱ្យអនុវត្តច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បន្តតាមដានការប្រមូលចំណូល ឬការលាក់ទុកចំណូលរបស់ក្រសួង ស្ថាប័ន និងអង្គភាពនៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ហើយមានវិធានការលើកទឹកចិត្ត សមស្របសម្រាប់ស្ថាប័នទាំងឡាយណា ដែលប្រមូលចំណូលបានល្អ និងមានវិធានការរដ្ឋបាលតឹងរ៉ឹងចំពោះស្ថាប័ន និងមន្ត្រីពាក់ព័ន្ធ ដែលប្រមូលចំណូលមិនបានល្អ ឬលាក់ចំណូល ដោយមិនរាប់បញ្ចូលនូវទោសទណ្ឌផ្សេងទៀត
- បន្តស្រាវជ្រាវ និងកំណត់ឱ្យបានច្បាស់នូវបំណុលមិនមែនសារពើពន្ធគ្រប់ប្រភេទ រួចបង្កើតយន្តការតឹងទារបំណុលទាំងនោះ ដោយចាត់វិធានការព្រមាន ដកហូតអាជ្ញាបណ្ណ លុបចោលកិច្ចសន្យា ឬបង្កកគណនីនៅធនាគារពាណិជ្ជ និងវិធានការចាំបាច់ផ្សេងៗទៀត តាមការអនុញ្ញាតរបស់ច្បាប់ក្នុងករណីក្រុមហ៊ុនមិនមានចំណាត់ការណាមួយក្នុងការសងបំណុល
- ពង្រឹងការគ្រប់គ្រងកាស៊ីណូ និងចំណូលពីកាស៊ីណូ តាមរយៈការរៀបចំ និងដាក់ឱ្យអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងកាស៊ីណូ
- ពង្រឹងការគ្រប់គ្រងធនធានប្រេងកាត និងរ៉ែ តាមរយៈការរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធពន្ធលើប្រតិបត្តិការប្រេងកាត និងធនធានរ៉ែ ទន្ទឹមនឹងការសិក្សានិងធ្វើការកែប្រែតម្លៃនៃកម្រៃអាជ្ញាបណ្ណ និងកម្រៃសួយសារសម្រាប់ការរុករក និងការធ្វើអាជីវកម្មធនធានរ៉ែគ្រប់ប្រភេទ ការបន្តរៀបចំទិន្នន័យ និងប្រព័ន្ធតាមដានកាតព្វកិច្ចហិរញ្ញវត្ថុទៅលើកិច្ចសន្យានិងអាជ្ញាបណ្ណដែលបានផ្តល់រួច
- រៀបចំ និងដាក់ឱ្យអនុវត្តឱ្យមានប្រសិទ្ធភាពនូវការបង់កម្រៃនៅក្នុងការលក់ ឬផ្ទេរសិទ្ធិភាគហ៊ុននៅក្នុងកិច្ចសន្យាជួលកោះ តំបន់ឆ្នេរ និងតំបន់រមណីយដ្ឋាននានា និងអនុវត្តការបង់ពន្ធប្រថាប់ត្រាតាមច្បាប់ជាធរមាន
- ពង្រឹងការប្រមូលចំណូលពាក់ព័ន្ធនឹងវិស័យទេសចរណ៍ ដូចជា ការលក់សំបុត្រទស្សនាប្រាសាទ រមណីយដ្ឋាន និងទីតាំងប្រវត្តិសាស្ត្រផ្សេងៗ
- បន្តជំរុញឱ្យគ្រប់ចំណុចគោលដៅដែលមានសមត្ថកិច្ចផ្តល់ទិដ្ឋាការជូនភ្ញៀវទេសចរ រៀបចំរបាយការណ៍ស្តីពីចំណូលអាករស្ថានទូត ស្ថានភាពប្រើប្រាស់សន្លឹកទិដ្ឋាការ និងស្ថានភាពប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំឱ្យបានទៀងទាត់ និងច្បាស់លាស់

- ពង្រឹងការបង់ចំណូលថវិកាពីថ្លៃសម្បទានដីសេដ្ឋកិច្ច និង ផលអនុផលព្រៃឈើពីព្រៃឈើពីសម្បទានិក តាមរយៈការរៀបចំនិងដាក់ឱ្យអនុវត្តនូវបទប្បញ្ញត្តិមួយចំនួនពាក់ព័ន្ធនឹងការលក់និងការផ្ទេរសិទ្ធិសម្បទានដីសេដ្ឋកិច្ច នីតិវិធីនៃការបង់ថ្លៃសម្បទានដីសេដ្ឋកិច្ច ការបង្កើនយន្តការនិងនីតិវិធីក្នុងការគ្រប់គ្រងនិងការប្រមូលចំណូលពីផល-អនុផលព្រៃឈើលើដីសម្បទានសេដ្ឋកិច្ច វារីអគ្គិសនី ទំនប់ អាងស្រោចស្រព និងពីប្រភពផ្សេងៗទៀត
- រៀបចំ និងដាក់ឱ្យអនុវត្តការបង់កម្រៃនៅក្នុងការលក់ ឬផ្ទេរសិទ្ធិភាគហ៊ុននៅក្នុងសម្បទានដីសេដ្ឋកិច្ច និងអនុវត្តការបង់ពន្ធប្រថាប់ត្រាតាមច្បាប់ជាធរមាន
- ពង្រឹងប្រសិទ្ធភាពការប្រមូលចំណូលពីការផ្តល់អាជ្ញាបណ្ណក្នុងវិស័យទេសចរណ៍ តាមរយៈការបង្កើតការស្នើសុំអាជ្ញាបណ្ណទេសចរណ៍តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ការធ្វើចំណាត់ថ្នាក់សណ្ឋាគារ និងការបង្កើតឱ្យមានប្រព័ន្ធចំណាត់ថ្នាក់សេវាកម្មទេសចរណ៍គ្រប់ប្រភេទ
- បន្តពង្រឹងការគ្រប់គ្រង និងលើកកម្ពស់អភិបាលកិច្ចសាជីវកម្មរបស់សហគ្រាសសាធារណៈទាំងអស់ តាមរយៈត្រួតពិនិត្យលើកិច្ចដំណើរការអាជីវកម្ម និងចំណាយលើការវិនិយោគប្រចាំឆ្នាំ ធ្វើការផ្ទៀង-ផ្ទាត់ស្ថានភាពប្រែប្រួលនៃបញ្ជីសារពើភ័ណ្ឌ និងការធ្វើសវនកម្មពេញលេញលើផ្នែកហិរញ្ញវត្ថុ ព្រមទាំង ពង្រឹងការអនុវត្តនូវកាតព្វកិច្ចបង់ភាគលាភប្រចាំឆ្នាំចូលថវិការដ្ឋ
- ពង្រឹងការគ្រប់គ្រងគ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងអស់ តាមរយៈការសិក្សា និងរៀបចំឡើងវិញនូវក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្ត រួមទាំងការកែលម្អលក្ខន្តិកៈគតិយុត្តឱ្យស្របតាមការរីកចម្រើននៃសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា និងដើម្បីផ្តល់លទ្ធភាពដល់អង្គភាពរដ្ឋទាំងឡាយណាដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទៅជាគ្រឹះស្ថាន ក៏ដូចជាដើម្បីជំរុញការអភិវឌ្ឍស្ថាប័នរបស់គ្រឹះ-ស្ថានសាធារណៈរដ្ឋបាលដែលមានស្រាប់
- លើកកម្ពស់ការគ្រប់គ្រងវិស័យប្រៃសណីយ៍និងទូរគមនាគមន៍ ដោយធ្វើវិសោធនកម្មច្បាប់ស្តីពីប្រៃស-ណីយ៍ និង ជំរុញការរៀបចំនិងដាក់ឱ្យអនុវត្តច្បាប់ស្តីពីទូរគមនាគមន៍
- ធ្វើការវាយតម្លៃអំពីប្រសិទ្ធភាពនៃការប្រមូលចំណូលពីកម្រៃសេវាសាធារណៈរបស់រដ្ឋ ដោយផ្សារភ្ជាប់ជាមួយនឹងការសិក្សាអំពីភាពប្រកួតប្រជែងរបស់កម្ពុជាពាក់ព័ន្ធនឹងកម្រៃសេវានីមួយៗ នៅក្នុងតម្លៃនៃការធ្វើធុរកិច្ច អាជីវកម្ម និងពាណិជ្ជកម្មជារួមដោយប្រៀបធៀបជាមួយប្រទេសជិតខាងក្នុងតំបន់ ដើម្បីដាក់ចេញជាយុទ្ធសាស្ត្រធ្វើការកែតម្រូវកម្រៃសេវា និងវង្វាន់លើកទឹកចិត្ត ផ្សារភ្ជាប់ជាមួយនឹងការកែទម្រង់បៀវត្សក្នុងគោលដៅបង្កើនសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា
- រៀបចំ និងដាក់ឱ្យអនុវត្តជាជំហានៗនូវកម្រៃសេវាធ្វើដំណើរ ដោយក្នុងនោះអាចចាប់ផ្តើមពីកម្រៃសេវាធ្វើដំណើរតាមផ្លូវអាកាសមុន ដើម្បីប៉ះប៉ូវដល់លទ្ធភាពនៃការបាត់បង់ចំណូលពីការបន្តផ្តល់ការលើកលែងទិដ្ឋាការនាពេលខាងមុខ
- ពិនិត្យឡើងវិញ និងធ្វើកែប្រែជាយថាហេតុលើកិច្ចព្រមព្រៀង ឬកិច្ចសន្យាណាមួយ ដែលមិនឆ្លុះបញ្ចាំងពីវឌ្ឍនភាពសង្គម ឬមិនផ្តល់ផលប្រយោជន៍សមស្របសម្រាប់ភាគីរាជរដ្ឋាភិបាល

- ជំរុញការវាយតម្លៃដីធ្លីរបស់ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងនីតិបុគ្គលសាធារណៈដែលស្ថិតនៅក្រៅតារាងតម្លៃពន្ធអចលនទ្រព្យ និងការចុះបញ្ជីសារពើភ័ណ្ឌនូវដីធ្លី ដែលបានដោះស្រាយរួចតាមរយៈគោលនយោបាយដោះស្រាយផលប៉ះពាល់។

**ផ្នែកចំណាយ**

- បន្តអនុវត្តគោលការណ៍បង្កើនបៀវត្សដល់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធឱ្យទទួលបានច្រើនជាង ១ លានរៀល នៅឆ្នាំ ២០១៨ ក្នុងគោលដៅបង្កើនគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ដោយឈរលើគោលការណ៍ប្រសិទ្ធភាព សមធមិ សង្គតិភាព ការធានាបាននិរភាពថវិកា និងស្ថិរភាពសេដ្ឋកិច្ចទាំងមូល
- បង្កើនការរៀបចំថវិកាឱ្យកាន់តែផ្សារភ្ជាប់ទៅនឹងគោលនយោបាយ តាមរយៈការបង្កើនប្រសិទ្ធភាពនៃការវិភាជថវិកាឱ្យកាន់តែមានមូលដ្ឋានច្បាស់លាស់ និងចំទិសដៅ ពិសេសការពង្រឹងអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងពង្រីកការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកាពីចំនួន១០ ក្រសួង ស្ថាប័ន នៅក្នុងឆ្នាំ២០១៥ ឱ្យឡើងដល់ ២៥ ក្រសួង ស្ថាប័ន នៅឆ្នាំ២០១៦
- លើកកម្ពស់ប្រសិទ្ធភាពបច្ចេកទេស និងប្រតិបត្តិការចំណាយ តាមរយៈការបង្កើនតម្លៃនៃលុយដោយផ្តោតការយកចិត្តទុកដាក់លើភាពសមស្របនៃថ្លៃ, បរិមាណ, គុណភាព និងភាពទាន់ពេល ក្នុងចំណាយថវិកា ទាំងចំណាយចរន្ត (ទាំងចំណាយបុគ្គលិក និងមិនមែនបន្ទុកបុគ្គលិក) ទាំងចំណាយមូលធន
- រឹតត្បិតចំពោះមុខសញ្ញាចំណាយណាដែលមិនចាំបាច់ ឬមិនមែនអាទិភាព ដោយបង្កើនការយកចិត្តទុកដាក់លើមុខចំណាយដែលបង្កើនផលិតភាព និងទ្រទ្រង់កំណើន
- បង្កើនការសន្សំសំចៃថវិកា តាមរយៈការលើកកម្ពស់ចំណាយថវិកាលើមុខចំណាយទំនិញ និងសេវាមួយចំនួនដូចជា ប្រេងឥន្ធនៈ អគ្គិសនី សេវាទូរគមនាគមន៍និងអ៊ិនធើណែត ការកាត់បន្ថយនូវបេសកកម្មទាំងក្នុងនិងក្រៅប្រទេស និងការបោះពុម្ពដែលមានគុណភាពប្រណិតហើយមានតម្លៃខ្ពស់
- បន្តរក្សាអាទិភាព និង វិចារណកម្មនៃគោលនយោបាយចំណាយដល់វិស័យអប់រំ បណ្តុះបណ្តាល-វិជ្ជាជីវៈ សុខាភិបាល សំណាញ់សុវត្ថិភាព កសិកម្ម ដីធ្លីនិងអភិវឌ្ឍន៍ជនបទ ទឹកស្អាត សាលារៀន និងមន្ទីរពេទ្យ។ល។
- បន្តការវិនិយោគលើការពង្រីក ការកែលម្អ និងពង្រឹងការថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដូចជា ផ្លូវថ្នល់ ផ្លូវដែក កំពង់ផែ ប្រព័ន្ធធារាសាស្ត្រស្រោចស្រព និងអគ្គិសនី ។ល។
- បន្តផ្តោតការយកចិត្តទុកដាក់ និងបង្កើនការវិនិយោគសាធារណៈឱ្យចំវិស័យដែលផ្តល់ផលិតភាពខ្ពស់ ក្នុងគោលដៅទ្រទ្រង់កំណើនប្រកបដោយចីរភាព ដូចជា វិស័យកសិកម្ម និងវិស័យគាំទ្រដើម្បីជំរុញផលិតភាព តម្លៃបន្ថែម និងជំរុញការកែច្នៃ និងនាំចេញផលិតឧស្សាហកម្មនិងកសិផល ការចិញ្ចឹមសត្វ និងវារីវប្បកម្ម ដើម្បីគាំទ្រដល់ការជំរុញផលិតកម្មម្ហូបអាហារ
- បន្តធ្វើវិចារណកម្ម និងរឹតបន្តឹងចំណាយក្នុងគោលបំណងរក្សាវិនភាពថវិកាឱ្យនៅត្រឹមកម្រិតសមរម្យមួយដែលមិនប៉ះពាល់និរន្តរភាពថវិកា និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងបង្កើន "**លំហថវិកា**" សម្រាប់ដោះស្រាយតម្រូវការបន្ទាន់ ករណីប្រធានស័ក្តិ និងវិបត្តិផ្សេងៗ ឬតម្រូវការ

ចំណាយចាំបាច់ភ្លាមៗរបស់រាជរដ្ឋាភិបាលនាពេលអនាគត ព្រមទាំងការកាត់បន្ថយការពឹងផ្អែកលើហិរញ្ញប្បទានក្រៅប្រទេស

- បន្តអនុវត្តក្របខណ្ឌគោលនយោបាយស្តីពីការគ្រប់គ្រងហានិភ័យបំណុល និងបន្តពង្រឹងបន្ថែមសមត្ថភាពស្ថាប័នដែលពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ក្នុងគោលដៅបន្តរក្សាចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈ
- បន្តពង្រឹងការគ្រប់គ្រងចំណាយសាធារណៈ ជាពិសេសបន្តពង្រឹងជំរុញការកែលម្អការអនុវត្តថវិកាតាមរយៈការបន្តកាត់បន្ថយនីតិវិធីចំណាយ ការបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ការបន្តពង្រឹងការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស ការបន្តត្រួតពិនិត្យការអនុវត្តថវិកាប្រចាំត្រីមាស និងឆមាស ការបន្តពង្រឹងការត្រួតពិនិត្យផ្ទៃក្នុង ដើម្បីបន្តពង្រឹងភាពជឿទុកចិត្តបាននៃថវិកាដែលសម្រេចបាន និងបន្តបង្កើនប្រសិទ្ធភាពគណនេយ្យភាពហិរញ្ញវត្ថុ និងជំហានបន្ទាប់នានាទៀត
- បន្តអនុវត្តឱ្យមានប្រសិទ្ធភាព និងតម្លាភាពនូវការងារលទ្ធកម្មនៃចំណាយសាធារណៈ និងពង្រឹងការអនុវត្តច្បាប់លទ្ធកម្មសាធារណៈ
- ពង្រឹងការគ្រប់គ្រង ឱ្យបានត្រឹមត្រូវ និងហ្មត់ចត់ និងការជ្រើសរើសមន្ត្រីរាជការ ពិសេសបុគ្គលិកអណ្តែត ក្នុងគោលបំណងផ្គូរផ្គងធនធានហិរញ្ញវត្ថុដែលមាន និងតម្រូវការមន្ត្រីថ្មី។

## ៣. រចនាសម្ព័ន្ធនៃឯកសារផែនការយុទ្ធសាស្ត្រថវិកា

ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលបានគូសរំលេចខាងលើបានកំណត់អំពីគោលដៅរួមនៃការប្រមូលចំណូល និងវិធានការចាំបាច់នានាដែលត្រូវអនុវត្តដើម្បីសម្រេចឱ្យបាននូវគោលដៅដែលបានដាក់ចេញនោះ ចំណែកខាងផ្នែកចំណាយវិញបានកំណត់អំពីគោលដៅរួមនៃចំណាយ និងបណ្តាអាទិភាពចម្បងៗ ដើម្បីសម្រេចគោលដៅរួមរបស់រាជរដ្ឋាភិបាល ដូចបានដាក់ចេញក្នុង**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ២០១៤-២០១៨។ ដូចនេះ ក្រសួង ស្ថាប័ននីមួយៗ ត្រូវផ្អែកលើក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈដូចបានកំណត់ខាងលើ ដើម្បីឈានទៅរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួនឱ្យបានល្អត្រឹមត្រូវ និងមានភាពជាក់ស្តែង។ ទន្ទឹមនឹងនេះ ដើម្បីជាមូលដ្ឋានសម្រាប់ឱ្យក្រសួង ស្ថាប័ន អាចរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងមានលក្ខណៈឯកភាពគ្នា រចនាសម្ព័ន្ធ និងខ្លឹមសារនៃផែនការយុទ្ធសាស្ត្រថវិកា ត្រូវរៀបចំទៅតាមទម្រង់ដូចខាងក្រោម ÷

**-ផ្នែកទី១:** សេចក្តីផ្តើម:

ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦ ត្រូវចាប់ផ្តើមដោយការរៀបរាប់អំពីតួនាទី និងបេសកកម្មចម្បងៗរបស់ក្រសួង ស្ថាប័ន, អំពីស្ថានភាពជាក់ស្តែងនៃការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៤ និងការព្យាករសភាពការណ៍នៃការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៥ ធៀបនឹងគោលដៅសូចនាករដែលបានកំណត់ និងបញ្ហាប្រឈមផ្សេងៗ ដែលត្រូវដោះស្រាយជាបន្តបន្ទាប់នៅក្នុងឆ្នាំ២០១៥ និងឆ្នាំខាងមុខ ។ បន្ទាប់មកត្រូវមានការរៀបរាប់អំពីវិធានការគោលនយោបាយសំខាន់ៗ សម្រាប់រួមចំណែកអនុវត្តគោលនយោបាយដែលបាន

ដាក់ក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨។ **សូមរៀបចំខ្លឹមសារនៃផ្នែកទី១នេះទៅតាមទម្រង់គំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។**

-**ផ្នែកទី២:** គោលបំណងគោលនយោបាយៈ

គោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ន ត្រូវបានរៀបចំឡើងសម្រាប់ចក្ខុវិស័យរយៈពេល មធ្យម និងវែង (៣-៥ឆ្នាំ) ដោយផ្អែកលើគោលនយោបាយតាមវិស័យដែលចែងក្នុងយុទ្ធសាស្ត្រចតុកោណ និង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ គោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ននីមួយៗ មិនមែនជាកម្មវត្ថុនៃការធ្វើបច្ចុប្បន្នកម្មជារៀងរាល់ឆ្នាំទេ ប៉ុន្តែក្រសួង ស្ថាប័នមួយចំនួនអាចត្រួតពិនិត្យនិងវាយតម្លៃឡើងវិញនូវគោលបំណងគោលនយោបាយដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៥របស់ខ្លួនបាន ដើម្បីកែសម្រួលគោលបំណងគោលនយោបាយឱ្យកាន់តែច្បាស់លាស់ និងសមស្របតាមវឌ្ឍនភាពជាក់ស្តែងនៃវិស័យរៀងៗខ្លួន។ **សូមរៀបចំខ្លឹមសារនៃផ្នែកទី២នេះទៅតាមទម្រង់គំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។**

-**ផ្នែកទី៣:** កម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពៈ

ការរៀបចំកម្មវិធី (សម្រាប់ក្រសួង ស្ថាប័នអនុវត្តថវិកាកម្មវិធី) ឬយុទ្ធសាស្ត្រអាទិភាព (សម្រាប់ក្រសួង ស្ថាប័នមិនអនុវត្តថវិកាកម្មវិធី) ត្រូវឱ្យឆ្លើយតបទៅនឹងគោលបំណងគោលនយោបាយ ហើយត្រូវបញ្ជាក់អំពីគោលបំណងនៃកម្មវិធីឬយុទ្ធសាស្ត្រអាទិភាពឱ្យច្បាស់លាស់ ដើម្បីឆ្លុះបញ្ចាំងឱ្យឃើញច្បាស់ថា ការអនុវត្តកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពទាំងនោះ មានគោលដៅសម្រេចគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័នដែលបានកំណត់។ ដូច្នេះ នៅក្នុងផ្នែកនេះ ក្រសួង ស្ថាប័ននីមួយៗ ត្រូវបង្កើតឈ្មោះកម្មវិធី រៀបរាប់និងពន្យល់អំពីគោលបំណងនៃកម្មវិធីដែលបានបង្កើត ឬ យុទ្ធសាស្ត្រអាទិភាព ព្រោះកម្មវិធីឬយុទ្ធសាស្ត្រអាទិភាព គឺជាឧបករណ៍ដែលបានបង្កើតឡើង ដើម្បីឱ្យអគ្គនាយកដ្ឋាន/នាយកដ្ឋានក្រោមឱវាទរបស់ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលស្ថិតក្រោមក្រសួង ស្ថាប័នសាមី ដាក់ចេញនូវអនុកម្មវិធី និង ចង្កោមសកម្មភាព (សម្រាប់ក្រសួង ស្ថាប័នអនុវត្តថវិកាកម្មវិធី) ឬ ចង្កោមសកម្មភាពអាទិភាព (សម្រាប់ក្រសួង ស្ថាប័នមិនអនុវត្តថវិកាកម្មវិធី) ព្រមទាំងលើកគម្រោងថវិកាដើម្បីអនុវត្តកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពទាំងនោះ ក្នុងគោលដៅសម្រេចគោលបំណងគោលនយោបាយដែលបានកំណត់នៅក្នុងផ្នែកទី២។

កម្មវិធីឬយុទ្ធសាស្ត្រអាទិភាព ត្រូវមានខ្លឹមសារទូលាយ និងគ្របដណ្តប់បានទាំងស្រុងគ្រប់តួនាទី ភារកិច្ច និងបេសកកម្មរបស់ក្រសួង ស្ថាប័ននីមួយៗ ព្រមទាំងមានលក្ខណៈសមាហរណកម្មដោយត្រូវគ្របដណ្តប់លើគម្រោង ឬ សកម្មភាពការងារទាំងអស់ទាំងរវាងគម្រោង ឬសកម្មភាពការងារដែលហិរញ្ញប្បទានដោយថវិការដ្ឋ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ ទាំងថវិកាចរន្ត និងថវិកាមូលធន។ ជាមួយគ្នានេះ ក្រសួង ស្ថាប័នត្រូវកំណត់អង្គភាពទទួលខុសត្រូវ និងអ្នកគ្រប់គ្រងទៅតាមរចនាសម្ព័ន្ធកម្មវិធី (ចំពោះក្រសួង ស្ថាប័នអនុវត្តថវិកាកម្មវិធី) ឬយុទ្ធសាស្ត្រអាទិភាព (ចំពោះក្រសួង ស្ថាប័នមិនអនុវត្តថវិកាកម្មវិធី)។ ទន្ទឹមនឹងនេះ ក្នុងក្របខណ្ឌនៃការកែទម្រង់ប្រព័ន្ធថវិកា ក្រសួង ស្ថាប័ននីមួយៗត្រូវកំណត់ភារកិច្ច វិសាលភាពការងារ និងក្របខណ្ឌទទួលខុសត្រូវរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរជំនាញរាជធានី ខេត្តឱ្យច្បាស់លាស់នៅក្នុងរចនាសម្ព័ន្ធកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពរបស់ខ្លួន។ មន្ទីរជំនាញរាជធានី ខេត្ត មិនចាំបាច់ត្រូវមានកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពដោយឡែកទេ ព្រោះមន្ទីរជំនាញរាជធានី ខេត្ត គឺជាដៃរបស់ក្រសួងនៅតាមរាជធានី ខេត្ត ដែលមានភារកិច្ចរួមចំណែកអនុវត្តបណ្តាកម្មវិធី ឬ យុទ្ធសាស្ត្រអាទិភាពរបស់ក្រសួង ស្ថាប័ន។

ក្នុងន័យនេះ ក្រសួង ស្ថាប័ននីមួយៗ ត្រូវណែនាំដល់មន្ទីរជំនាញរបស់ខ្លួននៅរាជធានី ខេត្ត អំពី **អនុកម្មវិធីរួមមួយនៅក្នុងកម្មវិធីមួយឬកម្មវិធីលើសពីមួយ ដោយផ្អែកលើមុខងារ វិសាលភាពការងារ និងលក្ខណៈដោយឡែកនៃគោលនយោបាយ និងសេវាសាធារណៈរបស់ក្រសួង ស្ថាប័នរៀងៗខ្លួន ដើម្បីឱ្យមន្ទីរជំនាញរាជធានីខេត្តរបស់ខ្លួនដឹងច្បាស់លាស់អំពីទីតាំងនៃអនុកម្មវិធីរួមមួយនៅក្នុងកម្មវិធីមួយណា ឬនៅក្នុងគ្រប់កម្មវិធីទាំងអស់។** ជាទូទៅ មន្ទីរជំនាញមួយអាចមានចង្កោមសកម្មភាពតែមួយគត់ក្រោមអនុកម្មវិធីរួមមួយនៃកម្មវិធីមួយ លើកលែងតែក្រសួង ស្ថាប័នដែលមានតួនាទីនិងភារកិច្ចច្រើន ហើយការងារនោះភាគច្រើនអនុវត្តនៅថ្នាក់ក្រោមជាតិ ដូចជាក្រសួងអប់រំ យុវជននិងកីឡា និងក្រសួងសុខាភិបាលជាដើម ដែលត្រូវមានអនុកម្មវិធីរួមលើសពីមួយ ដែលជាសេវា ឬការងារគាំទ្រដល់កម្មវិធីលើសពីមួយ។ សូមបញ្ជាក់ផងដែរថា ក្រសួង ស្ថាប័ននីមួយៗ ត្រូវបង្កើតកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពមិនឱ្យលើសពី៥ឡើយ ប៉ុន្តែអាចមានអនុកម្មវិធីសមស្រប និងតាមការចាំបាច់។ ជាមួយគ្នានេះ ក្រសួង ស្ថាប័ននីមួយៗ ត្រូវគ្រោងផងដែរទាំងធនធានថវិកាជាតិ និង ថវិកាហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់អនុវត្តកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពនៃផ្នែកទី៣នេះ។ ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល **ត្រូវរៀបចំផ្នែកទី៣នេះ ទៅតាមតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។**

-**ផ្នែកទី៤**: សូចនាករ និងគោលដៅសូចនាករៈ

គោលបំណងគោលនយោបាយ និងកម្មវិធីឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ ត្រូវមានសូចនាករសម្រាប់វាស់ និង ត្រូវកំណត់គោលដៅសូចនាករដែលចង់សម្រេចបានសម្រាប់ជាមូលដ្ឋាននៃការត្រួតពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលនៃការអនុវត្ត។ ក្នុងការកំណត់សូចនាករ ឬហៅថាការជ្រើសរើសសូចនាករសម្រាប់ការវាស់វែង ក្រសួង ស្ថាប័ននីមួយៗ ត្រូវកំណត់ទាំងសូចនាករលទ្ធផលក្នុងឆ្នាំ និងសូចនាករលទ្ធផលចុងក្រោយ។ សូចនាករលទ្ធផលក្នុងឆ្នាំគឺជារង្វាស់ដែលបានជ្រើសរើសសម្រាប់វាស់លទ្ធផល/ សមិទ្ធកម្មនៃការអនុវត្តកម្មវិធីឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ ទៅតាមគោលដៅដែលបានកំណត់នៅក្នុងរយៈពេលជាក់លាក់មួយដែលមិនលើសពីមួយឆ្នាំ។ រីឯសូចនាករលទ្ធផលចុងក្រោយ គឺជារង្វាស់ដែលបានជ្រើសរើសសម្រាប់វាស់សមិទ្ធកម្មចុងក្រោយដែលជាលទ្ធផលសម្រេចបានដោយការបូកបញ្ចូលគ្នានូវលទ្ធផលក្នុងឆ្នាំនៃការអនុវត្តកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាព ក្នុងរយៈពេលមធ្យម និងវែង (លើសពីមួយឆ្នាំ)។ ក្រសួង ស្ថាប័ននីមួយៗ អាចកែសម្រួលសូចនាករនៃកម្មវិធីឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ តាមរយៈការបន្ថែមសូចនាករថ្មី និងកែសម្រួលសូចនាករចាស់ដែលបានកំណត់កន្លងមក។ ការជ្រើសរើសសូចនាករនីមួយៗត្រូវមានការពន្យល់ពីមូលហេតុឱ្យច្បាស់លាស់។ ចំពោះសូចនាករចាស់ត្រូវបញ្ជាក់អំពីស្ថានភាពនៃការអនុវត្តឆ្នាំ២០១៤ ការព្យាករស្ថានភាពនៃការអនុវត្តក្នុងឆ្នាំ២០១៥ និងធ្វើបច្ចុប្បន្នភាពតាមការជាក់ស្តែង។ **កម្មវិធីឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ អាចមានសូចនាករយ៉ាងច្រើនចំនួន៣** ដើម្បីធានានូវការសម្រេចបានលទ្ធផលជាក់លាក់នៃការអនុវត្តកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាព។ បន្ទាប់ពីការជ្រើសរើស និងកំណត់បាននូវសូចនាករសមស្របរួចហើយ ក្រសួង ស្ថាប័ននីមួយៗចាំបាច់ត្រូវកំណត់គោលដៅនៃសូចនាករទាំងគោលដៅសូចនាករលទ្ធផលក្នុងឆ្នាំ និងគោលដៅសូចនាករលទ្ធផលចុងក្រោយ។ គោលដៅសូចនាករទាំងពីរប្រភេទនេះចាំបាច់ត្រូវឱ្យមានទំនាក់ទំនងគ្នា និងឆ្លើយតបគ្នាយ៉ាងមានប្រសិទ្ធភាព ដើម្បីធានានូវការសម្រេចបានលទ្ធផលនៃគោលបំណងគោលនយោបាយដែលបានកំណត់នៅក្នុងរយៈពេលជាក់លាក់មួយ។ គោលដៅសូចនាករលទ្ធផលក្នុងឆ្នាំមានលក្ខណៈជាបរិមាណឬ/និងជាគុណភាពប្រចាំឆ្នាំ ដែលជាសមិទ្ធកម្មនៃការអនុវត្ត

កម្មវិធីឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ។ រីឯគោលដៅសូចនាករលទ្ធផលចុងក្រោយ គឺជាគោលដៅសមិទ្ធកម្មចុងក្រោយជាបរិមាណឬ/និងជាគុណភាព ដែលជាលទ្ធផលបង្កើតឡើងដោយលទ្ធផលក្នុងឆ្នាំនៃការអនុវត្តកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពនីមួយៗនៅក្នុងរយៈពេលមធ្យមនិងវែង(លើសពី១ឆ្នាំ)។ ក្នុងការកំណត់គោលដៅសូចនាករ កត្តាចាំបាច់និងសំខាន់បំផុតគឺត្រូវដឹងអំពីស្ថានភាពបច្ចុប្បន្នរបស់សូចនាករទាំងនោះទើបអាចទៅកំណត់គោលដៅដែលចង់បាន ដើម្បីឱ្យឆ្លើយតបបានទៅនឹងគោលបំណងគោលនយោបាយដែលបានកំណត់ ហើយការកំណត់គោលដៅនេះចាំបាច់ត្រូវតែមានភាពសមស្របនិងប្រាកដនិយមដែលអាចអនុវត្តបាន។ ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល **ត្រូវរៀបចំខ្លឹមសារនៃផ្នែកទី៤នេះទៅតាមតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។**

-**ផ្នែកទី៥:** ការកំណត់ធនធានៈ

ការគ្រោងតម្រូវការចំណាយ គឺជាការគណនាចំណាយសម្រាប់រយៈពេល៣ឆ្នាំ (២០១៦-២០១៨) ទៅតាមកម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ និងទៅតាមប្រភេទចំណាយ និងប្រភពធនធាន រួមទាំង ថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ។ ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈ-រដ្ឋបាល ត្រូវរៀបចំខ្លឹមសារនៃផ្នែកទី៥នេះទៅ**តាមតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ**។ ការកំណត់អំពីតម្រូវការធនធានដើម្បីអនុវត្តកម្មវិធី ឬ យុទ្ធសាស្ត្រអាទិភាពនីមួយៗ ត្រូវផ្ដោតជាសំខាន់លើកត្តាមួយចំនួនដូចខាងក្រោម÷

- ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលរាជរដ្ឋាភិបាល តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានកំណត់ ជាពិសេសកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ អត្រាអតិផរណាប្រចាំឆ្នាំ និងទិសដៅសំខាន់ៗក្នុងការកំណត់អាទិភាពនៃចំណាយ
- ការវាយតម្លៃការអនុវត្តចំណាយក្នុងរយៈកាលកន្លងមក និងការប៉ាន់ស្មានការអនុវត្តចំណាយក្នុងឆ្នាំកំពុងអនុវត្តរបស់ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗ
- ការកំណត់តម្រូវការធនធានទៅតាមឆ្នាំនីមួយៗ ត្រូវមានភាពជាក់ស្ដែង និងមានសុក្រឹតភាពដើម្បីឆ្លើយតបទៅតាមតម្រូវការរបស់កម្មវិធី ឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ ។

ការគ្រោងចំណូល គឺជាការគ្រោងចំណូលសម្រាប់រយៈពេល៣ឆ្នាំ (២០១៦-២០១៨) ដោយផ្អែកលើក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច និងក្របខណ្ឌហិរញ្ញវត្ថុសាធារណៈខាងលើ ព្រមទាំងលទ្ធផល និងបទពិសោធន៍ក្នុងការអនុវត្តនៃបណ្ដាឆ្នាំកន្លងមក រួមទាំងគោលនយោបាយ និងវិធានការថ្មីដែលនឹងដាក់ឱ្យអនុវត្ត។ ការគ្រោងចំណូលនេះ ត្រូវគិតបញ្ចូលចំណូលគ្រប់ប្រភេទទាំងអស់ រួមទាំងចំណូលដែលស្ថិតក្រោមការគ្រប់គ្រង និងប្រមូលផ្ទាល់ដោយក្រសួង ស្ថាប័ន និងចំណូលដែលបានមកពីថវិកាហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់អនុវត្តគម្រោងនៅក្នុងក្រសួង ស្ថាប័ន។ ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈ-រដ្ឋបាល ត្រូវរៀបចំខ្លឹមសារនេះតាម**តារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ**។ នៅក្នុងផ្នែកនេះ ប្រសិនបើក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលមិនមានប្រភពចំណូលគឺពុំតម្រូវឱ្យរៀបចំឡើយ ប៉ុន្តែចំពោះ ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល

ដែលមានប្រភពចំណូល គឺត្រូវរៀបចំយុទ្ធសាស្រ្ត រួមមានទាំងគោលនយោបាយ និងវិធានការសម្រាប់ពង្រឹងការគ្រប់គ្រង និងប្រមូលចំណូល។ នៅក្នុងការគ្រោងចំណូល ក្រសួង ស្ថាប័ន ដោយរួមទាំងមន្ទីរជំនាញរាជធានី ខេត្ត និង គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវផ្អែកជាសំខាន់លើ÷

- ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ
- យុទ្ធសាស្រ្តកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨
- ការវាយតម្លៃការអនុវត្តប្រមូលចំណូលក្នុងឆ្នាំកន្លងទៅ និងការប៉ាន់ស្មានការអនុវត្តប្រមូលចំណូលក្នុងឆ្នាំកំពុងអនុវត្ត។

**-ផ្នែកទី៦**: សេចក្តីសន្និដ្ឋានៈ

ផ្នែកចុងក្រោយ គឺជាការសន្និដ្ឋានទៅលើការរៀបចំផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ២០១៦ និងការលើកទិសដៅ និងវិធានការដើម្បីសម្រេចគោលដៅដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ២០១៦ ។

## ៤. សេចក្តីសន្និដ្ឋាន

ផែនការយុទ្ធសាស្រ្តថវិកា គឺជាយន្តការមួយនៃដំណើរការរៀបចំថវិកាប្រចាំឆ្នាំ ដែលបានដាក់ឱ្យអនុវត្តក្នុងក្របខណ្ឌនៃការអនុវត្តកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងទិសដៅយុទ្ធសាស្រ្តនៃការកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា ដែលក្រសួង ស្ថាប័ននីមួយៗ ត្រូវរៀបចំឱ្យបានច្បាស់លាស់ ត្រឹមត្រូវ មានតម្លាភាព និងមានគណនេយ្យភាព ដើម្បីអនុវត្តកម្មវិធី ឬយុទ្ធសាស្រ្តអាទិភាពរបស់ក្រសួង ស្ថាប័នរៀងៗខ្លួន ក្នុងគោលដៅសម្រេចគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ននីមួយៗ និងដើម្បីចូលរួមចំណែកសម្រេចគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញក្នុង**យុទ្ធសាស្រ្តចតុកោណ-ដំណាក់កាលទី៣ និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ២០១៤-២០១៨**។ ការរៀបចំផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ២០១៦ គឺជាដំណាក់កាលទី១នៃដំណើរការរៀបចំថវិកាប្រចាំឆ្នាំ ដែលក្រសួង ស្ថាប័ននីមួយៗ មានលទ្ធភាពគ្រោងផែនការថវិកាសម្រាប់អនុវត្តកម្មវិធីឬយុទ្ធសាស្រ្តអាទិភាព ដោយផ្សារភ្ជាប់គោលនយោបាយរបស់ក្រសួង ស្ថាប័ន ទៅនឹងថវិកា ដោយផ្អែកលើក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ដែលបានដាក់ចេញរួចហើយ។

ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការរៀបចំផែនការយុទ្ធសាស្រ្តថវិកាប្រចាំឆ្នាំ ដែលជាផ្នែកមួយនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាវិធានការដ៏មានសារៈសំខាន់បំផុតសម្រាប់លើកកម្ពស់ប្រសិទ្ធភាពនៃការរៀបចំថវិកា និងការបែងចែកធនធានថវិកា។ ជាវិធីសាស្រ្តជាក់ស្តែងមួយ ដើម្បីរៀបចំផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ២០១៦ឱ្យបានសមស្រប ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗត្រូវត្រួតពិនិត្យឡើងវិញនិងវាយតម្លៃលើការអនុវត្តកន្លងមក ដោយផ្អែកលើផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ២០១៥របស់ខ្លួន និងក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈខាងលើ ហើយរៀបចំកែសម្រួលទៅ**តាមទម្រង់គំរូដូចបានភ្ជាប់ជាមួយសារាចរណែនាំនេះ**។

***គ្រប់ក្រសួង ស្ថាប័នទាំងអស់ ត្រូវបញ្ជូនផែនការយុទ្ធសាស្រ្តថវិកាសម្រាប់ឆ្នាំ២០១៦ ដែលមានវិសាលភាពគ្របដណ្តប់ទាំងថវិកាមន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៥*** ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានពេលវេលា

គ្រប់គ្រាន់សម្រាប់ពិនិត្យ បូកសរុប និងអាចអញ្ជើញតំណាងក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានីខេត្ត និង គ្រឹះស្ថានសាធារណៈរដ្ឋបាល មកពិគ្រោះនិងសាកសួរព័ត៌មានបន្ថែមក្នុងករណីចាំបាច់។ ក្រសួង ស្ថាប័នដែលមិនបានផ្តល់ផែនការយុទ្ធសាស្ត្រថវិកាតាមពេលវេលាកំណត់ខាងលើប្រកបដោយគុណភាពទេ ត្រូវបានអនុញ្ញាតឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្នើការវិភាជកញ្ចប់ថវិកាដោយផ្អែកលើមូលដ្ឋាននៃផែនការយុទ្ធសាស្ត្រថវិកា និងការអនុវត្តថវិកានៃឆ្នាំកន្លងទៅ។

ទទួលបានសារាចរណែនាំនេះ ក្រសួង ស្ថាប័ន រួមទាំងមន្ទីរជំនាញរាជធានី-ខេត្ត និង គ្រឹះស្ថានសាធារណៈ-រដ្ឋបាលទាំងអស់ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ និងឱ្យបានទាន់ឱសានវាទ។ ក្នុងករណីក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត និង គ្រឹះស្ថានសាធារណៈរដ្ឋបាល មានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេសត្រូវទាក់ទងជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា) ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦ឱ្យបានទាន់ពេលវេលាតាមកាលកំណត់ និងផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៥។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែមេសា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួលៈ</u>
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
"ដើម្បីជូនជ្រាប"
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-រាជកិច្ច "ដើម្បីចុះផ្សាយ"
-គ្រប់ក្រសួង ស្ថាប័ន
-គ្រប់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
-គ្រប់មន្ទីរជំនាញរាជធានី ខេត្ត
"ដើម្បីមុខការ"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :....០៥....សរ.ណន

# សារាចរណែនាំ
# ស្តីពី
# ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦

## I. សេចក្តីផ្តើម

១- មាត្រា៣៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បានចែងអំពីប្រតិទិនសម្រាប់រៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ជា៣ដំណាក់កាលគឺ (១) **ដំណាក់កាលទី១**: ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ពីខែមីនា ដល់ខែឧសភា (២) **ដំណាក់កាលទី២**: ការរៀបចំកញ្ចប់ថវិកា ពីខែមិថុនាដល់ខែកញ្ញា និង(៣) **ដំណាក់កាលទី៣**: ការអនុម័តថវិកា ពីខែតុលាដល់ខែធ្នូ។ សម្រាប់ដំណាក់កាលទី១នេះ រាជរដ្ឋាភិបាលតាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដាក់ចេញរួចហើយនូវក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ និងសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦។ ទន្ទឹមនេះដែរ ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦ ដែលក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលស្ថិតក្រោមក្រសួង ស្ថាប័ននីមួយៗបានរៀបចំ គឺជាមូលដ្ឋានដ៏សំខាន់សម្រាប់ពន្យល់ និងធ្វើអំណះអំណាងអំពីលទ្ធភាព និងកិច្ចខិតខំក្នុងការប្រមូលចំណូល និងតម្រូវការចំណាយសម្រាប់រយៈពេល៣ឆ្នាំរំកិល(២០១៦-២០១៨) សម្រាប់សម្រេចគោលបំណងគោលនយោបាយរបស់ខ្លួន ដែលជាការរួមចំណែកអនុវត្ត "**យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣**" និង "**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨**"។ នៅក្នុងដំណាក់កាលទី២នេះ រាជរដ្ឋាភិបាល ត្រូវចេញសារាចរណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ សម្រាប់ជាមូលដ្ឋាន និងជាក្របខណ្ឌនៃការរៀបចំកញ្ចប់ថវិកាឆ្នាំ២០១៦ របស់គ្រប់ក្រសួង ស្ថាប័ន ដោយគ្របដណ្តប់ទាំងថវិកាមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ និងគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលជារដ្ឋបាលថ្នាក់ជាតិ។ ក្នុងស្មារតីនេះ សារាចរនេះដាក់ចេញនូវក្របខណ្ឌនិងវិធានការប្រមូលចំណូល ការកំណត់អាទិភាពចំណាយតាមវិស័យ និងកំណត់គោលការណ៍សំខាន់ៗសម្រាប់បង្កើនប្រសិទ្ធភាពនៃការវិភាជថវិកា ដោយផ្អែកលើលទ្ធភាពជាក់ស្តែងនៃថវិកាជាតិ អាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល និងប្រសិទ្ធភាពនៃការអនុវត្តថវិការបស់ក្រសួង ស្ថាប័នផងដែរ។ ដោយឡែក ចំពោះការរៀបចំកញ្ចប់ថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានសារាចរណែនាំដោយ

ឡែកមួយទៀតចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដោយឈរលើមូលដ្ឋាននិងគោលការណ៍ដែលមានចែងនៅក្នុងសារាចរណែនាំនេះ ជាពិសេសគោលការណ៍នៃការកំណត់កញ្ចប់ និងគោលការណ៍នៃការវិភាជថវិកាទៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីចូលរួមបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធនៃការប្រមូលចំណូល និងប្រសិទ្ធភាពនៃការវិភាជនិងភាពស័ក្តិសិទ្ធនៃការអនុវត្តចំណាយទាំងកម្រិតបច្ចេកទេស និងប្រតិបត្តិការក្នុងគោលដៅរួមចំណែកកាត់បន្ថយឱនភាពថវិកា និង រក្សាអតិរេកសាច់ប្រាក់។

២-ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ស្ថិតក្នុងបរិការណ៍ដែលព្រះរាជាណាចក្រកម្ពុជាកំពុងមានសុខសន្តិភាព ឯកភាពជាតិ និងស្ថិរភាពនយោបាយ ប្រកាន់ខ្ជាប់នូវគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស,ព្រមទាំងមានការរីកចម្រើនយ៉ាងឆាប់រហ័សលើគ្រប់ផ្នែក និងគ្រប់វិស័យ ហើយកំពុងក្លាយខ្លួនជាប្រទេសចំណូលមធ្យមកម្រិតទាប។ ប្រការនេះបានបង្កលក្ខខណ្ឌអំណោយផល និងស្ថានភាពអនុគ្រោះ សម្រាប់ជាមូលដ្ឋានក្នុងការកសាងអនាគតកម្ពុជាមួយដ៏រុងរឿង និងត្រចះត្រចង់។ ទន្ទឹមនឹងនេះ ការពង្រីកវប្បធម៌នៃការសន្ទនាគ្នា ដោយឈរលើមូលដ្ឋានគោរពឧត្តមប្រយោជន៍ជាតិ និងប្រជាជននាពេលថ្មីៗនេះ ក៏នឹងកាន់តែផ្តល់នូវឱកាស និងភាពងាយស្រួលដល់រាជរដ្ឋាភិបាល ក្នុងការបន្តអនុវត្តការកែទម្រង់ឱ្យកាន់តែស៊ីជម្រៅ និងគ្រប់ជ្រុង-ជ្រោយ ដើម្បីឆ្លើយតបទៅតាមឆន្ទៈនិងបំណងប្រាថ្នារបស់ប្រជាជនកម្ពុជាផង និង ដើម្បីឆ្លើយតបទៅនឹងដំណើរការនៃការផ្លាស់ប្តូររចនាសម្ព័ន្ធរបស់សង្គម-សេដ្ឋកិច្ចកម្ពុជាផង ព្រមទាំងការប្រែប្រួលនិមាបនកម្មសេដ្ឋកិច្ច និងភូមិសាស្ត្រនយោបាយ ទាំងក្នុងកម្រិតតំបន់ និងពិភពលោក។

៣- ទោះបីកម្ពុជាត្រូវជួបប្រទះនូវបញ្ហាប្រឈមគ្រប់បែបយ៉ាង ទាំងក្នុង និងក្រៅប្រទេសក៏ដោយក៏រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា, ចាប់តាំងតែពីដើមនីតិកាលរហូតមក, នៅតែអាចតស៊ូពុះពារ និងជំនះបាននូវរាល់ឧបសគ្គ និង ការលំបាកផងទាំងពួង ហើយធានាបាននូវប្រក្រតីភាពនៃដំណើរការសង្គម-សេដ្ឋកិច្ចកម្ពុជា។ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជាធានាបានល្អប្រសើរនូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, គ្រប់គ្រងអតិផរណាឱ្យស្ថិតក្នុងកម្រិតទាបសមរម្យ, ធានាស្ថិរភាពនៃអត្រាប្តូរប្រាក់ ព្រមទាំងពង្រឹងឡើងថែមទៀតនូវសមត្ថភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ តាមរយៈការជំរុញការអនុវត្តវិធានការនានា សំដៅពន្លឿនពិពិធកម្មសេដ្ឋកិច្ច រួមមានជាអាទិ៍ ការបង្កើនផលិតភាពនៃវិស័យកសិកម្ម, ការកសាងមូលដ្ឋានសេដ្ឋកិច្ចជនបទ និងការធ្វើឱ្យកាន់តែល្អប្រសើរនូវបរិយាកាសអំណោយផលសម្រាប់ទាក់ទាញការវិនិយោគឯកជន ដែលប្រការទាំងអស់នេះបានបង្កើតការងារជូនប្រជាជនកម្ពុជា, ពិសេសយុវជន, ជាច្រើនសែននាក់ក្នុងមួយឆ្នាំៗ។ ជាក់ស្តែង នៅក្នុងរបាយការណ៍របស់ធនាគារពិភពលោកឆ្នាំ២០១៤ ប្រទេសកម្ពុជាត្រូវបានចាត់បញ្ចូលក្នុងក្រុមប្រទេសឯកទគ្គករកំណើនទាំងប្រាំបីនៅក្នុងពិភពលោក ( Olympians of Growth ) ដែលមានកំណើនសេដ្ឋកិច្ចខ្ពស់ និងរឹងមាំ។

៤- ស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសកលនៅឆ្នាំ២០១៥ និង២០១៦ ខាងមុខ ត្រូវបានវាយតម្លៃថាមានស្ថានភាពល្អ ទោះបីជាមានបញ្ហាវិវាទភូមិសាស្ត្រនយោបាយ និងភូមិសាស្ត្រសេដ្ឋកិច្ចនៅក្នុងតំបន់មួយចំនួនក្តី។ តាមការព្យាករ សេដ្ឋកិច្ចអាមេរិកនឹងនៅបន្តមានកំណើនល្អ ក្នុងខណៈដែលសេដ្ឋកិច្ច

តំបន់ចាយប្រាក់អឺរ៉ូត្រូវបានរំពឹងថាចាប់ផ្តើមមានកំណើនជាវិជ្ជមានឡើងវិញ ទោះបីកំណើននេះមានកម្រិតទាបក៏ដោយ។ ចំណែកឯសេដ្ឋកិច្ចធំៗក្នុងតំបន់អាស៊ី ដូចជាជប៉ុនជាដើម នឹងបន្តមានកំណើនវិជ្ជមាន ហើយប្រទេសចិននឹងនៅតែអាចបន្តរក្សាកំណើនខ្ពស់បានដដែល ទោះបីជាយឺតជាងពេលមុនបន្តិចក៏ដោយ។ ចំណែកសេដ្ឋកិច្ចប្រទេសឥណ្ឌា និងអាស៊ាន៥ វិញ នឹងអាចរក្សាបានកំណើនក្នុងកម្រិតមធ្យមក្នុងរង្វង់ពី ៥% ទៅ ៦%។ ជានិន្នាការសកល តម្លៃប្រេងនឹងស្ថិតនៅក្នុងស្ថានភាពទាប, ថ្លៃកសិផលបន្តធ្លាក់ចុះ ហើយប្រាក់ដុល្លារអាមេរិករំពឹងថានឹងកើនឡើងតម្លៃ។ ការវាយតម្លៃខ្លះបានបង្ហាញថាសេដ្ឋកិច្ចពិភពលោកកំពុងស្ថិតក្នុងនិន្នាការនៃ "**ប្រក្រតីថ្មី**" បន្ទាប់ពីវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិភពលោក ឆ្នាំ២០០៨។ ជារួម ស្ថានភាពបែបនេះ នឹងផ្តល់លក្ខណៈអំណោយផលមួយចំនួនដល់សេដ្ឋកិច្ចកម្ពុជា ប៉ុន្តែក៏បង្កើតឡើងនូវបញ្ហាប្រឈមថ្មីៗថែមទៀត។

៥- នៅក្នុងបរិបទតំបន់ ឆ្នាំ២០១៦ ជាឆ្នាំដែលតំបន់អាស៊ានកំពុងអនុវត្តក្របខណ្ឌសហគមន៍សេដ្ឋកិច្ចមួយ។ ពិតណាស់ថា នៅក្នុងដំណើរការសមាហរណកម្មនេះ កម្ពុជានឹងទទួលបាននូវផលប្រយោជន៍ច្រើន ពីលំហូរកាន់តែសេរីនូវទំនិញ មូលធន និងពលករជំនាញ ដែលជាឱកាសឱ្យកម្ពុជាប្រើប្រាស់បានកាន់តែច្រើននូវសក្តានុពលសម្រាប់ការអភិវឌ្ឍវិស័យឧស្សាហកម្ម ដែលផ្សារភ្ជាប់ទៅនឹងអ្វីដែលគេហៅថា"**ខ្សែចង្វាក់ផលិតកម្មពិភពលោក**"នៅតំបន់អាស៊ី។ ប៉ុន្តែកម្ពុជាអាចនឹងទទួលរងនូវផលប៉ះពាល់អវិជ្ជមានមួយចំនួននៅក្នុងរយៈពេលខ្លីផងដែរ ពិសេសការថយចុះនៃចំណូលពន្ធពីពាណិជ្ជកម្មអន្តរជាតិដែលអាចប៉ះពាល់ជាយថាហេតុដល់ចីរភាពថវិកា។ ក្នុងន័យនេះ កម្ពុជាចាំបាច់ត្រូវបន្តរៀបចំខ្លួនឱ្យបានល្អពិសេសការបន្តនូវការកែទម្រង់សំខាន់ៗ ស្របតាមការតម្រូវដើម្បីទាញយកអត្ថប្រយោជន៍ជាអតិបរមាពីសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥ និងតទៅអនាគត ព្រមទាំងត្រូវបន្តធ្វើការកែទម្រង់លើគ្រប់វិស័យឱ្យបានខ្លាំងក្លា និងស៊ីជម្រៅបន្ថែមទៀតដើម្បីពង្រឹងភាពប្រកួតប្រជែងក្នុងការទាក់ទាញការវិនិយោគ និងបង្កើនតម្លៃបន្ថែមឱ្យបានខ្ពស់ ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចខ្ពស់ឱ្យមានចីរភាព។

៦- ដោយផ្អែកលើចំណុចខ្លាំង, កត្តាអំណោយផល, បញ្ហាប្រឈម និងហានិភ័យ ដូចខាងលើ ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ត្រូវបានកំណត់លើមូលដ្ឋានសុទិដ្ឋិនិយម ជាមួយនឹងការប្រុងប្រយ័ត្នខ្ពស់ ដែលរួមមានខ្លឹមសារសំខាន់ៗ ដូចខាងក្រោម៖

## II. ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០១៦

### ក. ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចឆ្នាំ២០១៦

៧- ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា នៅតែមានលក្ខណៈរឹងមាំនៅក្នុងឆ្នាំ២០១៤ និងក្នុងរយៈពេលមធ្យម ដោយសារកំណើនខ្ពស់នៃវិស័យសំណង់ ភាពល្អប្រសើរនៃវិស័យទេសចរណ៍ និងការនាំចេញសំលៀកបំពាក់មានភាពកាន់តែប្រសើរ ជាមួយនឹងការធ្លាក់ចុះនៃថ្លៃប្រេងទីផ្សារអន្តរជាតិ។ នៅក្នុងឆ្នាំ២០១៤ កន្លងទៅ សេដ្ឋកិច្ចកម្ពុជាសម្រេចបានកំណើនក្នុងអត្រា ៧% តាមការរំពឹងទុក ជាមួយនឹង

អតិផរណាមធ្យមប្រចាំឆ្នាំ ក្នុងអត្រាប្រមាណ ៣,៩% និងអត្រាប្តូរប្រាក់មធ្យមប្រមាណ ៤ ០៣៩រៀល ក្នុងមួយដុល្លារសហរដ្ឋអាមេរិក។ កំណើនសេដ្ឋកិច្ចឆ្នាំ២០១៤ សម្រេចបានល្អ ដោយសារ (១)-វិស័យឧស្សាហកម្មមានកំណើន ១០,៤% ដែលក្នុងនោះ វិស័យសំណង់បាននាំមុខជាលើកទីមួយដោយមានកំណើនរហូតដល់២១,៤% និងវិស័យកាត់ដេរសម្រេចបានកំណើន ៦,៩% (២)-វិស័យសេវាមានកំណើន ៩,១% ដែលក្នុងនោះ វិស័យទេសចរណ៍មានកំណើន ៧,៣% និងវិស័យអចលនទ្រព្យមានកំណើន ១៣,៨% និង (៣)-វិស័យកសិកម្មបានធ្លាក់ចុះ ១,៤% ដែលក្នុងនោះ វិស័យជលផលធ្លាក់ចុះ ៨,៨% និងដំណាំមានកំណើន ១,៥%។ ការបន្តមានកំណើនខ្ពស់បែបនេះ បានធ្វើឱ្យចំណូលជាតិសរុបសម្រាប់ប្រជាជនម្នាក់ៗ កើនឡើងដល់១ ១២៣ដុល្លារអាមេរិក ជាកម្រិតចំណូលដែលកម្ពុជាកំពុងក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតទាប។

៨- នៅក្នុងឆ្នាំ២០១៥ និង ឆ្នាំ២០១៦ តាមការព្យាករ កម្ពុជានឹងសម្រេចបានកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៧%, ហើយផ.ស.ស.តាមថ្លៃចរន្តឆ្នាំ២០១៥ ត្រូវបានប៉ាន់ស្មានស្មើនឹងចំនួន៧៤ ៤៦០ ៩៣៨ លានរៀល និង ផ.ស.ស.តាមថ្លៃចរន្តឆ្នាំ២០១៦ ត្រូវបានគ្រោងចំនួន៨១ ៩៣៤ ៣៣៣ លានរៀល ។ កំណើននេះ បានមកពី៖

- វិស័យកសិកម្ម អាចសម្រេចបានកំណើនប្រមាណ ៤,៥% នៅឆ្នាំ២០១៥ និងប្រមាណ ៤,៣% នៅឆ្នាំ២០១៦ ក្នុងនោះដោយសារការកើនឡើងនូវដំណាំស្រូវ និងដំណាំឧស្សាហកម្ម ពិសេសកៅស៊ូដែលនឹងបន្តកើនឡើងក្នុងកម្រិតខ្ពស់ ព្រោះផ្ទៃដីត្រូវដល់ពេលប្រមូលផលមានចំនួនកាន់តែច្រើន។ ប៉ុន្តែ វិស័យកសិកម្ម នឹងត្រូវប្រឈមជាមួយនឹងបញ្ហាផលិតភាពទាប ពិសេសដំណាំស្រូវ។ ក្នុងន័យនេះ ដើម្បីសម្រេចបាននូវកំណើនខាងលើ រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់ក្នុងការដោះស្រាយបញ្ហាផលិតភាពទាបនេះ តាមរយៈការបន្តវិនិយោគបន្ថែមលើហេដ្ឋារចនាសម្ព័ន្ធ និងបច្ចេកវិទ្យា, ការផ្សព្វផ្សាយកសិកម្ម និង ការសិក្សាស្រាវជ្រាវ, ព្រមទាំងជំរុញការផ្តល់ហិរញ្ញប្បទាន។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាល នឹងផ្តោតការយកចិត្តទុកដាក់ផងដែរលើការជំរុញមច្ឆវប្បកម្ម និងការចិញ្ចឹមសត្វបន្ថែមដោយផ្សារភ្ជាប់ជាមួយនឹងការគិតគូរទៅដល់តុល្យភាពបរិស្ថាន។

- វិស័យឧស្សាហកម្មអាចនឹងសម្រេចបានកំណើនប្រមាណ ៩,៦% នៅឆ្នាំ២០១៥ និងរក្សា ៩,៦% នៅឆ្នាំ២០១៦ ដោយសារការបន្តកើនឡើងនៃវិស័យកាត់ដេរ ការបន្តការរីកចម្រើននៃវិស័យថាមពល និងសំណង់ ព្រមទាំងការរីកចម្រើននៃវិស័យឧស្សាហកម្មធុនស្រាល ពិសេសសក្តានុពលក្នុងការនាំចេញផលិតផលឧស្សាហកម្មមួយចំនួន ដូចជាគ្រឿងបង្គុំអេឡិចត្រូនិចជាដើម។ វិស័យសំណង់នឹងមានកំណើនថមថយបន្តិចមកវិញ ដោយសារវដ្តនៃកំណើនវិស័យនេះជាធម្មតាតែងមានរយៈពេលមួយខ្លី ហើយវិស័យកាត់ដេរនឹងនៅតែបន្តដើរតួនាទីជាជន្ទល់ទ្រទ្រង់កំណើនដដែល។ ក៏ប៉ុន្តែចំណែកទីផ្សារនៃផលិតផលសំលៀកបំពាក់ និងស្បែកជើងរបស់កម្ពុជាក្នុងពិភពលោក មាននិន្នាការធ្លាក់ចុះក្នុងខណៈដែលកំណើននៃការធ្វើពាណិជ្ជកម្មផលិតផលនេះនៅលើទីផ្សារពិភពលោកមានការកើនឡើង បើទោះបីរាជរដ្ឋាភិបាលបានខិតខំជួយទ្រទ្រង់វិស័យនេះច្រើនមកហើយក្តី។ មូលហេតុនៃការធ្លាក់ចុះនេះ បណ្តាលមកពីការកើនឡើងនូវសមត្ថភាពប្រកួតប្រជែងរបស់ប្រទេសជិតខាងយើងក្នុងតំបន់ ក្នុងខណៈដែលវិស័យកាត់ដេររបស់កម្ពុជា នៅមានផលិតភាពទាប, បញ្ហាទំនាក់ទំនងវិជ្ជាជីវៈ និងនិន្នាការនៃការ

កើនឡើងនូវប្រាក់ឈ្នួល ព្រមទាំងបញ្ហាផ្នែកសម្របសម្រួលស្ថាប័ន និងនីតិវិធីពាក់ព័ន្ធ។ ដើម្បីដោះស្រាយបញ្ហានេះ រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់ដល់ការបង្កើនផលិតភាពការងារ, ការបន្តធ្វើសុខដុមនីយកម្មក្នុងទំនាក់ទំនងវិជ្ជាជីវៈ ពិសេសការបង្កើនតម្លៃបន្ថែមរបស់វិស័យកាត់ដេរ និងការកែលម្អនីតិវិធីរដ្ឋបាល ព្រមទាំងការសម្រួលពាណិជ្ជកម្ម។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងជំរុញការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា២០១៥-២០២៥ ដើម្បីជំរុញកែប្រែ និងធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មកម្ពុជា ពីឧស្សាហកម្មអតិពលកម្ម ឈានទៅឧស្សាហកម្មផ្អែកលើជំនាញ។ ក្នុងគោលដៅនេះ រាជរដ្ឋាភិបាលនឹងបង្កើនការវិនិយោគសាធារណៈលើវិស័យអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ បច្ចេកទេស ឱ្យសមស្របតាមតម្រូវការទីផ្សារ, ការផ្គត់ផ្គង់ថាមពលអគ្គិសនី, និងការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូនគ្រប់ប្រភេទឱ្យក្លាយជាប្រព័ន្ធឡូជីស្ទីកមួយដ៏រស់រវើក និងមានភាពប្រកួតប្រជែងនៅក្នុងគោលដៅលើកកម្ពស់វិនិយោគ, ពាណិជ្ជកម្ម, ទេសចរណ៍ និង អភិវឌ្ឍន៍ជនបទ ព្រមទាំងការធ្វើឱ្យប្រសើរឡើងថែមទៀតនូវកិច្ចសម្រួលពាណិជ្ជកម្ម។

- កំណើនក្នុងវិស័យសេវាអាចនឹងសម្រេចបាន ៦,៦% នៅឆ្នាំ ២០១៥ និង ៦,៥% នៅឆ្នាំ ២០១៦ ដោយសារការកើនឡើងនៃវិស័យដឹកជញ្ជូននិងទូរគមនាគមន៍, វិស័យទេសចរណ៍, វិស័យហិរញ្ញវត្ថុ និងអចលនទ្រព្យ ជាពិសេសសេវាគាំទ្រផ្នែកឧស្សាហកម្ម។ វិស័យទេសចរណ៍នឹងនៅតែបន្តដើរតួនាទីជាជន្ទល់ទ្រទ្រង់កំណើនដដែល ប៉ុន្តែចាំបាច់ត្រូវបន្តធ្វើពិពិធកម្មឱ្យអស់សក្តានុពល ដើម្បីបង្កើនតម្លៃបន្ថែមនៃវិស័យនេះ ក្នុងសេដ្ឋកិច្ចជាតិ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលនឹងបន្តយកចិត្តទុកដាក់លើហានិភ័យមួយចំនួន ដែលអាចកើតឡើងពីផ្នែកអចលនទ្រព្យ និងមីក្រូហិរញ្ញវត្ថុ, ទន្ទឹមនឹងការជំរុញអភិវឌ្ឍវិស័យហិរញ្ញវត្ថុឱ្យកាន់តែខ្លាំងក្លា ទាំងវិស័យធនាគារ ទាំងវិស័យមិនមែនធនាគារ។

- អតិផរណាស្ថិតនៅក្នុងកម្រិតគ្រប់គ្រងបាន ទោះបីមានការប្រែប្រួលថ្លៃសម្ភារប្រើប្រាស់ និងម្ហូបអាហារ មួយចំនួនក៏ដោយ។ អត្រាអតិផរណាមធ្យមប្រចាំឆ្នាំ២០១៥ និងឆ្នាំ ២០១៦ រំពឹងថានឹងមានកម្រិតក្នុងរង្វង់ ៣,៥% ដោយសារតម្លៃប្រេងនៅលើទីផ្សារអន្តរជាតិនៅតែមានកម្រិតទាប និង ថ្លៃកសិផលមានការធ្លាក់ចុះ។ អត្រាប្តូរប្រាក់ រំពឹងថាមានតម្លៃជាមធ្យម៤ ០៥០ រៀលក្នុង ១ដុល្លារអាមេរិក នៅឆ្នាំ២០១៥ និងឆ្នាំ២០១៦។ ប្រាក់រៀលរំពឹងថាបន្តមានស្ថិរភាព និងមានបរិមាណកើនឡើង ដោយសារកំណើនសេដ្ឋកិច្ចខ្ពស់របស់កម្ពុជា និងការជឿទុកចិត្តពីសាធារណជន ពិសេសការបន្តអនុវត្តគោលនយោបាយគ្រប់គ្រងសាច់ប្រាក់ក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ និងគោលនយោបាយរូបិយវត្ថុសមស្រប ព្រមទាំងការអនុវត្តគោលនយោបាយជំរុញការប្រើប្រាស់ប្រាក់រៀលរបស់រាជរដ្ឋាភិបាល ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

- នៅឆ្នាំ ២០១៤ ឱនភាពគណនីចរន្តបានថយចុះមកត្រឹម ១១,២% នៃផ.ស.ស (ធ្លាក់ពី ១២,៥% នៃផ.ស.ស ក្នុងឆ្នាំ២០១៣) ដោយសារការកើនឡើងការនាំចេញលឿនជាងការនាំចូល។ តាមការព្យាករ ឱនភាព គណនីចរន្តរំពឹងថានឹងបន្តធ្លាក់ចុះដល់ ១០,៣% នៃផ.ស.ស នៅឆ្នាំ ២០១៥ និង ៩,៧% នៃផ.ស.ស នៅឆ្នាំ២០១៦។ និន្នាការនៃការធ្លាក់ចុះនេះ ដោយសារសមត្ថភាពនាំចេញរបស់កម្ពុជាមានការកើនឡើងជាលំដាប់ ទន្ទឹមនឹងផលិតផល និងវត្ថុធាតុដើមមួយចំនួន ចាប់ផ្តើមមានមូលដ្ឋានផលិតនៅក្នុងស្រុកជំនួសការនាំចូលជាបណ្តើរៗ។ នៅឆ្នាំ ២០១៥ ទុនបម្រុងនឹងមានទំហំ

៥ ១៤៤ លានដុល្លារអាមេរិក និងអាចកើនឡើងលើសពី ៥ ៧៣៩ លានដុល្លារអាមេរិក នៅឆ្នាំ ២០១៦ ដែលធានាបានប្រមាណជាង ៤,៥ ខែ នៃការនាំចូលទំនិញ និងសេវាប្រើប្រាស់ក្នុងស្រុក។

៩- ជារួមក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចនេះត្រូវបានរៀបចំឡើង ដើម្បីរក្សាឱ្យបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព ស្ថិរភាពតម្លៃ ការបង្កើតការងារ និងចីរភាពថវិកា និងបំណុល ព្រមទាំងស្ថិរភាពជញ្ជីងទូទាត់។ ដើម្បីសម្រេចគោលបំណងខាងលើ រាជរដ្ឋាភិបាលបានកំណត់គោលដៅកំណើន ផ.ស.ស ឱ្យសម្រេចបានក្នុងរង្វង់ ៧% សម្រាប់ឆ្នាំ ២០១៥ និងឆ្នាំ ២០១៦។ ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលនឹងខិតខំគ្រប់គ្រងអតិផរណាមធ្យមប្រចាំឆ្នាំឱ្យស្ថិតនៅក្រោម ៥% ក្នុងមួយឆ្នាំ ពោលគឺនៅក្នុងរង្វង់ ៣,៥% នៅឆ្នាំ ២០១៥ និង នៅឆ្នាំ ២០១៦ ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាល នឹងធានាឱ្យបានស្ថិរភាពអត្រាប្តូរប្រាក់រៀលឱ្យស្ថិតនៅក្នុងរង្វង់ ៤ ០៥០ រៀលក្នុង ១ដុល្លារសហរដ្ឋអាមេរិក ដោយខិតខំជំរុញបដិដុល្លារូបិយកម្មសេដ្ឋកិច្ចនៅចំពោះមុខ និងរយៈពេលវែង។

## ខ- ក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងថវិកាឆ្នាំ ២០១៦

១០- ក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងថវិកាឆ្នាំ២០១៦ ត្រូវបានរៀបចំដោយឈរលើមូលដ្ឋាននៃក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចឆ្នាំ២០១៦ និង"**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣**" និង "**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**" ដោយមានគោលបំណងសំខាន់ៗ ដូចតទៅៈ

- បន្តធានាសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយបរិយាប័ន្ននិងចីរភាព ព្រមទាំងធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពហិរញ្ញវត្ថុ ក្នុងបរិការណ៍នៃអត្រាអតិផរណាទាប និងអត្រាប្តូរប្រាក់មានស្ថិរភាព
- ធានាការការពារអធិបតេយ្យ និងបូរណភាពទឹកដី ដើម្បីបន្តរក្សាសុខសន្តិភាព សន្តិសុខ ស្ថិរភាព នយោបាយ និងសណ្តាប់ធ្នាប់សាធារណៈសង្គម
- បន្តធានាអនុវត្តគោលនយោបាយដើម្បីជំរុញកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពដើម្បីបន្តកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងបែងចែកផ្លែផ្កានៃកំណើន ប្រកបដោយសមធម៌ដល់គ្រប់ស្រទាប់វណ្ណៈនៃប្រជាជន
- ជំរុញអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨
- បន្តផ្តល់អាទិភាពដល់ការតម្លើងប្រាក់បៀវត្សរបស់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ឆ្ពោះទៅសម្រេចគោលដៅឱ្យបានជាង ១ លានរៀល នៅឆ្នាំ២០១៨ ដោយផ្សារភ្ជាប់ទៅនឹងការកែទម្រង់ប្រព័ន្ធបៀវត្ស និងការកែទម្រង់រដ្ឋបាលសាធារណៈ ពិសេសការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសារណៈ ២០១៥-២០១៨ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ
- បន្តធានាអនុវត្តកម្មវិធីកែទម្រង់ចាំបាច់នានារបស់រាជរដ្ឋាភិបាល ឱ្យមានលក្ខណៈស៊ីជម្រៅ និងទទួលបានលទ្ធផលជាផ្លែផ្កាជាក់ស្តែងជាបណ្តើរៗរួមមានៈ ការកែទម្រង់ប្រព័ន្ធកងកម្លាំង

ប្រដាប់អាវុធ, ការកែទម្រង់រិមជ្ឈការនិងវិសហមជ្ឈការ, ការកែទម្រង់ប្រព័ន្ធយុត្តិធម៌និងតុលាការ, ការកែទម្រង់ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ

- បន្តជំរុញការអភិវឌ្ឍធនធានមនុស្សតាមរយៈការលើកកម្ពស់គុណភាពអប់រំ ការបណ្តុះបណ្តាលជំនាញ វិជ្ជាជីវៈនិងបច្ចេកទេស ព្រមទាំងការលើកកម្ពស់សេវាសុខាភិបាល
- បន្តជំរុញការលើកទឹកចិត្តក្នុងការងារស្រាវជ្រាវ និងការអភិវឌ្ឍផ្នែកបច្ចេកទេស និងវិទ្យាសាស្ត្រ
- បន្តជំរុញការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធចាំបាច់នានាសម្រាប់គាំទ្រដល់កំណើន និងការអភិវឌ្ឍ
- ធានាការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ប្រកបដោយប្រសិទ្ធភាព
- បន្តការជំរុញការអភិវឌ្ឍវិស័យកសិកម្ម ពិសេសបន្តធានាការអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ ការចិញ្ចឹមសត្វនិងវារីវប្បកម្ម ព្រមទាំងផលិតកម្មម្ហូបអាហារ
- ពង្រឹង និងពង្រីកលំហថវិកា រួមទាំងយន្តការគ្រប់គ្រងវិបត្តិដើម្បីទប់ទល់វិបត្តិកលិយុគ និងហានិភ័យផ្សេងៗដែលអាចកើតមានឡើងជាយថាហេតុ ជាពិសេសបំពេញឡើងវិញនូវប្រាក់បញ្ញើរដ្ឋ ព្រមទាំងកាត់បន្ថយការពឹងផ្អែកលើហិរញ្ញប្បទានក្រៅប្រទេស
- បន្តពង្រឹងការអនុវត្តគោលនយោបាយគ្រប់គ្រងបំណុលសាធារណៈ ឱ្យស្ថិតក្នុងកម្រិតមួយដែលអាចគ្រប់គ្រងបាន និងប្រកបដោយចីរភាព
- បន្តពង្រឹងស្ថាប័នសាធារណៈ និងប្រព័ន្ធអភិបាលកិច្ច ដើម្បីធានាប្រសិទ្ធភាព, គណនេយ្យភាព និងតម្លាភាព និងធានាបានសមធម៌សង្គម ហើយផ្តល់ឱកាសស្មើគ្នា និងប្រកបដោយសមធម៌
- លើកកម្ពស់គុណភាព ពង្រីកការទទួលបានភាពពេញចិត្តនិងប្រសិទ្ធភាពនៃសេវាសាធារណៈ។

១១- ក្នុងបរិបទ និងទស្សនៈវិស័យម៉ាក្រូសេដ្ឋកិច្ចបានរៀបរាប់រួចមកហើយ និងក្នុងទិសដៅសម្រេចឱ្យបាននូវគោលបំណងខាងលើ រាជរដ្ឋាភិបាលបានកំណត់ក្របខណ្ឌថវិកាឆ្នាំ២០១៦ រួមជាមួយនឹងវិធានការគោលនយោបាយជាក់លាក់ទាំងផ្នែកចំណូល និង ផ្នែកចំណាយសម្រាប់ឆ្នាំ២០១៦ ដូចខាងក្រោម៖

## ក្របខណ្ឌចំណូលថវិកាឆ្នាំ ២០១៦

១២- គម្រោងចំណូលថវិកាឆ្នាំ២០១៦ ត្រូវបានកំណត់ដូចតទៅ ៖

-ចំណូលសរុបក្នុងប្រទេសសម្រាប់ឆ្នាំ២០១៦ គ្រោងសម្រេចឱ្យបាន១៧,៥១% នៃផ.ស.ស. គឺមានកំណើន១,៦៥ពិន្ទុភាគរយនៃផ.ស.ស. ឬកើន ២១,៥% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ (ច្បាប់ឆ្នាំ២០១៥) ក្នុងនោះ

- ចំណូលចរន្តថវិការដ្ឋត្រូវសម្រេចឱ្យបានប្រមាណ១៧,៣៥% នៃផ.ស.ស. គឺកើនឡើង ១,៦៧ពិន្ទុភាគរយ នៃផ.ស.ស. ឬកើន ២១,៧% ធៀបនឹងច្បាប់ឆ្នាំ២០១៥។ **ចំណូល**

**ពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**ត្រូវគ្រោងសម្រេចឱ្យបាន៨,៤២%នៃផ.ស.ស. គឺមានកំណើន១,៣៤ពិន្ទុភាគរយ នៃផ.ស.ស. ឬកើន៣០,៩% ធៀបនឹងច្បាប់ឆ្នាំ២០១៥, **ចំណូលពីអគ្គនាយកដ្ឋានពន្ធដារ**ត្រូវគ្រោងសម្រេចឱ្យបាន ៥,៧០%នៃផ.ស.ស. គឺមានកំណើន ០,២៩ពិន្ទុភាគរយ នៃផ.ស.ស. ឬកើន១៦,០% ធៀបនឹងច្បាប់ឆ្នាំ២០១៥, **ចំណូលសារពើពន្ធផ្សេងទៀត**ត្រូវសម្រេចឱ្យបាន០,៣៦% នៃផ.ស.ស. គឺមានកំណើន ០,០២ពិន្ទុភាគរយនៃផ.ស.ស. ឬកើន ១៦,០% ធៀបនឹងច្បាប់ឆ្នាំ២០១៥, និង**ចំណូលមិនមែនសារពើពន្ធ**ត្រូវគ្រោងសម្រេចឱ្យបាន១,៩៩% នៃផ.ស.ស. គឺ ថយចុះ ០,០២ ពិន្ទុភាគរយនៃផ.ស.ស. តែមានកំណើន ៨,៩% ធៀបនឹងច្បាប់ឆ្នាំ២០១៥។

- **ចំណូលមូលធនក្នុងស្រុក**ត្រូវសម្រេចឱ្យបាន០,១៦% នៃផ.ស.ស. គឺថយចុះ ០,០២ពិន្ទុភាគរយ នៃផ.ស.ស. ឬថយ ២,០% ធៀបនឹងច្បាប់ឆ្នាំ២០១៥។
- ដោយឡែក **ហិរញ្ញប្បទានក្រៅប្រទេសសម្រាប់អនុវត្តគម្រោងវិនិយោគសាធារណៈ** គ្រោងសម្រេចឱ្យបាន៤,៩២%នៃផ.ស.ស. គឺថយចុះ០,៤៣ ពិន្ទុភាគរយនៃផ.ស.ស. តែមានកំណើន ១,២% ធៀបនឹងច្បាប់ឆ្នាំ២០១៥។

១៣- ជារួមដើម្បីសម្រេចគោលដៅចំណូលសរុបខាងលើនេះ រាជរដ្ឋាភិបាលពុំមានគោលការណ៍បង្កើតបន្ទុកពន្ធថ្មី ឬតម្លើងពន្ធបន្ថែមដល់ប្រជាជន និងធុរជននោះទេ។ រាជរដ្ឋាភិបាលនឹងផ្តោតលើការពង្រឹងការអនុវត្តគោលនយោបាយនិងច្បាប់ដែលមានស្រាប់ តាមរយៈការអនុវត្តវិធានការយ៉ាងម៉ឺងម៉ាត់ និងមុតស្រួច ទាំងតាមវិធានការរដ្ឋបាល និងវិធានការគោលនយោបាយ ទាំងសម្រាប់រយៈពេលខ្លី មធ្យម និងវែង ពិសេសការលើកកម្ពស់វប្បធម៌បង់ពន្ធ ការបង្ក្រាបអំពើរត់ពន្ធនិងការគេចវេសពន្ធគ្រប់រូបភាពឱ្យដល់ឫសគល់ ព្រមទាំងការកែលម្អអភិបាលកិច្ចក្នុងការប្រមូលចំណូល ទាំងក្នុងផ្នែកគយ និង ផ្នែកពន្ធដារ ព្រមទាំងផ្នែកមិនមែនសារពើពន្ធ ជាពិសេស តាមរយៈការជំរុញអនុវត្តប្រកបដោយភាពស័ក្តិសិទ្ធនូវ **យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨** ដែលក្នុងនោះ ក្របខណ្ឌនៃវិធានការសំខាន់ៗ មានដូចតទៅ៖

១៤- **វិធានការផ្នែកចំណូលគយ និងរដ្ឋាករ មានដូចខាងក្រោម៖**

- បន្តពង្រឹងវិធានបង្ការ ទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធគយគ្រប់រូបភាព
- បន្តពង្រឹងការប្រកាសគយ តាមរយៈការពង្រឹងការគ្រប់គ្រងឯកសារនាំចេញ-នាំចូល និងការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ ពិសេសចំពោះមុខទំនិញវេទយិតលើចំណូលពន្ធគយមួយចំនួន
- ពង្រឹងការកំណត់ និង ធ្វើចំណាត់ថ្នាក់ហានិភ័យ តាមរយៈការកែលម្អប្រព័ន្ធគ្រប់គ្រងហានិភ័យ និងពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មានសម្ងាត់គយ
- ពង្រឹងប្រសិទ្ធភាព និងពង្រីកវិសាលភាពនៃការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ ដើម្បីបង្កើនអនុលោមភាពនៃការបំពេញកាតព្វកិច្ចបង់ពន្ធអាករគយឱ្យបានត្រឹមត្រូវ

- សិក្សា និងវាយតម្លៃពីលទ្ធភាពនៃការអនុវត្តឱ្យបានពេញលេញនូវកាតព្វកិច្ចប្រកាសតម្លៃគិតពន្ធគយ លើទំនិញនាំចេញ-នាំចូល ក្រោមរបបអនុគ្រោះពន្ធតាមតម្លៃចម្លងការ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការ កំណត់ពន្ធគយ និងដើម្បីបញ្ចៀសនូវការបាត់បង់ចំណូល
- ជំរុញការប្រើប្រាស់ប្រព័ន្ធអាស៊ីគូដាឱ្យអស់សក្តានុពល ដើម្បីធានាឱ្យប្រព័ន្ធអាស៊ីគូដាអាចអនុវត្តបានទាំងស្រុងនូវមុខងារទាំងអស់ និងដើម្បីពង្រីកវិសាលភាពនៃការប្រើប្រាស់ប្រព័ន្ធនេះ
- ជំរុញការដាក់ឱ្យអនុវត្តប្រព័ន្ធបញ្ចរជាតិតែមួយឱ្យបានពេញលេញតាមបទប្បញ្ញត្តិជាធរមាន
- បន្តពង្រឹងយន្តការសហប្រតិបត្តិការរវាងគយ និងវិស័យឯកជន
- វាយតម្លៃរៀងរាល់ត្រីមាសលើការបាត់បង់ចំណូលពន្ធអាករគយ ពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន និងប្រទេសដៃគូផ្សេងទៀត និងស្នើឡើងនូវវិធានការសមស្រប
- រៀបចំផែនការអភិវឌ្ឍស្ថាប័ន កែលម្អការត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីកែទម្រង់គយ
- បន្តពង្រឹងក្រមសីលធម៌ និងកិរិយាមាយាទមន្ត្រីគយ។

១៥- **វិធានការផ្នែកចំណូលពន្ធដារ មានដូចខាងក្រោម៖**

- បន្តពង្រឹងការចុះបញ្ជីពន្ធដារតាមប្រព័ន្ធថ្មី និងបន្តធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសទាំង-អស់ដែលបានចុះបញ្ជីពន្ធដារក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង និងប្រមូលចំណូល
- បន្តពង្រឹង និងកែលម្អការផ្តល់សេវាដល់អ្នកជាប់ពន្ធ
- បន្តកែលម្អការចាត់ចែងលិខិតប្រកាសពន្ធ ដោយផ្តោតទៅលើ៖ (១). ការរៀបចំយន្តការឱ្យអ្នកជាប់ពន្ធអាចដាក់លិខិតប្រកាសតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងបង់ប្រាក់ពន្ធតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីកាត់បន្ថយបន្ទុកចំណាយ និងពេលវេលារបស់អ្នកជាប់ពន្ធ និងរដ្ឋបាលសារពើពន្ធ, (២).អនុវត្តវិធានការលុបចោលការចុះបញ្ជីឬដកវិញ្ញាបនបត្រអាករលើតម្លៃបន្ថែមជាបណ្តោះអាសន្នចំពោះអ្នកជាប់ពន្ធ ដែលមិនបានដាក់លិខិតប្រកាសអាករលើតម្លៃបន្ថែមក្នុងរយៈពេល ៣ ខែជាប់គ្នា, និង (៣). កំណត់អត្រាគោលដៅនៃការដាក់លិខិតប្រកាសឱ្យបានខ្ពស់ជាអតិបរមា បន្ទាប់ពីបានធ្វើការលុបឈ្មោះអ្នកជាប់ពន្ធចេញពីបញ្ជី ដើម្បីវាយតម្លៃហានិភ័យអ្នកជាប់ពន្ធឱ្យបានទាន់ពេលវេលា
- បន្តពង្រឹងប្រសិទ្ធភាព និង ធ្វើឱ្យប្រសើរឡើងនូវការធ្វើសវនកម្មពន្ធដារ ទាំងសវនកម្មមានកម្រិត និងសវនកម្មពេញលេញ ដោយផ្តោតការយកចិត្តទុកដាក់លើ៖ (១).កែលម្អវិធីសាស្ត្រកំណត់ហានិភ័យដែលមានស្រាប់ រួមទាំងជ្រើសរើសក្រុមហ៊ុនធំៗជាអាទិភាពក្នុងការធ្វើ-សវនកម្ម និងរៀបចំសារាចរណែនាំដើម្បីដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវស្តង់ដាររួម ដែលមានកំណត់ត្រាបង្ហាញពីឥរិយាបថហានិភ័យរបស់អ្នកជាប់ពន្ធ ដើម្បីប្រើជាការជ្រើសរើសអ្នកជាប់ពន្ធដែលត្រូវធ្វើសវនកម្ម, (២) រៀបចំរបាយការណ៍លទ្ធផលសវនកម្ម និងផ្តល់មតិត្រលប់វិញដើម្បីផ្ទៀងផ្ទាត់ការកំណត់ហានិភ័យមុនពេលចុះសវនកម្ម និងសម្រាប់កែលម្អវិធីសាស្ត្រកំណត់ហានិភ័យនៅពេលក្រោយ និងធ្វើការវាយតម្លៃឥរិយាបថអ្នកជាប់ពន្ធ, (៣).

ជំរុញការអនុវត្តកាតព្វកិច្ចផ្តល់របាយការណ៍ហិរញ្ញវត្ថុ ដែលធ្វើសវនកម្មដោយស្នងការគណនេយ្យឯករាជ្យ ដើម្បីពង្រឹងការគោរពច្បាប់និងបន្ថយបន្ទុកសវនកម្ម និង (៤). រៀបចំសារាចរណែនាំស្តីពីការធ្វើសវនកម្មលើវិស័យសំខាន់ៗមួយចំនួន រួមមានៈ ធនាគារ, សំណង់, ដឹកជញ្ជូន និងទូរគមនាគមន៍ ដើម្បីឱ្យសវនករងាយស្រួលក្នុងការអនុវត្តសវនកម្ម និងបង្កើនប្រសិទ្ធភាពសវនកម្ម

- បង្កើតការិយាល័យស៊ើបអង្កេតបទល្មើសពន្ធដារ និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់មន្ត្រីស៊ើបអង្កេតបទល្មើសពន្ធដារ
- អនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការតឹងទារបំណុលពន្ធ ដែលមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ ដូចជា ការរឹបអូស ឬការឃុំគ្រងទ្រព្យសម្បត្តិរបស់អ្នកជាប់បំណុលពន្ធ និងការប្តឹងអ្នកជំពាក់បំណុលពន្ធទៅតុលាការ
- ជំរុញការបង្កើនចំណូលពីអាករលើតម្លៃបន្ថែម តាមរយៈ៖ (១). រៀបចំកែប្រែអនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែម ដោយបន្ថយកម្រិតផលរបរប្រចាំឆ្នាំសម្រាប់សហគ្រាសជាប់ពន្ធតាមរបបស្វ័យប្រកាស ដើម្បីពង្រីកមូលដ្ឋានយកពន្ធ និងបង្កើនចំណូលអាករលើតម្លៃបន្ថែម និងពន្ធដទៃទៀត, (២).បញ្ឈប់ការលើកលែងអាករលើតម្លៃបន្ថែមលើវិស័យដែលមិនមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធ
- ពង្រឹងការគ្រប់គ្រងរបបម៉ៅការ និងជំរុញការអនុវត្តរបបស្វ័យប្រកាស តាមរយៈ៖ (១). រៀបចំបទប្បញ្ញត្តិសម្រាប់អ្នកជាប់ពន្ធតាមរបបម៉ៅការ ដោយតម្រូវឱ្យបង់ពន្ធប៉ាតង់ប្រចាំឆ្នាំរួមបញ្ចូលទាំងការបង់ប្រាក់អាករលើផលរបរ និងពន្ធលើប្រាក់ចំណេញក្នុងមួយឆមាសម្តងឬមួយឆ្នាំម្តង ដើម្បីបន្ថយបន្ទុករបស់អ្នកជាប់ពន្ធ និងផ្ទេរមន្ត្រីទៅបម្រើការងារនៅកន្លែងដែលមានចំណូលខ្ពស់, (២). រៀបចំ និងដាក់ឱ្យអនុវត្តនូវរបបស្វ័យប្រកាសបំព្រួញ និងតម្រូវឱ្យអនុវត្តកាតព្វកិច្ចកាន់បញ្ជីគណនេយ្យ ដែលមានលក្ខណៈសាមញ្ញសម្រាប់អ្នកជាប់ពន្ធក្នុងរបបនេះ។
- ពិនិត្យឡើងវិញចំពោះការលើកទឹកចិត្តពន្ធក្នុងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធការវិនិយោគ
- ពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ពិសេសអាជ្ញាធរមូលដ្ឋាន ក្នុងការប្រមូលពន្ធលើអចលនទ្រព្យ
- បន្តពង្រឹងកម្មវិធីផ្សព្វផ្សាយ និងការអប់រំពន្ធ ដើម្បីលើកកម្ពស់វប្បធម៌បង់ពន្ធ
- បន្តពង្រឹងក្រមសីលធម៌ និងកិរិយាមាយាទមន្ត្រីពន្ធដារ។

១៦- **វិធានការផ្នែកចំណូលមិនមែនសារពើពន្ធ មានដូចខាងក្រោម៖**

- ពង្រឹងប្រសិទ្ធភាពនៃការប្រមូល និងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដោយធ្វើ-សវនកម្ម ក្រសួង ស្ថាប័ន និងអង្គភាពនៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលប្រមូល

ចំណូលប្រភេទនេះ ពិសេសរៀបចំនិងដាក់ឱ្យអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ

- ពង្រឹងការគ្រប់គ្រង ការប្រើប្រាស់ និងចាត់ចែងទ្រព្យសម្បត្តិរដ្ឋ តាមរយៈការធ្វើសវនកម្មលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង ស្ថាប័ន និងអង្គភាពនៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ពិសេស រៀបចំ និងដាក់ឱ្យអនុវត្តច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បន្តតាមដានការប្រមូលចំណូល ឬការលាក់ទុកចំណូលរបស់ក្រសួង ស្ថាប័ន និងអង្គភាពនៃរដ្ឋបាល ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ហើយមានវិធានការលើកទឹកចិត្តសមស្របសម្រាប់ស្ថាប័នទាំងឡាយណា ដែលប្រមូលចំណូលបានល្អ និងមានវិធានការរដ្ឋបាលតឹងរ៉ឹងចំពោះស្ថាប័ន និងមន្ត្រីពាក់ព័ន្ធ ដែលប្រមូលចំណូលមិនបានល្អ ឬលាក់ចំណូល ដោយមិនរាប់បញ្ចូលនូវទោសទណ្ឌផ្សេងទៀត
- បន្តស្រាវជ្រាវ និងកំណត់ឱ្យបានច្បាស់នូវបំណុលមិនមែនសារពើពន្ធគ្រប់ប្រភេទ រួចបង្កើតយន្តការតឹងទារបំណុលទាំងនោះដោយចាត់វិធានការព្រមាន ដកហូតអាជ្ញាបណ្ណ លុបចោលកិច្ចសន្យា ឬបង្កកគណនីនៅធនាគារពាណិជ្ជ និងវិធានការចាំបាច់ផ្សេងៗទៀត តាមការ-អនុញ្ញាតរបស់ច្បាប់ក្នុងករណីក្រុមហ៊ុនមិនមានចំណាត់ការណាមួយក្នុងការសងបំណុល
- ពង្រឹងការគ្រប់គ្រងកាស៊ីណូ និងចំណូលពីកាស៊ីណូ តាមរយៈការរៀបចំ និងដាក់ឱ្យអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងកាស៊ីណូ
- ពង្រឹងការគ្រប់គ្រងធនធានប្រេងកាត និងរ៉ែ តាមរយៈការរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធពន្ធលើប្រតិបត្តិការប្រេងកាត និងធនធានរ៉ែ, ទន្ទឹមនឹង ការសិក្សា និងធ្វើការកែប្រែតម្លៃនៃកម្រៃអាជ្ញាបណ្ណ និងកម្រៃសួយសារសម្រាប់ការរុករក និងការធ្វើអាជីវកម្មធនធានរ៉ែគ្រប់ប្រភេទ, ការបន្តរៀបចំទិន្នន័យ និងប្រព័ន្ធតាមដានកាតព្វកិច្ចហិរញ្ញវត្ថុទៅលើកិច្ចសន្យានិងអាជ្ញាបណ្ណដែលបានផ្តល់រួច
- រៀបចំ និងដាក់ឱ្យអនុវត្តឱ្យមានប្រសិទ្ធភាពនូវការបង់កម្រៃនៅក្នុងការលក់ ឬផ្ទេរសិទ្ធិភាគ-ហ៊ុននៅក្នុងកិច្ចសន្យាជួលកោះ, តំបន់ឆ្នេរ និង តំបន់រមណីយដ្ឋាននានា និងអនុវត្តការបង់ពន្ធប្រថាប់ត្រាតាមច្បាប់ជាធរមាន
- ពង្រឹងការប្រមូលចំណូលពាក់ព័ន្ធនឹងវិស័យទេសចរណ៍ ដូចជាការលក់សំបុត្រទស្សនាប្រាសាទ រមណីយដ្ឋាន និងទីតាំងប្រវត្តិសាស្ត្រផ្សេងៗ
- បន្តជំរុញឱ្យគ្រប់ចំណុចគោលដៅដែលមានសមត្ថកិច្ចផ្តល់ទិដ្ឋាការជូនភ្ញៀវទេសចរ រៀបចំរបាយការណ៍ស្តីពីចំណូលអាករស្ថានទូត ,ស្ថានភាពប្រើប្រាស់សន្លឹកទិដ្ឋាការ និងស្ថានភាពប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ប្រចាំខែ, ប្រចាំត្រីមាស, ប្រចាំឆមាស និងប្រចាំឆ្នាំឱ្យបានទៀង-ទាត់ និងច្បាស់លាស់

Rw

- ពង្រឹងការបង់ចំណូលថវិកាពីថ្លៃសម្បទានដីសេដ្ឋកិច្ច និងផល-អនុផលព្រៃឈើពីព្រៃឈើពីសម្បទានិក តាមរយៈការរៀបចំ និងដាក់ឱ្យអនុវត្តនូវបទប្បញ្ញត្តិមួយចំនួន ពាក់ព័ន្ធនឹងការលក់និងការផ្ទេរសិទ្ធិសម្បទានដីសេដ្ឋកិច្ច, នីតិវិធីនៃការបង់ថ្លៃសម្បទានដីសេដ្ឋកិច្ច, ការ-បង្កើនយន្តការនិងនីតិវិធីក្នុងការគ្រប់គ្រងនិងការប្រមូលចំណូលពីផល-អនុផលព្រៃឈើលើដីសម្បទានសេដ្ឋកិច្ច, វារីអគ្គិសនី, ទំនប់ អាង ស្រោចស្រព និងពីប្រភពផ្សេងៗទៀត
- រៀបចំ និងដាក់ឱ្យអនុវត្តការបង់កម្រៃនៅក្នុងការលក់ ឬផ្ទេរសិទ្ធិភាគហ៊ុននៅក្នុងសម្បទានដីសេដ្ឋកិច្ច និងអនុវត្តការបង់ពន្ធប្រថាប់ត្រាតាមច្បាប់ជាធរមាន
- ពង្រឹងប្រសិទ្ធភាពការប្រមូលចំណូលពីការផ្តល់អាជ្ញាបណ្ណក្នុងវិស័យទេសចរណ៍ តាមរយៈការបង្កើតការស្នើសុំអាជ្ញាបណ្ណទេសចរណ៍តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន, ការធ្វើចំណាត់ថ្នាក់សណ្ឋាគារ និងការបង្កើតឱ្យមានប្រព័ន្ធចំណាត់ថ្នាក់សេវាកម្មទេសចរណ៍គ្រប់ប្រភេទ
- បន្តពង្រឹងការគ្រប់គ្រង និងលើកកម្ពស់អភិបាលកិច្ចសាជីវកម្មរបស់សហគ្រាសសាធារណៈទាំងអស់តាមរយៈត្រួតពិនិត្យលើកិច្ចដំណើរការអាជីវកម្ម និងចំណាយលើការវិនិយោគប្រចាំឆ្នាំ, ធ្វើការផ្ទៀងផ្ទាត់ស្ថានភាពប្រែប្រួលនៃបញ្ជីសារពើភ័ណ្ឌ និងការធ្វើសវនកម្មពេញលេញលើផ្នែកហិរញ្ញវត្ថុ, ព្រមទាំងពង្រឹងការអនុវត្តនូវកាតព្វកិច្ចបង់ភាគលាភប្រចាំឆ្នាំចូលថវិការដ្ឋ
- ពង្រឹងការគ្រប់គ្រងគ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងអស់ តាមរយៈការសិក្សា និងរៀបចំឡើងវិញនូវក្របខណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្ត រួមទាំងការកែលម្អលក្ខន្តិកៈគតិយុត្តឱ្យស្របតាមការរីកចម្រើននៃសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា និង ដើម្បីផ្តល់លទ្ធភាពដល់អង្គភាពរដ្ឋទាំងឡាយណាដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទៅជាគ្រឹះស្ថាន ក៏ដូចជាដើម្បីជំរុញការអភិវឌ្ឍស្ថាប័នរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលដែលមានស្រាប់,
- លើកកម្ពស់ការគ្រប់គ្រងវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ដោយធ្វើវិសោធនកម្មច្បាប់ស្តីពីប្រៃសណីយ៍ និងជំរុញការរៀបចំ និងដាក់ឱ្យអនុវត្តច្បាប់ស្តីពីទូរគមនាគមន៍,
- ធ្វើការវាយតម្លៃអំពីប្រសិទ្ធភាពនៃការប្រមូលចំណូលពីកម្រៃសេវាសាធារណៈរបស់រដ្ឋ ដោយផ្សារភ្ជាប់ជាមួយនឹងការសិក្សា អំពីភាពប្រកួតប្រជែងរបស់កម្ពុជា ពាក់ព័ន្ធនឹងកម្រៃសេវានីមួយៗនៅក្នុងតម្លៃនៃការធ្វើធុរកិច្ច, អាជីវកម្ម និងពាណិជ្ជកម្មជារួមដោយប្រៀបធៀបជាមួយប្រទេសជិតខាងក្នុងតំបន់ ដើម្បីដាក់ចេញជាយុទ្ធសាស្ត្រធ្វើការកែតម្រូវកម្រៃសេវានិងរង្វាន់លើកទឹកចិត្តផ្សារភ្ជាប់ជាមួយនឹងការកែទម្រង់បៀវត្សក្នុងគោលដៅបង្កើនសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា,
- រៀបចំ និងដាក់ឱ្យអនុវត្តជាជំហានៗនូវកម្រៃសេវាធ្វើដំណើរ ដោយក្នុងនោះអាចចាប់ផ្តើមពីកម្រៃសេវាធ្វើដំណើរតាមផ្លូវអាកាសមុន ដើម្បីប៉ះប៉ូវដល់លទ្ធភាពនៃការបាត់បង់ចំណូលពីការបន្តផ្តល់ការលើកលែងទិដ្ឋាការនាពេលខាងមុខ
- ពិនិត្យឡើងវិញ និងធ្វើកែប្រែជាយថាហេតុលើកិច្ចព្រមព្រៀងឬកិច្ចសន្យាណាមួយ ដែលមិនឆ្លុះបញ្ចាំងពីវឌ្ឍនភាពសង្គម ឬមិនផ្តល់ផលប្រយោជន៍សមស្របសម្រាប់ភាគីរាជរដ្ឋាភិបាល

- ជំរុញការវាយតម្លៃដីធ្លីរបស់ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងនីតិបុគ្គលសាធារណៈដែលស្ថិតនៅក្រៅតារាងតម្លៃពន្ធអចលនទ្រព្យ និងការចុះបញ្ជីសារពើភ័ណ្ឌនូវដីធ្លី ដែលបានដោះស្រាយរួចតាមរយៈគោលនយោបាយដោះស្រាយផលប៉ះពាល់។

## ***ក្របខណ្ឌចំណាយថវិកាឆ្នាំ ២០១៦***

១៧- គម្រោងចំណាយថវិកាឆ្នាំ២០១៦ ត្រូវបានកំណត់ និងវិភាជ ដូចតទៅ ៖

- ចំណាយសរុបសម្រាប់ឆ្នាំ២០១៦ ត្រូវបានគ្រោងត្រឹម២១,២៨%នៃផ.ស.ស. គឺកើនឡើង ០,២០ពិន្ទុភាគរយនៃផ.ស.ស. ឬកើន១១,១% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ២០១៥(ច្បាប់ឆ្នាំ២០១៥)។ ក្នុងនោះ**ចំណាយចរន្ត**នឹងកម្រិតត្រឹម១៣,២៨% នៃផ.ស.ស. (កើនឡើង០,១១ពិន្ទុភាគរយ នៃផ.ស.ស. ស្មើនឹង១០,៩% ធៀបនឹងច្បាប់ឆ្នាំ ២០១៥) ដោយផ្តោតអាទិភាពលើការបង្កើន**ចំណាយបៀវត្ស**សម្រាប់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធឱ្យបាន ៤៨,៤៨% នៃចំណាយចរន្តសរុប ឬ ស្មើប្រមាណ ៦,៤៤% នៃផ.ស.ស.។ **ចំណាយមូលធន**នឹងត្រូវរក្សាឱ្យនៅត្រឹម៨,០%នៃផ.ស.ស. គឺកើនឡើង ០,០៩ពិន្ទុភាគរយ នៃផ.ស.ស. ឬកើន១១,២% ធៀបនឹងច្បាប់ឆ្នាំ២០១៥។ **ចំណាយមូលធនដោយហិរញ្ញប្បទានក្នុងស្រុក** ត្រូវកំណត់ក្នុងកម្រិត ២,៦៥%នៃ ផ.ស.ស. គឺកើនឡើង ០,២៧ពិន្ទុភាគរយនៃផ.ស.ស. ឬកើន២២,៩% ធៀបនឹងច្បាប់ឆ្នាំ២០១៥ និង**ចំណាយសម្រាប់រំលស់បំណុល**ត្រូវកំណត់ត្រឹម០,៦២% នៃផ.ស.ស. គឺកើន ០,៣០ពិន្ទុភាគរយនៃផ.ស.ស. ឬកើន១៦,៦% ធៀបនឹងច្បាប់ឆ្នាំ២០១៥។ ទន្ទឹមនឹងនេះ **ចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស**ត្រូវបានគ្រោងក្នុងកម្រិត៤,៧២%នៃផ.ស.ស. គឺថយចុះ០,២៣ពិន្ទុភាគរយនៃផ.ស.ស. តែមានកំណើន ៥% ធៀបនឹងច្បាប់ឆ្នាំ២០១៥។
- **ចំណាយចរន្តថវិកាថ្នាក់ជាតិ**ត្រូវបានវិភាជទៅតាមវិស័យនីមួយៗ ដូចតទៅ: **វិស័យសង្គមកិច្ច**ស្មើនឹង ៤,៨៤%នៃផ.ស.ស. គឺមានកំណើន ០,០៣ពិន្ទុភាគរយ នៃផ.ស.ស. ធៀបនឹងច្បាប់ឆ្នាំ២០១៥, **វិស័យសេដ្ឋកិច្ច**ស្មើនឹង ១,៣៥%នៃផ.ស.ស. គឺមានកំណើន០,០១ពិន្ទុភាគរយនៃផ.ស.ស. ធៀបនឹងច្បាប់ឆ្នាំ២០១៥, **វិស័យរដ្ឋបាលទូទៅ**ស្មើនឹង ១,៦៨%នៃផ.ស.ស. គឺទាបជាង ០,០៩ពិន្ទុភាគរយនៃផ.ស.ស. ធៀបនឹងច្បាប់ឆ្នាំ២០១៥, **វិស័យការពារជាតិ សន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ** ស្មើនឹង ៣,១០%នៃផ.ស.ស. គឺទាបជាង ០,០១ពិន្ទុភាគរយនៃផ.ស.ស. ធៀបនឹងច្បាប់ឆ្នាំ២០១៥។ ជារួម កំណើនចំណាយនៅឆ្នាំ២០១៦ គឺត្រូវបានផ្តល់អាទិភាពលើការតម្លើងបៀវត្សមន្ត្រីរាជការ។
- ថវិការាជធានី ខេត្ត, ក្រុង ស្រុក ខណ្ឌ និង ឃុំ-សង្កាត់ ត្រូវកំណត់ត្រឹម១,៣៧%នៃផ.ស.ស មានកំណើន០,០៦ពិន្ទុភាគរយនៃផ.ស.ស. ធៀបនឹងច្បាប់ឆ្នាំ២០១៥ ដែលក្នុងនោះថវិកាផ្ទាល់របស់រាជធានី ខេត្តសរុបមានប្រមាណ០,៧៥%នៃផ.ស.ស. និងថវិកាឧបត្ថម្ភពីថ្នាក់

ជាតិដល់រាជធានី ខេត្ត ស្មើនឹង ០,១៣%នៃផ.ស.ស., ថវិកាឧបត្ថម្ភពីថ្នាក់ជាតិដល់ក្រុង ស្រុក ខណ្ឌ ស្មើនឹង០,១២%នៃផ.ស.ស. ឬស្មើនឹង០,៩% នៃចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ២០១៥, និង ថវិកាឧបត្ថម្ភពីថ្នាក់ជាតិដល់មូលនិធិថវិកាឃុំ-សង្កាត់ឆ្នាំ២០១៥ ស្មើនឹង ០,១២%នៃផ.ស.ស. ឬស្មើនឹង ២,៨០%នៃចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ២០១៥។

១៨- ក្នុងក្របខណ្ឌនៃគោលដៅចំណាយខាងលើនេះ រាជរដ្ឋាភិបាល នឹងជំរុញការអនុវត្ត យុទ្ធសាស្ត្រ និង ក្របខណ្ឌនៃវិធានការដើម្បី ***បង្កើនប្រសិទ្ធភាពចំណាយ*** ដូចខាងក្រោម៖

- បង្កើនការរៀបចំថវិកាឱ្យកាន់តែផ្សារភ្ជាប់ទៅនឹងគោលនយោបាយ តាមរយៈការបង្កើន ប្រសិទ្ធភាពនៃការវិភាជថវិកាឱ្យកាន់តែមានមូលដ្ឋានច្បាស់លាស់ និងចំទិសដៅ ពិសេសការ ពង្រឹងអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងពង្រីកការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកា ពីចំនួន១០ ក្រសួង ស្ថាប័ន នៅក្នុងឆ្នាំ២០១៥ ឱ្យឡើងដល់ ២៥ ក្រសួង ស្ថាប័ន នៅឆ្នាំ២០១៦
- លើកកម្ពស់ប្រសិទ្ធភាពបច្ចេកទេស និងប្រតិបត្តិការចំណាយ តាមរយៈការបង្កើនតម្លៃនៃ លុយ ដោយផ្តោតការយកចិត្តទុកដាក់លើភាពសមស្របនៃថ្លៃ, បរិមាណ, គុណភាព និង ភាពទាន់ពេលក្នុងចំណាយថវិកា ទាំងចំណាយចរន្ត (ចំណាយបន្ទុកបុគ្គលិក និងចំណាយ មិនមែនបន្ទុកបុគ្គលិក) និង ចំណាយមូលធន
- ពង្រឹងការគ្រប់គ្រង និងការជ្រើសរើសមន្ត្រីរាជការឱ្យបានត្រឹមត្រូវ និងហ្មត់ចត់ រួមទាំង បុគ្គលិកជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត ក្នុងគោលបំណងឈានទៅសម្រេចគោលដៅនៃ ការតម្លើងបៀវត្សជូនដល់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ឱ្យបានច្រើនជាង១ លានរៀល នៅឆ្នាំ២០១៨ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និង បង្កើនកម្រិតជីវភាពរបស់មន្ត្រីរាជការឱ្យកាន់តែល្អប្រសើរ
- រឹតត្បិតចំពោះមុខសញ្ញាចំណាយណាដែលមិនចាំបាច់ ឬមិនមែនអាទិភាព ដើម្បីសន្សំថវិកា យកទៅអនុវត្តសកម្មភាពអាទិភាព ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពនៃសេវាសាធារណៈ ព្រមទាំងបង្កើនផលិតភាព និងទ្រទ្រង់កំណើនសេដ្ឋកិច្ច។
- បន្តធ្វើវិចារណកម្ម និងរឹតបន្តឹងចំណាយក្នុងគោលបំណងរក្សាឱនភាពថវិកាឱ្យនៅត្រឹម កម្រិតសមរម្យមួយដែលមិនប៉ះពាល់ចិរភាពថវិកា និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងបង្កើន "**លំហថវិកា**" សម្រាប់ដោះស្រាយតម្រូវការបន្ទាន់ ករណីប្រធានស័ក្តិ និងវិបត្តិផ្សេងៗ ឬតម្រូវ ការចំណាយចាំបាច់ភ្លាមៗរបស់រាជរដ្ឋាភិបាលនាពេលអនាគត ព្រមទាំងការកាត់បន្ថយការ ពឹងផ្អែកលើហិរញ្ញប្បទានក្រៅប្រទេស
- អនុវត្តឱ្យមានប្រសិទ្ធភាពនូវក្របខណ្ឌគោលនយោបាយស្តីពីការគ្រប់គ្រងហានិភ័យបំណុល ព្រមទាំង ពង្រឹងបន្ថែមសមត្ថភាពស្ថាប័នដែលពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ ក្នុងគោលដៅបន្តរក្សាចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈ

- បង្កើនការសន្សំសំចៃថវិកា តាមរយៈការលើកកម្ពស់ប្រសិទ្ធភាពចំណាយថវិកាលើមុខចំណាយទំនិញ និងសេវា មួយចំនួនដូចជា ប្រេងឥន្ធនៈ អគ្គិសនី សេវាទូរគមនាគមន៍ និងអ៊ិនធើណែត ការកាត់បន្ថយនូវបេសកកម្ម ទាំងក្នុងនិងក្រៅប្រទេស និងការបោះពុម្ពដែលមានគុណភាពប្រណិតហើយមានតម្លៃខ្ពស់
- បន្តផ្តល់អាទិភាពចំណាយលើវិស័យអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ សុខាភិបាល សំណាញ់សុវត្ថិភាព កសិកម្ម ដីធ្លី និងអភិវឌ្ឍន៍ជនបទ
- បន្តផ្តល់អាទិភាពដល់សកម្មភាពថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលបានកសាងរួច ជាពិសេស ផ្លូវថ្នល់ និង ប្រព័ន្ធធារាសាស្ត្រស្រោចស្រព
- បន្តវិនិយោគលើការពង្រីក និងកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាពិសេស ផ្លូវថ្នល់ ផ្លូវដែក កំពង់ផែ ប្រព័ន្ធធារាសាស្ត្រស្រោចស្រព អគ្គិសនី ទឹកស្អាត សាលារៀន និង មន្ទីរពេទ្យ ។ល។
- បង្កើនវិនិយោគសាធារណៈឱ្យចំវិស័យដែលផ្តល់ផលិតភាពខ្ពស់ក្នុងគោលដៅទ្រទ្រង់កំណើនប្រកបដោយចីរភាព ដូចជា វិស័យកសិកម្ម និងវិស័យគាំទ្រដើម្បីជំរុញផលិតភាព តម្លៃបន្ថែម និង ជំរុញការកែច្នៃ និងនាំចេញផលិតកសិ-ឧស្សាហកម្ម និងកសិផល ការចិញ្ចឹមសត្វ និងវារីវប្បកម្ម ដើម្បីគាំទ្រដល់ការជំរុញផលិតកម្មម្ហូបអាហារ
- បន្តពង្រឹងការគ្រប់គ្រងចំណាយសាធារណៈ ជាពិសេសបន្តពង្រឹងជំរុញការកែលម្អការអនុវត្តថវិកា តាមរយៈការបន្តកាត់បន្ថយនីតិវិធីចំណាយ ការបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ការបន្តពង្រឹងការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស ការបន្តត្រួតពិនិត្យការអនុវត្តថវិកាប្រចាំត្រីមាស និងឆមាស ការបន្តពង្រឹងការត្រួតពិនិត្យផ្ទៃក្នុង ដើម្បីបន្តពង្រឹងភាពជឿទុក-ចិត្ត បាននៃថវិកាដែលសម្រេចបាន និងបន្តបង្កើនប្រសិទ្ធភាពគណនេយ្យភាពហិរញ្ញវត្ថុ
- អនុវត្តឱ្យមានប្រសិទ្ធភាព និងតម្លាភាពនូវការងារលទ្ធកម្មនៃចំណាយសាធារណៈ និងពង្រឹងការអនុវត្តច្បាប់លទ្ធកម្មសាធារណៈ។

## ក្របខណ្ឌតុល្យភាពថវិកាឆ្នាំ ២០១៦

១៩- រាជរដ្ឋាភិបាល មានការចាំបាច់ក្នុងការធ្វើវិចារណកម្មចំណាយ ដើម្បីកាត់បន្ថយឱនភាពថវិកាឱ្យមកត្រឹមកម្រិតមួយសមរម្យ ស្របតាមគោលការណ៍អន្តរជាតិ និងតំបន់ តាមរយៈការរឹតបន្តឹងនិងសន្សំសំចៃចំណាយ ដើម្បីបង្កើន "**លំហថវិកា**" សម្រាប់ដោះស្រាយសេចក្តីត្រូវការបន្ទាន់ក្នុងការងារអភិវឌ្ឍន៍ ក៏ដូចជាសម្រាប់ត្រៀមដាយថាហេតុចាំបាច់ផ្សេងទៀត ពិសេសត្រៀមសម្រាប់ដោះស្រាយទប់ទល់នឹងវិបត្តិ ដោះស្រាយបញ្ហាគ្រោះធម្មជាតិ ដោះស្រាយតម្រូវការចំណាយសម្រាប់ការការពារអធិបតេយ្យនិងបូរណភាពទឹកដី ក៏ដូចជាសម្រាប់ឆ្លើយតបទៅនឹងសេចក្តីត្រូវការក្នុងការអនុវត្តគោលនយោបាយថ្មី ដែលអាចត្រូវបានដាក់ចេញនៅក្នុងឆ្នាំអនុវត្ត។ ក្នុងក្របខ័ណ្ឌចំណាយខាងលើ អតិរេកថវិកាចរន្តសម្រាប់ឆ្នាំ២០១៦ គ្រោងសម្រេចឱ្យបានប្រមាណ ៤,០៧% នៃផ.ស.ស. ចំណែកឯឱនភាពថវិកាសរុបត្រូវបានកាត់បន្ថយឱ្យនៅត្រឹម៣,៧៧% នៃផ.ស.ស.។ ការថយចុះនៃឱនភាពថវិកានឹងជួយដល់ការគ្រប់គ្រងបំណុលប្រកបដោយចីរភាពក្នុងគោលដៅជំរុញការអភិវឌ្ឍនៅក្នុងល្បឿនខ្ពស់។ ទំហំ

តុល្យភាពខាងលើ គឺអាចធានាបាននូវចីរភាពថវិកាដែលជាកត្តាគន្លឹះសម្រាប់ធានាបាននូវស្ថិរភាពម៉ាក្រូ-សេដ្ឋកិច្ច សម្រាប់ផ្តល់ភាពអនុគ្រោះដល់កំណើនសេដ្ឋកិច្ច ជាពិសេស បង្កើននូវប្រាក់បញ្ញើរបស់រាជ-រដ្ឋាភិបាលឡើងវិញ ដើម្បីមានមូលដ្ឋានកាន់តែរឹងមាំសម្រាប់ទប់ទល់នឹងវិបត្តិខាងក្រៅ និងកាត់បន្ថយហានិភ័យផ្សេងៗ ដែលអាចកើតមានឡើងដោយថាហេតុ។

## III- គោលការណ៍ និងបច្ចេកទេសនៃការរៀបចំថវិកាឆ្នាំ២០១៦

### ក- ការគ្រោងចំណូលថវិកាឆ្នាំ២០១៦

២០- ការគ្រោងគិតចំណូលថវិកាចរន្ត អាស្រ័យលើប្រភពធនធាននៃផលិតផល ឬផលទុនដែលជាប្រភពចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ។ ដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ច និង លក្ខខណ្ឌនៃប្រភពធនធានដូចបានលើកឡើងខាងលើ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំគម្រោងចំណូលថវិការបស់ខ្លួនដូចតទៅ៖

- ចំណូលសារពើពន្ធត្រូវគិតគូរដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម៖
  - លទ្ធផលដែលទទួលបាននៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ
  - ចំណូលបន្ថែមដែលសង្ឃឹមថាប្រមូលបានដោយសារការពង្រឹង និងកែលម្អរដ្ឋបាល និងគោលនយោបាយពន្ធដារ គោលនយោបាយគយនិងរដ្ឋាករ ការធ្វើវិចារណកម្មសារពើពន្ធ និងការប្រមូលបំណុលពន្ធដែលត្រូវទារ
  - ការប៉ាន់ស្មានលើការអភិវឌ្ឍសេដ្ឋកិច្ច និងអាជីវកម្មនៅពេលខាងមុខ
  - ការប្រែប្រួលដែលអាចកើតមានឡើង ព្រមទាំងការត្រួតពិនិត្យ និងពិចារណាទៅលើអត្រា និងមូលដ្ឋានប្រមូលពន្ធ
- ចំពោះចំណូលមិនមែនសារពើពន្ធ ត្រូវគិតគូរទៅតាមកិច្ចការដែលនាំឱ្យមានផលទុន ដូចជាកិច្ចសន្យាសម្បទានគ្រប់ប្រភេទ កិច្ចសន្យាជួលសេវាកម្ម ការពង្រឹងនិងកែលម្អការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងការប្រមូលបំណុលដែលត្រូវទារជាដើម។ល។

### ខ-ការគ្រោងចំណាយថវិកាឆ្នាំ២០១៦

២១- ចំពោះក្រសួង **ស្ថាប័ន អនុវត្តថវិកាកម្មវិធី** ព្រមទាំង មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ការរៀបចំថវិកាត្រូវយកចិត្តទុកដាក់អំពីប្រសិទ្ធភាពនៃការបែងចែកថវិកាទៅតាមកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព និង ជាពិសេស លទ្ធផលឬធាតុចេញ (Output)ដែលនឹងសម្រេចបាន ដើម្បីសម្រេចគោលបំណងគោលនយោបាយដែលបានដាក់ចេញនៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័ន។ ប្រការនេះ ជាមូលដ្ឋានយ៉ាងសំខាន់សម្រាប់ធ្វើជាអំណះអំណាង និងគាំទ្រដល់ការរៀបចំ និងការចរចាថវិកា ព្រមទាំងជាមូលដ្ឋានសម្រាប់ធ្វើវិមជ្ឈការនីតិវិធីអនុវត្តចំណាយ។ ដោយឡែក ចំពោះ **ក្រសួង ស្ថាប័នអនុវត្តថវិកាមិនមែនកម្មវិធី** ព្រមទាំង មន្ទីរជំនាញរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ការរៀបចំគម្រោងឥណទានចំណាយថវិកាត្រូវផ្អែកលើតម្រូវការចំណាយជាក់ស្តែង និង ដោយផ្ទាល់ សម្រាប់អនុវត្តសកម្មភាពការងាររបស់

អង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដើម្បីសម្រេចគោលដៅនៃយុទ្ធសាស្ត្រអាទិភាព និងគោលបំណងគោលនយោបាយ ដែលបានដាក់ចេញនៅក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័ន។ *សូមរៀបចំគម្រោងថវិកាតាមតារាងគំរូដែលភ្ជាប់មកជាមួយសារាចរណែនាំនេះ។*

២២- គ្រប់ក្រសួង **ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត** ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ គម្រោងចំណាយចាំបាច់ត្រូវមានការឆ្លុះបញ្ចាំងដោយលម្អិតទៅតាមមាតិកាសេដ្ឋកិច្ចនៃចំណាត់ថ្នាក់ថវិកា(ជំពូក គណនី និងអនុគណនី) ព្រមទាំងត្រូវមានការវិភាគល្អិតល្អន់អំពីតម្រូវការចំណាយទៅតាមសកម្មភាពជាអាទិភាព និងត្រូវមានឯកសារគាំទ្រភ្ជាប់មកជាមួយ ដើម្បីពន្យល់អំពីភាព-ចាំបាច់នៃចំណាយ។ លើសពីនេះ ការគណនាតម្រូវការចំណាយត្រូវផ្អែកទៅលើកត្តាដែលទាក់ទងនឹងមុខសញ្ញាចំណាយ ដូចជា ចំណាយបន្ទុកបុគ្គលិក និងចំណាយមិនមែនបន្ទុកបុគ្គលិកដែលត្រូវប៉ាន់ស្មានតម្លៃជាតុចូលដែលត្រូវការជាក់ស្តែង ដោយធៀបទៅនឹងតម្រូវការប្រើប្រាស់ក្នុងឆ្នាំ២០១៤ និងប៉ាន់ស្មានឆ្នាំ២០១៥ និង ដោយផ្អែកលើថ្លៃឯកតាជាក់ស្តែងនៃទីផ្សារ ឬតាមគោលរបបកំណត់ជាដើម។

២៣- លើមូលដ្ឋាននៃតម្រូវការចំណាយដែលបានប៉ាន់ស្មាននៅក្នុងផែនការយុទ្ធសាស្ត្រថវិកាក្នុងការរៀបចំគម្រោងចំណាយសម្រាប់ឆ្នាំ២០១៦ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ព្រមទាំងព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ត្រូវធានាឱ្យបាននូវការគ្រោងចំណាយរបស់ខ្លួនដោយអនុលោមទៅតាម **គោលការណ៍** និង **បណ្តាវិធានការ** ដូចខាងក្រោម៖

- **ចំណាយបន្ទុកបុគ្គលិក(ជំពូក៦៤)** ត្រូវគ្រោងទៅតាមមូលដ្ឋាននៃក្របខណ្ឌ និងកម្រិតបៀវត្សឆ្នាំ២០១៥សិន ពោលគឺតាមតារាងប្រព័ន្ធប្រាក់បៀវត្សនៃក្រសួងមុខងារសាធារណៈ និងតាមចំនួនមន្ត្រីរាជការដែលមានជាក់ស្តែងក្នុងឆ្នាំ២០១៥។ក្នុងពេលរង់ចាំគោលការណ៍តម្លើងបៀវត្សមន្ត្រីរាជការឆ្នាំ២០១៦ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានគ្រោងថវិកាជាកញ្ចប់រួមសម្រាប់វិស័យនីមួយៗដូចមានចែងនៅក្នុងផ្នែកស្តីពីក្របខណ្ឌចំណាយថវិកាឆ្នាំ២០១៦ ខាងលើ។ ចំពោះមន្ត្រីរាជការដែលត្រូវជ្រើសរើសបន្ថែមថ្មី ត្រូវផ្អែកលើគោលការណ៍បែងចែកដោយក្រសួងមុខងារសាធារណៈ បន្ទាប់ពីទទួលបានគោល-ការណ៍ឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **ពោលគឺចំនួនក្របខណ្ឌថ្មីយ៉ាងច្រើនត្រូវស្មើនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ ផ្ទេរចេញ ឬលាឈប់ពីក្របខណ្ឌរដ្ឋ និងមរណភាព**ដែលត្រូវកាត់ចេញពីអង្គភាពសាមី និងមិនត្រូវគ្រោងថវិកាទេ។ ចំពោះការឡើងឋានៈ និង កាំប្រាក់ត្រូវគ្រោងដោយឡែក និងដោយផ្អែកលើលិខិតយុត្តិការផ្លូវការរបស់រាជរដ្ឋាភិបាល។ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល មិនត្រូវគិតអតិផរណានៅក្នុងការគ្រោងចំណាយបៀវត្សនេះទេ។ ចំពោះបុគ្គលិកជាប់កិច្ចសន្យា និង បុគ្គលិកអណ្តែត ក្រសួងមុខងារសាធារណៈត្រូវស្នើសុំគោល-ការណ៍ឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុន មុននឹងចេញលិខិតអនុញ្ញាតឱ្យក្រសួង ស្ថាប័ន និង មន្ទីរជំនាញរាជធានី ខេត្ត ជ្រើសរើស និងប្រើប្រាស់។

• ចំណាយក្រៅបន្ទុកបុគ្គលិក (**ជំពូក៦០ ការទិញ, ជំពូក៦១ សេវាកម្ម, ជំពូក៦២ អត្ថប្រយោជន៍សង្គម, ជំពូក៦៥ ឧបត្ថម្ភកធន**) ត្រូវគ្រោងក្នុងកម្រិតអតិបរមា ត្រឹមកញ្ចប់ឥណទាននៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ដោយឈរលើគោលការណ៍ដូចខាងក្រោម៖

- **បន្តអនុវត្តសកម្មភាពការងារកំពុងដំណើរការដោយ**ក្រសួង ស្ថាប័ន និងមន្ទីរជំនាញ រាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវគ្រោងចំណាយដោយផ្អែកលើបរិមាណធាតុចូលដែលធ្លាប់ប្រើក្នុងឆ្នាំ២០១៤កន្លងទៅ និងការប៉ាន់ស្មានអនុវត្តនៅក្នុងឆ្នាំ២០១៥ នេះ និង ដោយផ្អែកលើតម្លៃឯកតាជាក់ស្តែងលើទីផ្សារ ហើយជៀសវាងការបង្កើនបរិមាណធាតុចូលលើសពីតម្រូវការដែលធ្លាប់មាន។ ទន្ទឹមនឹងនេះ ត្រូវគ្រោងថវិកាប្រកបដោយលក្ខណៈត្បិតត្បៀត និងសន្សំសំចៃបំផុត ពិសេសលើមុខសញ្ញាទិញឧបករណ៍សម្ភារបរិក្ខារទំនើប គ្រឿងសង្ហារឹមប្រណិត ការបោះពុម្ពប្រណិត ការជួសជុលធំ សម្ភារការិយាល័យ ប្រេងឥន្ធនៈ ការទទួលភ្ញៀវអធឹកអធម និងបេសកកម្មក្នុងនិងក្រៅប្រទេស ព្រមទាំងសោហ៊ុយចំណាយជាអចិន្ត្រៃយ៍ ដូចជា សេវាទូរគមនាគមន៍ អគ្គិសនី និង ទឹកជាដើម
- ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវពិនិត្យឡើងវិញ ហើយកាត់ចេញនូវមុខចំណាយដែលមានតម្រូវការតែសម្រាប់ឆ្នាំ២០១៥ តែលែងត្រូវការនៅក្នុងឆ្នាំ២០១៦ ឬ ដែលសកម្មភាពការងារត្រូវបានបញ្ចប់
- ថវិកាដែលកាត់ចេញពីមុខចំណាយ ឬសកម្មភាពការងារដែលត្រូវបានបញ្ចប់ មិនមែនជាកម្មវត្ថុនៃការវិភាជឡើងវិញជាស្វ័យប្រវត្តិឡើយ គឺលុះត្រាតែមាន**សកម្មភាពការងារចាំបាច់ថ្មី** ឬ**គោលនយោបាយថ្មី** ដែលត្រូវអនុវត្ត ហើយដែលបានលើកឡើងក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៦ ហើយមានយុត្តិការអំពីភាពចាំបាច់ និងបន្ទាន់។

• ក្នុងករណីមានគោលនយោបាយ ឬ/និងសកម្មភាពការងារថ្មី ដែលមានតម្រូវការថវិកាលើសពីកញ្ចប់ឥណទានថវិកាឆ្នាំ២០១៥ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ត្រូវលើកគម្រោងចំណាយនោះដោយឡែក រួមទាំងគម្រោងចំណាយសម្រាប់អាផ្ធារ គណៈកម្មការ ឧត្តមក្រុមប្រឹក្សា ក្រុមប្រឹក្សា និង អង្គភាពដែលចំណុះឱ្យក្រសួង ស្ថាប័ន ដោយបង្ហាញទឡ្ហីករណ៍អំពីភាពចាំបាច់ អាទិភាពខ្ពស់ និងផ្អែកលើទំហំ បរិមាណ និងថ្លៃ ដែលអាចទទួលយកបាន។ ទន្ទឹមនឹងនេះដែរ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមឱវាទ ត្រូវខិតខំធ្វើវិចារណកម្មចំណាយក្នុងរង្វង់ក្របខណ្ឌថវិការបស់ខ្លួន និងខិតខំលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រោងថវិកាឱ្យបានត្រឹមត្រូវ ទាំងបរិមាណ និងតម្លៃឯកតា ជាមុនសិន មុននឹងទទួលបានការពិចារណាលើការបន្ថែមថវិកា។

• ក្នុងគោលបំណងផ្តល់ភាពទន់ភ្លន់ចំពោះក្រសួង ស្ថាប័ន និងមន្ទីរជំនាញ ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្នុងការរៀបចំថវិកា ពិសេស ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងសម្រាប់អនុវត្តសកម្មភាពការងារថ្មី ការកំណត់កញ្ចប់ថវិកាអតិបរមាតាមបណ្តាជំពូកខាងលើ ដោយផ្អែកលើមូលដ្ឋាននៃ

ឥណទានថវិកាឆ្នាំ២០១៥ អាចត្រូវបានអនុញ្ញាតឱ្យធ្វើការកែសម្រួលតាមតម្រូវការជាក់ស្តែង តាមជំពូកនីមួយៗ ដោយរក្សាកញ្ចប់សរុបនៃឥណទានថវិកាក្រៅពីបន្ទុកបុគ្គលិកទាំងអស់ត្រឹមកម្រិតឆ្នាំ២០១៥។ ប៉ុន្តែការរៀបចំគម្រោងចំណាយលម្អិត តម្រូវឱ្យមានការយកចិត្តទុកដាក់ខ្ពស់ដើម្បីបង្កើនសុក្រឹតភាពនៃការគ្រោងថវិកា ព្រោះ *ដូចជាឆ្នាំមុនៗដែរ ការធ្វើនិយ័តកម្មឥណទានថវិកាផ្ទៃក្នុងរបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត អាចនឹងត្រូវអនុញ្ញាតឱ្យធ្វើបានទាល់តែចាប់ពីត្រីមាសទី២ សម្រាប់ក្រសួង ស្ថាប័នអនុវត្តថវិកាកម្មវិធី និងចាប់ពីត្រីមាសទី៣ សម្រាប់ក្រសួង ស្ថាប័នអនុវត្តថវិកាមិនមែនកម្មវិធី។*

២៤- ទន្ទឹមនឹងការគ្រោងចំណាយដោយផ្អែកលើគោលការណ៍នៃការកំណត់កញ្ចប់ និងវិធានការខាងលើ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវធ្វើការ **គណនាតម្រូវការចំណាយនៃជំពូកក្រៅពីបន្ទុកបុគ្គលិក** រួមមាន ជំពូក៦០ ជំពូក៦១ ជំពូក៦២ និងជំពូក៦៥ ដោយផ្អែកលើមូលដ្ឋានពីរដូចខាងក្រោម៖

- *កំណត់ចំណាយជាប្រចាំ ហើយបង្កើតមូលដ្ឋានគណនាតម្រូវការចំណាយនេះ ឱ្យបានច្បាស់លាស់*។ ចំណាយជាប្រចាំ គឺជាចំណាយដែលមានតម្រូវការជាប្រចាំ និងត្រូវការចំណាយប្រចាំឆ្នាំ ដែលរួមមាន ការចំណាយសម្ភារផ្គត់ផ្គង់ និង ថែទាំជាប្រចាំ (ដូចជាសម្ភារផ្គត់ផ្គង់ថែទាំតូចតាចសម្រាប់ថែទាំអគារ ប្រាសាទ ផ្លូវថ្នល់ ស្ពាន លូ រថយន្ត និងឧបករណ៍ប្រើប្រាស់ផ្សេងៗ) និងសម្ភារផ្គត់ផ្គង់រដ្ឋបាលជាប្រចាំ (ដូចជាសម្ភារការិយាល័យ ការបោះពុម្ព និងទិញឯកសារ សម្ភារបរិក្ខារប្រើប្រាស់ជាប្រចាំ ស្បៀងអាហារ និងឯកសណ្ឋានសម្រាប់ក្រសួង ស្ថាប័នមួយចំនួនដែលត្រូវការប្រើប្រាស់ជាប្រចាំ ព្រមទាំងការចំណាយលើអគ្គិសនី ទឹក ប្រេងឥន្ទនៈ និងទូរស័ព្ទជាដើម)។ ប្រភេទចំណាយជាប្រចាំនេះ គួរកំណត់ឱ្យបានច្បាស់លាស់ និងបង្កើតមូលដ្ឋានគណនាឱ្យបានត្រឹមត្រូវ និងសមស្របទៅតាមតម្រូវការជាក់ស្តែង ព្រមទាំងវិភាជទៅតាមអង្គភាពថវិកា នាយកដ្ឋាន ឬអង្គភាពជំនាញដោយផ្ទាល់។
- *កំណត់ចំណាយមិនជាប្រចាំ ហើយត្រូវមានគម្រោងច្បាស់លាស់បញ្ជាក់ពីតម្រូវការ និងប្រសិទ្ធភាពនៃការប្រើប្រាស់ចំណាយមិនប្រចាំនេះ ព្រមទាំងមូលដ្ឋានគណនាតម្រូវការចំណាយនេះឱ្យបានច្បាស់លាស់។* ចំណាយមិនជាប្រចាំគឺជាចំណាយដែលមិនត្រូវការចំណាយប្រចាំឆ្នាំ ដែលរួមមានការចំណាយបំពាក់ឧបករណ៍សម្ភារការិយាល័យ ឧបករណ៍សម្ភារដឹកជញ្ជូន សម្ភារបរិក្ខារបច្ចេកទេស គ្រឿងសង្ហារិម និងឧបករណ៍សម្ភារប្រើប្រាស់ផ្សេងៗដែលជាចំណាយមិនត្រូវទិញប្រចាំឆ្នាំ ព្រមទាំងចំណាយសម្រាប់ការជួសជុល បោះពុម្ពកិច្ចប្រជុំ សិក្ខាសាលា និងបេសកកម្មមួយចំនួនដែលមិនមែនជាសកម្មភាពជាប្រចាំឆ្នាំ។ ប្រភេទចំណាយមិនជាប្រចាំនេះ គួរកំណត់ឱ្យបានច្បាស់លាស់ មានគម្រោង និងកាលវិភាគច្បាស់លាស់សម្រាប់ការចំណាយប្រភេទនេះសម្រាប់រយៈពេលមធ្យម និង មានមូលដ្ឋានគណនាតម្រូវការចំណាយត្រឹមត្រូវទៅតាមតម្រូវការជាក់ស្តែងរបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល។

២៥- ទន្ទឹមនឹងត្រូវផ្អែកលើមូលដ្ឋាននៃថវិកាឆ្នាំ២០១៥ ដែលកំពុងអនុវត្តស្របតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ក្នុងការរៀបចំថវិកាឆ្នាំ២០១៦ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល អាចពិនិត្យផងដែរទៅដល់បម្រែបម្រួលនៃថវិកាក្នុងអំឡុងពេលអនុវត្ត ដែលទាក់ទងទៅនឹងបណ្តាមូលហេតុដូចខាងក្រោម៖

- ចលនាឥណទានដែលបានធ្វើឡើងក្នុងឆ្នាំកំពុងអនុវត្ត ដូចជាការបង្វែរឥណទានថវិកាផ្ទៃក្នុងជំពូក ឬ ពីជំពូកមួយទៅជំពូកមួយទៀត ផ្ទៃក្នុងឬពីកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាពមួយ ទៅកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាពមួយទៀត ដែលធ្វើឱ្យការបែងចែកឥណទានដើមនៃក្រសួង ស្ថាប័ន ព្រមទាំងមន្ទីរជំនាញរាជធានី ខេត្ត មានការប្រែប្រួល។

- ការផ្ទេរឥណទានថវិកាបន្ថែមសម្រាប់ផលប្រយោជន៍របស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត។

២៦- ក្នុងគោលដៅសមាហរណកម្មថវិការបស់ក្រសួង ស្ថាប័ន រវាងសកម្មភាពការងាររដ្ឋបាលកណ្តាល និង មន្ទីរជំនាញរាជធានី ខេត្ត និង អង្គភាពក្រោមឱវាទ ដើម្បីឈានទៅសម្រេចគោលបំណងគោលនយោបាយរបស់ខ្លួន ក្រសួង ស្ថាប័ននីមួយៗ គួររៀបចំជាបណ្តើរៗឱ្យមានជាគោលការណ៍ និងវិធីសាស្ត្រវិភាជថវិកាច្បាស់លាស់ ជាពិសេសនិយាមចំណាយសមស្របសម្រាប់អង្គភាពក្រោមឱវាទ និងមន្ទីរជំនាញរាជធានី ខេត្ត ដែលជាខ្សែបណ្តោយ អាចប្រើប្រាស់ជាមូលដ្ឋានក្នុងការបង្កើនសុក្រឹតភាពនៃការគ្រោងចំណាយប្រចាំឆ្នាំ និងអាចឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រើប្រាស់ជាមូលដ្ឋានក្នុងការវិនិច្ឆ័យលើអំណះអំណាងនៃតម្រូវការថវិកា និងធ្វើការចរចាកំណត់កញ្ចប់ថវិកា ដើម្បីលើកកម្ពស់ ប្រសិទ្ធភាពនៃការវិភាជថវិកា។

២៧- ទន្ទឹមនេះ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលស្ថិតក្រោមក្រសួង ស្ថាប័ននីមួយៗ ត្រូវពង្រឹងតួនាទីក្រុមការងារថវិការបស់ខ្លួន និងត្រូវផ្តល់កិច្ចសហការគ្នាទៅវិញទៅមកជាប្រចាំឱ្យបានពេញលេញក្នុងកម្រិតបច្ចេកទេស ជាមួយក្រុមការងារថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្ម នៃអគ្គនាយកដ្ឋានថវិកា) សំដៅបង្កើនប្រសិទ្ធភាព និងភាពទាន់ពេលវេលានៃការរៀបចំថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ននីមួយៗ។

## គ- កាលវសាននៃការរៀបចំគម្រោងចំណូល-ចំណាយថវិកាឆ្នាំ២០១៦

២៨- រាជរដ្ឋាភិបាលមានកាតព្វកិច្ចរៀបចំឱ្យបានទាន់ពេលវេលា នូវសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦។ នៅក្នុងកិច្ចដំណើរការនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចាប់ផ្តើមការចរចា និងពិភាក្សារៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ជាមួយក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ចាប់ពីថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៥ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥។ **ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ និងធ្វើកំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់នេះ ហើយផ្ញើជូនគណៈរដ្ឋមន្ត្រីឱ្យបាននៅក្នុងសប្តាហ៍ទី១ នៃខែតុលា ឆ្នាំ២០១៥**

ដើម្បីគណៈរដ្ឋមន្ត្រីពិនិត្យ និងសម្រេច ហើយផ្ញើជូនរដ្ឋសភាឱ្យបានក្នុងសប្តាហ៍ទី១ នៃខែវិច្ឆិកា ឆ្នាំ២០១៥ ដើម្បីស្ថាប័ននីតិប្បញ្ញត្តិមានពេលគ្រប់គ្រាន់ក្នុងការពិនិត្យពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់នេះឱ្យបានមុន ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥។

